Food and Agriculture Organization of the United Nations



គោលការណ៍ណែនាំ
សម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)
សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី

# ជីវសុវត្ថិភាពក្នុងកសិដ្ឋាន ការពិឃាតសត្វ និងការចិញ្ចឹមសត្វឡើងវិញ

USAID
FROM THE AMERICAN PEOPLE

គោលការណ៍ណែនាំ
សម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)
សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី

# ជីវសុវត្ថិភាពក្នុងកសិដ្ឋាន ការពិឃាតសត្វ និងការចិញ្ចឹមសត្វឡើងវិញ


**Andrew Bremang**
សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង
**Jeremy Ho**
នាយកដ្ឋានកសិកម្ម វារីវប្បកម្ម និងអភិរក្ស នៃប្រទេសចិនតំបន់រដ្ឋបាលពិសេសហុងកុង
**Anne Conan**
សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង
**Hao Tang**
ការិយាល័យប្រចាំតំបន់របស់ FAO សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក
**Yooni Oh**
ការិយាល័យប្រចាំតំបន់របស់ FAO សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក
**Dirk Pfeiffer**
សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង
សាកលវិទ្យាល័យវេជ្ជសាស្ត្រសត្វ
ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង



**អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ**
**ទីក្រុងភ្នំពេញ ឆ្នាំ ២០២៣**

Required citation:

**Ho, H.P.J., Bremang, A., Conan, A., Tang, H., Oh, Y. and Pfeiffer, D.U. 2023.** *គោលការណ៍ណែនាំសម្រាប់ការបង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី៖ ជីវសុវត្ថិភាពក្នុងកសិដ្ឋាន ការពិឃាតសត្វ និងការចិញ្ចឹមសត្វឡើងវិញ* ភ្នំពេញ ហ្វាវ។

The designations employed and the presentation of material in this information product do not imply the expression of any opinion whatsoever on the part of the Food and Agriculture Organization of the United Nations (FAO) concerning the legal or development status of any country, territory, city or area or of its authorities, or concerning the delimitation of its frontiers or boundaries. The mention of specific companies or products of manufacturers, whether or not these have been patented, does not imply that these have been endorsed or recommended by FAO in preference to others of a similar nature that are not mentioned.

The views expressed in this information product are those of the author(s) and do not necessarily reflect the views or policies of FAO.

**ISBN 978-92-5-137979-0**
**© FAO, 2023**

Some rights reserved. This work is made available under the Creative Commons Attribution-NonCommercial-ShareAlike 3.0 IGO licence (CC BY-NC-SA 3.0 IGO; https://creative commons.org/licenses/by-nc-sa/3.0/igo/legalcode).

Under the terms of this licence, this work may be copied, redistributed and adapted for non-commercial purposes, provided that the work is appropriately cited. In any use of this work, there should be no suggestion that FAO endorses any specific organization, products or services. The use of the FAO logo is not permitted. If the work is adapted, then it must be licensed under the same or equivalent Creative Commons licence. If a translation of this work is created, it must include the following disclaimer along with the required citation: "This translation was not created by the Food and Agriculture Organization of the United Nations (FAO). FAO is not responsible for the content or accuracy of this translation. The original [Language] edition shall be the authoritative edition."

Disputes arising under the licence that cannot be settled amicably will be resolved by mediation and arbitration as described in Article 8 of the licence except as otherwise provided herein. The applicable mediation rules will be the mediation rules of the World Intellectual Property Organization http://www.wipo.int/amc/en/mediation/rules and any arbitration will be conducted in accordance with the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL).

Third-party materials. Users wishing to reuse material from this work that is attributed to a third party, such as tables, figures or images, are responsible for determining whether permission is needed for that reuse and for obtaining permission from the copyright holder. The risk of claims resulting from infringement of any third-party-owned component in the work rests solely with the user.

Sales, rights and licensing. FAO information products are available on the FAO website (www.fao.org/publications) and can be purchased through publications-sales@fao.org. Requests for commercial use should be submitted via: www.fao.org/contact-us/licence-request. Queries regarding rights and licensing should be submitted to: copyright@fao.org.

This publication is made possible by the support of the American People through the United States Agency for International Development (USAID). The contents of this report are the sole responsibility of FAO and do not necessarily reflect the views of USAID or the United States of America Government.

Photo: ©ShutterStock/ccpixx photography

# មាតិកា


សេចក្តីថ្លែងអំណរគុណ v
ពាក្យកាត់ និងពាក្យបំព្រួញ vi
សេចក្តីសង្ខេបចំណុចសំខាន់ៗ vii
ផែនទីគំនិត xxiii
១. សេចក្តីផ្តើម ១
១.១ និយមន័យជីវសុវត្ថិភាព ២
២. តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធលើជីវសុវត្ថិភាព ASF ក្នុងការចិញ្ចឹមជ្រូកនៅអាស៊ីអាគ្នេយ៍ ៥
២.១ ថ្នាក់ដឹកនាំបសុពេទ្យថ្នាក់ជាតិ/ថ្នាក់កណ្តាល ៥
២.២ សមាគមអ្នកចិញ្ចឹមសត្វ និងអង្គការក្រៅរដ្ឋាភិបាល ៦
២.៣ មន្ត្រីបសុពេទ្យ និងមន្ត្រីនៅមូលដ្ឋាន ៧
២.៤ អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ ៧
២.៥ អ្នកជំនាញនៅមូលដ្ឋាន (ពេទ្យសត្វភូមិ ឬអ្នកស្ម័គ្រចិត្តសុខភាពសត្វសហគមន៍) ៨
៣. លក្ខខណ្ឌអប្បរមានៃជីវសុវត្ថិភាព ASF សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ១០
៣.១ ការនាំចូលជ្រូកថ្មីៗទៅក្នុងហ្វូង ១១
៣.២ ចំណី និងទឹក ១២
៣.៣ កម្រាលទ្រុងសត្វ ១៣
៣.៤ យានយន្ត និងសំភារៈបរិក្ខារនានា ១៤
៣.៥ ការប្រគល់ទំនិញ និងការផ្គត់ផ្គង់សំភារៈនានា ១៥
៣.៦ បុគ្គលិក និងការបណ្តុះបណ្តាល ១៥

៣.៧ សត្វព្រៃ សត្វល្អិត និងការបរបាញ់ ១៧
៣.៨ ការគ្រប់គ្រងកាកសំណល់ពីកន្លែងចិញ្ចឹមជ្រូក ១៩
៣.៩ នីតិវិធីសម្អាតទូទៅ និងការរំងាប់មេរោគ ២០
៣.១០ ប្រព័ន្ធជីវៈសុវត្ថិភាព ASF សម្រាប់ការចិញ្ចឹមជ្រូក លក្ខណៈគ្រួសារ ៣៨
៤. ជីវសុវត្ថិភាព ក្នុងអំឡុងពេលផ្ទុះជំងឺ (សម្រាប់មន្ត្រីបសុពេទ្យ) ៥០
៤.១ ការកំណត់អត្តសញ្ញាណបរិវេណ ឬតំបន់មានមេរោគ ៥១
៤.២ ត្រួតពិនិត្យចរាចរណ៍ក្នុងអំឡុងពេលផ្ទុះជំងឺ ៥៨
៤.៣ ការត្រៀមសម្រាប់ការដឹកជញ្ជូនជ្រូករស់ ៦០
៥. ការពិឃាតជ្រូកក្នុងកន្លែងមានមេរោគ ៦២
៥.១ ការពិឃាតសត្វនៅតាមផ្ទះ ៦៣
៥.២ ការដឹកជញ្ជូនទៅសត្តឃាតដ្ឋាន ៦៦
៥.៣ ការរំងាប់មេរោគនៅសត្តឃាតដ្ឋាន ៦៦
៦. ការចិញ្ចឹមសត្វឡើងវិញក្នុងតំបន់មានមេរោគ និងមានការប៉ះពាល់ដ៏គ្រោះថ្នាក់ ៧២
៧. អនាគតនៃនិរន្តរភាពជីវសុវត្ថិភាព ASFV ៧៧
ឯកសារយោង ៨១
សទ្ទានុក្រម ៨៥

# សេចក្តីថ្លែងអំណរគុណ

ឯកសារបោះពុម្ពនេះ ជាលទ្ធផលនៃកិច្ចសហការរវាងការិយាល័យប្រចាំតំបន់របស់អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក (FAO RAP) និងសាកលវិទ្យាល័យទីក្រុងហុងកុង។ ការបោះពុម្ពផ្សាយនេះអាចធ្វើទៅបាន ដោយសារការគាំទ្រដែលផ្តល់ដោយការិយាល័យជំនួយមនុស្សធម៌(BHA) ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)ក្រោមលក្ខខណ្ឌនៃការផ្តល់ជូន No.720FDA19IO00092 ***“ការពង្រឹងសមត្ថភាពអនុវត្តសម្រាប់ការរកឃើញជំងឺប៉េស្តជ្រូកអាហ្វ្រិក និងការឆ្លើយតបបន្ទាន់”***។ មតិដែលបានក្នុងឯកសារណែនាំនេះ គឺជាគំនិតរបស់អ្នកនិពន្ធ និងពុំសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឡើយ។

និយមន័យកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារមិនដូចគ្នាទេ នៅទូទាំងប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ខណៈ ដែលគោលការណ៍ណែនាំទាំងនេះបង្ហាញសម្ភារៈដែលផ្តោតលើម្ចាស់កសិដ្ឋានលក្ខណៈគ្រួសារ វិធានការទាំងអស់ដែលបានពិពណ៌នានៅក្នុងការណែនាំទាំងនេះ នឹងអាចអនុវត្តបានសម្រាប់ការកាត់បន្ថយហានិភ័យជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) នៅក្នុងសហគ្រាសចិញ្ចឹមជ្រូកទាំងអស់។

ការិយាល័យ FAO RAP សូមថ្លែងអំណរគុណចំពោះអ្នកនិពន្ធ Andrew Bremang, Jeremy Ho, Anne Conan, Hao Tang, Yooni Oh និង Dirk Pfeiffer សម្រាប់ការរៀបរៀងឯកសារណែនាំនេះ។ យើងសូមថ្លែងអំណរគុណចំពោះសហការីរបស់ FAO ពោលគឺ Fusheng Guo, Pawin Padungtod និង Tosapol Dejyong ដែលបានផ្តល់មតិយោបល់ដ៏មានតម្លៃលើសេចក្តីព្រាងឯកសារនេះ។ កំណែដែលបានកែសម្រួល ត្រូវបានពិនិត្យដោយអ្នកជំនាញ Carolyn Benigno (ក្រុមហ៊ុនសេវាកម្មសុខភាពសត្វ Philvet), Caitlin Holley (តំណាងអង្គការសុខភាពសត្វពិភពលោក សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក), Jixian Cui (កម្មវិធីបណ្តុះបណ្តាលអំពីរោគរាតត្បាតសម្រាប់បសុពេទ្យនៅតាមមូលដ្ឋានក្នុងប្រទេសចិន) និងក្រុមការងារជំពូកកិច្ច ASF នៃការិយាល័យឧស្សាហកម្មសត្វសម្រាប់ប្រទេសហ្វីលីពីនក្នុងស្មារតីនៃក្រុមអ្នកជំនាញការអេចិន្ត្រៃយ៍ជំងឺប៉េស្តជ្រូកអាហ្វ្រិក(SGE-ASF) សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក, ក្របខ័ណ្ឌសកលសម្រាប់ការត្រួតពិនិត្យវឌ្ឍនភាពនៃជំងឺឆ្លងសត្វ (GF-TADs)។ យើងសូមអរគុណចំពោះការចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃក្នុងការកែលម្អឯកសារណែនាំនេះឱ្យងាយស្រួលប្រើ។

មជ្ឈមណ្ឌលអាសន្នសម្រាប់ជម្ងឺសត្វឆ្លងដែន (ECTAD) នៃការិយាល័យ FAO RAP មន្ត្រីគ្រប់គ្រងថ្នាក់តំបន់ Kachen Wongsathapornchai បានផ្តល់ការណែនាំបច្ចេកទេសក្នុងការរៀបចំឯកសារណែនាំនេះ រួមទាំង Daniela Scalise និង Domingo Caro III ក៏បានផ្តល់មតិយោបល់បន្ថែមទៀតផងដែរ។

គោលការណ៍ណែនាំជាភាសាខ្មែរនេះត្រូវបានបកប្រែ និងពិនិត្យដោយលោក ហាក់ មករា លោក ឳត ស៊ីដេត លោកស្រី ហេង យេន (អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា)និងលោក ភឹម ម៉េងហាក់ (បណ្តាញសាកលវិទ្យាល័យសុខភាពតែមួយអាស៊ីអាគ្នេយ៍)។

# ពាក្យកាត់ និងពាក្យបំព្រួញ

| | | |
|---|---|---|
| ASF | African swine fever | ជំងឺប៉េស្តជ្រូកអាហ្វ្រិក |
| ASFV | African swine fever virus | វីរុសជំងឺប៉េស្តជ្រូកអាហ្វ្រិក |
| DEFRA | Department for Environment Food and Rural Affairs, United Kingdom | ក្រសួងបរិស្ថាន ចំណីអាហារ និងកិច្ចការជនបទ នៃចក្រភពអង់គ្លេស |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| IP | Infected premises | បរិវេណឆ្លងមេរោគ |
| NGOs | Non-governmental organizations | អង្គការក្រៅរដ្ឋាភិបាល |
| OIE | World Organisation for Animal Health | អង្គការពិភពលោកដើម្បីសុខភាពសត្វ |

# សេចក្តីសង្ខេបចំណុចសំខាន់ៗ

## ១. សេចក្តីផ្តើម

គោលការណ៍ណែនាំស្តីពីជីវសុវត្ថិភាពក្នុងកសិដ្ឋាន ការចិញ្ចឹមសត្វឡើងវិញ និងការពិឃាតសត្វ នៅក្នុងប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ត្រូវបានរៀបរៀងឡើងសម្រាប់ប្រើប្រាស់ដោយមន្ត្រីបសុពេទ្យនៅថ្នាក់ជាតិ កណ្តាល (មន្ត្រីបសុពេទ្យ) កសិករនិងអ្នកពាក់ព័ន្ធក្នុងការចិញ្ចឹមជ្រូកនៅអាស៊ីអាគ្នេយ៍។

គោលការណ៍ណែនាំនេះ ផ្តល់ការណែនាំអំពីការអនុវត្តល្អនៅក្នុងការគ្រប់គ្រងជីវសុវត្ថិភាព និងសកម្មភាពពាក់ព័ន្ធនៅក្នុងទីតាំងតូចៗ ឬភូមិនានា ដូចជាការដឹកជញ្ជូន និងការពិឃាតជ្រូក ដើម្បីបង្ការ និងគ្រប់គ្រងការរាលដាលនៃវីរុសប៉េស្តជ្រូកអាហ្វ្រិក។ ការអនុវត្តល្អដែលស្នើឡើងក្នុងកម្រិតអប្បបរមា ឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃខ្សែសង្វាក់ទីផ្សារជ្រូកពីកសិដ្ឋានលក្ខណៈគ្រួសារ ដោយគិតគូរពីកត្តាសេដ្ឋកិច្ចសង្គម និងអាកប្បកិរិយាដែលអាចប៉ះពាល់ដល់ការលក់ជ្រូកទាំងនោះផងដែរ។

ការអនុវត្តវិធានការទាំងនេះ រួមជាមួយ ស្តង់ដារដែលមានស្រាប់សម្រាប់បង្ការ និងគ្រប់គ្រងជំងឺឆ្លងនឹងនាំឱ្យមានកំណើនផលិតភាពនៃការចិញ្ចឹមជារួម និងលើកកម្ពស់ជីវភាពរស់នៅ។

ដង់ស៊ីតេជ្រូកខ្ពស់ និងអត្រាខ្ពស់នៃការផលិតជ្រូកជាទ្រង់ទ្រាយតូចនៅអាស៊ីអាគ្នេយ៍ បង្កើតលក្ខណៈងាយស្រួលសម្រាប់ការរីករាលដាលជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF)។ កត្តានេះត្រូវបានបញ្ជាក់ដោយផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃការសាយភាយ និងការរីករាលដាលថ្មីៗ នៃវីរុស ASF (ASFV) នៅក្នុងតំបន់នេះ។

ក្នុងករណីគ្មានការព្យាបាល និងវ៉ាក់សាំងដែលមានប្រសិទ្ធភាព ការអនុវត្តយុទ្ធសាស្ត្របង្ការ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គឺជាដំណោះស្រាយដ៏ល្អតែមួយគត់។ ការអនុវត្តវិធានការជីវសុវត្ថិភាព ការអប់រំ និងបង្កើតការយល់ដឹងក្នុងចំណោមតួអង្គសំខាន់ៗនៅតាមខ្សែសង្វាក់តម្លៃនៃផលិតកម្មលក្ខណៈគ្រួសារ គឺជាកត្តាសំខាន់ក្នុងការទប់ស្កាត់ និងគ្រប់គ្រងASF ដោយជោគជ័យនៅអាស៊ីអាគ្នេយ៍។ ទោះជាយ៉ាងណាក៏ដោយ អ្នកចិញ្ចឹមសត្វលក្ខណៈ

គ្រួសារភាគច្រើនមានធនធានហិរញ្ញវត្ថុក្នុងកម្រិតកំណត់ និងប្រហែលជាមិនទទួលយក និងអនុវត្តតាមគោលការណ៍ជីវសុវត្ថិភាព ដែលត្រូវចំណាយខ្ពស់នោះឡើយ។ ដើម្បីលើកទឹកចិត្តដល់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ឱ្យទទួលយកវិធានការជីវសុវត្ថិភាពដែលបានកំណត់ គេត្រូវពិចារណាពីលទ្ធភាព និរន្តរភាព និងប្រសិទ្ធភាពនៃការចំណាយ។

## ១.១ និយមន័យជីវសុវត្ថិភាព

- ជីវសុវត្ថិភាព សំដៅលើបណ្តុំនៃវិធានការគ្រប់គ្រង និងវិធានការអនុវត្តផ្សេងៗ ដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យនៃចម្លងជំងឺ ការកកើតជំងឺ និងការរីករាលដាលនៃជំងឺសត្វ ការឆ្លងមេរោគ ឬការបំបែកខ្លួនរបស់មេរោគ ក្នុងហ្វូងសត្វមួយ ឬពីហ្វូងសត្វមួយទៅហ្វូងសត្វមួយទៀត។
- ជីវសុវត្ថិភាពមានសមាសធាតុសំខាន់ៗចំនួនបី ដែលបង្កើតជាមូលដ្ឋាននៃការអនុវត្តជីវសុវត្ថិភាពនៅតាមកសិដ្ឋានផ្ទាល់៖
    - ការបង្ខាំងជីវសាស្រ្ត - វិធានការជីវសុវត្ថិភាពក្នុងបំណងទប់ស្កាត់ ASFV មិនឱ្យចូលទៅក្នុង កសិដ្ឋានចិញ្ចឹមជ្រូក ដូចជា ព័ទ្ធរបង ទឹកថ្នាំលាងជើង ត្រួតពិនិត្យចរាចរណ៍កម្មករ ឬអ្នកមើលថែសត្វ និងចត្តាឡីស័ក។
    - ការគ្រប់គ្រងជីវសាស្រ្ត - វិធានការជីវសុវត្ថិភាពដែលគ្រប់គ្រង និងរក្សាលក្ខខណ្ឌអនាម័យនៃ កសិដ្ឋានចិញ្ចឹមជ្រូក ដូចជា ការសម្អាត និងរំងាប់មេរោគ ការកំណត់ព្រំដែនរវាងកន្លែងស្អាតនិងកន្លែងកខ្វក់ និងការគ្រប់គ្រងសំណល់។
    - ការហ៊ុមព័ទ្ធជីវសាស្រ្ត – វិធានការដែលទប់ស្កាត់ការសាយភាយមេរោគ ASFV និងភ្នាក់ងារបង្ករោគផ្សេងទៀត ពីកសិដ្ឋានមួយទៅកាន់កសិដ្ឋានមួយផ្សេងទៀត ដូចជា ការព័ទ្ធរបង ដើម្បីរារាំងសត្វជ្រូកដែលដើររកស៊ីសេរី ពីការចម្លងមេរោគទៅកន្លែងនានា។

## ២. តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធលើជីវសុវត្ថិភាព ASF ក្នុងផលិតកម្មជ្រូកនៅអាស៊ីអាគ្នេយ៍

- ជីវសុវត្ថិភាពដែលមានប្រសិទ្ធភាព ក្នុងការបង្ការ និងគ្រប់គ្រង ASF នៅកម្រិតកសិដ្ឋានលក្ខណៈគ្រួសារ ទាមទារឱ្យមានកិច្ចសហការប្រកបដោយប្រសិទ្ធភាព រវាងតួអង្គទាំងអស់នៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក និងមន្ត្រីបសុពេទ្យ។
- ការអនុវត្តជីវសុវត្ថិភាព ត្រូវធ្វើឡើងស្របគ្នាជាមួយនឹងការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងអស់ ពោលគឺ អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ បសុពេទ្យ មន្ត្រីបសុពេទ្យ សហគមន៍ និងតួអង្គនានាក្នុងខ្សែសង្វាក់តម្លៃជ្រូកនៃប្រព័ន្ធចិញ្ចឹមលក្ខណៈគ្រួសារ។ តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួន រួមមាន៖
  - មន្ត្រីបសុពេទ្យថ្នាក់ជាតិ/ថ្នាក់កណ្តាល
    - បង្កើត រក្សា និងពង្រឹងការអនុវត្តវិធានការជីវសុវត្ថិភាពក្នុងភាពជាដៃគូជាមួយអ្នកអនុវត្ត និងតួអង្គសំខាន់ៗ តាមខ្សែសង្វាក់តម្លៃជ្រូកថ្នាក់តំបន់ និងថ្នាក់ជាតិ។
  - សមាគមអ្នកចិញ្ចឹមសត្វនិងអង្គការក្រៅរដ្ឋាភិបាល (NGOs)
    - បណ្តុះបណ្តាល និងជួយអ្នកអនុវត្តបឋមលើវិធានការជីវសុវត្ថិភាពដែលបានស្នើឡើងដោយមន្ត្រីបសុពេទ្យ។
  - មន្ត្រីបសុពេទ្យ និងមន្ត្រីនៅមូលដ្ឋាន៖
    - ផ្តល់យោបល់ជំនាញអំពីហានិភ័យនៃ ASFV ដល់កសិដ្ឋានក្នុងតំបន់របស់ពួកគាត់ ដោយផ្អែកលើការវាយតម្លៃអំពីទីតាំងកសិដ្ឋាន ការប្រឈមចំពោះកត្តាហានិភ័យ និងការគ្រប់គ្រងសុខភាពនៃហ្វូងជ្រូក។ និង
    - ណែនាំកសិករអំពីវិធានការល្អៗ ដូចជា ការសម្អាត និងការរំងាប់មេរោគ ដើម្បីជួយគ្រប់គ្រងហានិភ័យ និងជួយការពារការវិនិយោគរបស់កសិករ។
  - អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ (កសិករ)៖
    - ធានាឱ្យមានការអនុវត្តល្អខាងផ្នែកជីវសុវត្ថិភាពក្នុងកសិដ្ឋានរបស់ពួកគាត់ ដើម្បីការពារសុខភាពសត្វ ឬដំណើការចិញ្ចឹមសត្វរបស់ពួកគាត់។

- អ្នកជំនាញនៅមូលដ្ឋាន (បុគ្គលិកពេទ្យសត្វភូមិបុគ្គលិកសុខភាពសត្វសហគមន៍)
  - ឆ្លើយតបនឹងតម្រូវការរបស់អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារតាមការចាំបាច់ និងជួយផ្តល់ឱសថព្យាបាល ឬវីតាមីន។
  - ផ្តល់ដំបូន្មាន និងការបណ្តុះបណ្តាលកសិករអំពីជីវសុវត្ថិភាព និងការថែទាំសត្វ។
  - រាយការណ៍ពីការរកឃើញសត្វដែលមានសុខភាពមិនប្រក្រតី ទៅមន្ត្រីបសុពេទ្យ។ និង
  - ជួយមន្ត្រីបសុពេទ្យក្នុងសកម្មភាពនានាដូចជាការតាមដានឃ្លាំមើលការតាមរកជំងឺ ការគ្រប់គ្រងជំងឺ ការចិញ្ចឹមសត្វឡើងវិញជាដើម។

## ៣. លក្ខខណ្ឌអប្បបរមានៃជីវសុវត្ថិភាព ASF សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ

ការអនុវត្តវិធានការជីវសុវត្ថិភាពក្នុងកម្រិតអប្បបរមាដែលបានស្នើឡើង ដើម្បីអនុវត្តចំពោះការចិញ្ចឹមសត្វលក្ខណៈគ្រួសារ មិនមែនជាដំណោះស្រាយ 'សម្រាប់គ្រប់ស្ថានភាព' ដើម្បីកាត់បន្ថយហានិភ័យ ASFV ឡើយ។ កសិដ្ឋាននីមួយៗត្រូវតែពិចារណាហានិភ័យ ASFV ដោយឡែករបស់ខ្លួន និងគ្រប់ចំណុចដែលមេរោគ ASFV អាចចូលមកក្នុងកសិដ្ឋាននោះ មុនពេលជ្រើសរើសវិធានការសមស្របបំផុតសម្រាប់អនុវត្ត។ ចំណុចសំខាន់ៗមួយចំនួននៃជីវសុវត្ថិភាពដែលត្រូវកត់សម្គាល់គឺ៖

### ៣.១ ការនាំចូលជ្រូកថ្មីៗទៅក្នុងហ្វូង

- ដើម្បីកាត់បន្ថយហានិភ័យនៃការនាំយកមេរោគ ASFV ចូលក្នុងហ្វូងណាមួយ កសិករលក្ខណៈគ្រួសារគួរតែកំណត់កម្រិតញឹកញាប់នៃការនាំយកជ្រូកថ្មីចូលមកក្នុងហ្វូងដែលមានស្រាប់។ បើអាចធ្វើបាន កសិករអាចរៀបចំរចនាសម្ព័ន្ធកសិដ្ឋាន និងផែនការរបស់ខ្លួន ដែលជាការនាំយកជ្រូកមកចិញ្ចឹម និងលក់តាមវគ្គកំណត់។
- កសិករគួរតែទទួលយកជ្រូកជំនួសឱ្យបានច្រើនតាមតែអាចធ្វើទៅបានពីប្រភពដែលទុកចិត្តបានថាគ្មាន ASF។ មន្ត្រីបសុពេទ្យ គួរតែផ្តល់ដោយឥតគិតថ្លៃនូវបញ្ជីឈ្មោះក្រុមហ៊ុនផលិតកូនជ្រូក ឬអ្នកផ្គត់ផ្គង់កូនជ្រូកដែលមានស្ថានភាពល្អ។

- គួរដាក់ជ្រូកទើបមកដល់ថ្មី ឱ្យនៅដាច់ដោយឡែកពីគ្នានៅក្នុងទ្រុងដោយឡែក ឬកន្លែងផ្សេងនៅក្នុងបរិវេណកសិដ្ឋាន/ផ្ទះនិងត្រូវសង្កេតមើលសញ្ញានៃជំងឺក្នុងរយៈពេល ១៤-៣០ថ្ងៃ។ ការអនុវត្តល្អក្នុងការគ្រប់គ្រងសុខភាពមានជាអាទិ៍ ការរក្សាកំណត់ត្រាប្រចាំថ្ងៃអំពីសត្វឈឺ និងងាប់។ ក្រោយពីពេញចិត្តនឹងស្ថានភាពសុខភាពជ្រូកហើយ កសិករអាចបញ្ចូលជ្រូកទាំងនោះទៅក្នុងហ្វូងធំបាន។

## ៣.២ ចំណី និងទឹក

- គ្រឿងផ្សំចំណីអាចឆ្លងមេរោគបានយ៉ាងងាយ ប្រសិនបើមិនរក្សាទុកឱ្យបានត្រឹមត្រូវ។ ជ្រូកព្រៃ និងជ្រូកដើររកស៊ីសេរី សត្វស្លាប សត្វកកេរ និងសត្វព្រៃផ្សេងទៀត អាចចូលមកក្នុងកសិដ្ឋាន និងចម្លងរោគដល់ជ្រូកបាន។ នេះអាចជាចំណុចចាប់ផ្តើមនៃការឆ្លងចូល និងរាលដាលនៃមេរោគ។
- វត្ថុធាតុដើមនៃចំណីផ្សំ ដែលដឹកជញ្ជូនមកកសិដ្ឋាន គួរត្រូវបានផ្ទេរនៅកន្លែងដែលបានកំណត់ណាមួយដែលស្ថិតនៅមាត់ច្រកទ្វារ ឬមាត់ទ្វារឃ្លាំងចំណី។ ត្រូវរក្សាបាវចំណីនៅទីតាំងផ្សេងមួយ ដែលអ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ ទិញពីកន្លែងផ្គត់ផ្គង់/លក់ចំណី។
- ក្នុងករណីប្រើកាកសំណល់ផ្ទះបាយជាចំណីជ្រូក ត្រូវចម្អិនដល់ចំណុចរំពុះយ៉ាងហោចណាស់ ៣០នាទី ដើម្បីរំងាប់វីរុសដែលអាចមានបន្ទាប់មកទុកឱ្យត្រជាក់ មុននឹងផ្តល់ជាចំណីដល់ជ្រូក។ មន្ត្រីបសុពេទ្យ ឬអ្នកជំនាញ (ដូចជា បុគ្គលិកសុខភាពសត្វសហគមន៍) គួរផ្តល់ការបណ្តុះបណ្តាលដល់កសិករអំពីវិធីដាក់ស្តែង ក្នុងការរៀបចំចំអិនកាកសំណល់ពីផ្ទះបាយសម្រាប់ជាចំណីជ្រូក។
- ត្រូវមានប្រភពទឹកស្អាត ហើយប្រសិនបើត្រូវស្តុកទឹកទុកត្រូវគ្របធុងឱ្យជិត។

## ៣.៣ កម្រាលទ្រុងសត្វ

- តាមដែលអាចធ្វើបាន ជៀសវាងយកចំបើង ឬស្មៅជាកម្រាលសម្រាប់ជ្រូកដេកដែលមានប្រភពមកពីតំបន់ដែលមានឆ្លង ASF។ ប្រសិនបើមានការរាតត្បាតASF នៅតំបន់ហើយនោះ ត្រូវស្វែងរកចំបើងឬស្មៅក្នុងមូលដ្ឋាន ឬនៅកន្លែងជិតកសិដ្ឋានបំផុត តាមដែលអាចធ្វើបាន។
- ត្រូវទុកកម្រាលសម្រាប់ជ្រូកដេក ឱ្យនៅឆ្ងាយពីទីចំហ និងឆ្ងាយពីកន្លែងដែលអាចមានជ្រូកព្រៃ ជ្រូកចិញ្ចឹមប្រលែងដទៃទៀត និងសត្វល្អិត។ គេអាចប្រកកម្រាលទាំងនោះក្នុងបាវ ឬថង់ចងមាត់ឱ្យជិតហើយរក្សាទុកនៅលើដំបូល ឬធ្នើរ។

### ៣.៤ យានយន្ត និងសំភារៈបរិក្ខារនានា

- មន្ត្រីបសុពេទ្យ ត្រូវសហការជាមួយភាគីពាក់ព័ន្ធក្នុងខ្សែសង្វាក់តម្លៃជ្រូកតាមមូលដ្ឋាន ដើម្បីផ្តល់ការបណ្តុះបណ្តាលស្តីអំពីវិធានការជីវសុវត្ថិភាពទៅកាន់អ្នកបើកបរ និងឈ្មួញកណ្តាល។ ខ្លឹមសារក្នុងវគ្គបណ្តុះបណ្តាលនេះ គួរតែរួមបញ្ចូលវិធីសាស្ត្រសមស្របសម្រាប់រំងាប់មេរោគ និងជីវសុវត្ថិភាពនៃការចរាចរណ៍ពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀត ដើម្បីបង្ការការរាលដាល ឬឆ្លងមេរោគ ASFV។
- ត្រូវលាងសម្អាត និងរំងាប់មេរោគយានយន្ត ម៉ូតូ រទេះ និងមធ្យោបាយដឹកជញ្ជូនផ្សេងទៀតទាំងអស់ នៅមុន និងក្រោយពេលប្រើប្រាស់ប្រចាំថ្ងៃ។
- ឧបករណ៍ ឬសំភារៈបរិក្ខារទាំងអស់ ដូចជា ខ្សែចងជ្រូក វត្ថុមុតស្រួច ចំណីនិងស្នូក ដែលអាចប៉ះជាមួយសត្វ និងលាមក ឬទឹកនោមសត្វ គួរតែបានរក្សាទុកនៅកសិដ្ឋាន និងមិនត្រូវចរាចរណ៍ ឬប្រើរួមគ្នា រវាងកសិដ្ឋានផ្សេងៗឡើយ។

### ៣.៥ ការប្រគល់ទំនិញ និងការផ្គត់ផ្គង់សំភារៈនានា

- ករណីមានទីធ្លាធំ ត្រូវកំណត់ឱ្យបានសមស្រប រវាងកន្លែងសម្រាប់ទទួលទំនិញនានា ដែលនាំមកតាមរទេះ រ៉ឺម៉ក រថយន្ត ម៉ូតូជាដើម។
- កសិករលក្ខណៈគ្រួសារ គួរតែមានការបាញ់ថ្នាំរំងាប់មេរោគដោយសុវត្ថិភាពលើទំនិញ ឬសំភារៈទាំងឡាយ ដែលបានទិញ ឬដែលបានបញ្ជូនមកដល់កសិដ្ឋាន។

### ៣.៦ បុគ្គលិក និងការបណ្តុះបណ្តាល

- ចរាចរណ៍របស់មនុស្សក្នុងនិងក្រៅកសិដ្ឋាន រួមទាំងសមាជិកគ្រួសារ និងអ្នកថែទាំសត្វផ្សេងទៀត ធ្វើឱ្យមានកំណើនហានិភ័យនៃការឆ្លង ASFV មកក្នុងកសិដ្ឋាន។
- សមាជិកគ្រួសារ ឬកម្មករ និងភ្ញៀវ ត្រូវតែយល់ដឹងអំពីវិធានការជីវសុវត្ថិភាពដើម្បីកាត់បន្ថយហានិភ័យនៃការចំលង ASFV ចូលក្នុងកសិដ្ឋាន។ គេអាចធ្វើបែបនេះបាន ដោយដាក់ស្លាកសញ្ញាដែលអាចមើលឃើញ ជាមួយសារសមស្របនៅតាមទីតាំងសមរម្យ។ សារទាំងនេះគួរតែសរសេរជាភាសាសាមញ្ញ រួមជាមួយរូបភាពលេចធ្លោ ដើម្បីទាក់ទាញការចាប់អារម្មណ៍។
- កម្មករខាងក្រៅកសិដ្ឋាន និងសមាជិកគ្រួសារដែលថែទាំជ្រូក ត្រូវប្រើសម្លៀកបំពាក់និងស្បែកជើងដាច់ដោយឡែកពេលនៅក្នុងកសិដ្ឋាន និងត្រូវប្រើសម្លៀកបំពាក់ទាំងនេះពេលចូលក្នុងកសិដ្ឋាន។ ប្រសិនបើអាចធ្វើបានគួរ

មានកន្លែងប្តូរសម្លៀកបំពាក់នៅក្រោម ឬក្រោយផ្ទះរបស់ម្ចាស់កសិដ្ឋាន។ គួរមានការកំណត់កន្លែងដែលងាយមើលឃើញ ដើម្បីជៀសវាងភាពត្រួតស៊ីគ្នានៃកន្លែងកខ្វក់ និងកន្លែងស្អាត។ បន្ទាប់មក កម្មករ និងសមាជិកគ្រួសារ ដែលថែទាំជ្រូកត្រូវលាងដៃជាមួយសាប៊ូ និងទឹក ដើម្បីឱ្យដៃស្អាតគ្មានមេរោគ មុនចាប់កាន់ឧបករណ៍ ឬសត្វណាមួយ។ ប្រសិនបើកន្លែងជ្រូកជាប់នឹងកន្លែងមនុស្សរស់នៅ គួរមានអាងទឹកថ្នាំលាងជើងនៅច្រកចេញ-ចូលគ្រប់ពេលវេលា។

## ៣.៧ សត្វព្រៃ សត្វល្អិត និងការបរបាញ់

- ពពួកចៃតុកកែ នៅពុំទាន់ត្រូវបានរកឃើញថា ពាក់ព័ន្ធក្នុងការរាលដាលមេរោគ ASFV នៅអាស៊ីទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ គួរមានវិធានការបង្ការ ឬត្រួតពិនិត្យចៃតុកកែ ដែលជាការគ្រប់គ្រងល្អសម្រាប់សត្វក្នុងកសិដ្ឋាន។
- ការអនុវត្តល្អ សម្រាប់បញ្ចៀសចៃតុកកែ ពីកន្លែងចិញ្ចឹមជ្រូក រួមមានការថែទាំ និងជួសជុលសម្ភារៈបរិក្ខារឱ្យបានត្រឹមត្រូវ និងមានអនាម័យល្អ និងការត្រួតពិនិត្យជាប្រចាំ។
- សត្វដែលប្រលែងសេរី ដូចជាបក្សី និងគោក្របី អាចប៉ះពាល់អាហារដែលឆ្លងមេរោគ ASFV ឬ នាំយកមេរោគ ASFV នៅលើខ្លួន ក្រចក បាត/ក្រញាំជើង ជាដើម ហើយអាចចម្លងជំងឺដល់ជ្រូក។ ត្រូវដាក់របាំងការពារផ្នែកនីមួយៗក្នុងទ្រុងជ្រូក និងវាលស្មៅ ឱ្យបានគ្រប់គ្រាន់ ដើម្បីបង្ការការចូលនៃសត្វដទៃ ដូចជា សត្វព្រៃ និងសត្វដែលដើររកស៊ីសេរី។
- គេអាចបាចកាល់ស្យូមអ៊ីដ្រាត (កំបោរ) នៅជុំវិញបរិវេណនៃកសិដ្ឋានសម្រាប់ជាវិធានការបង្ការ ជាពិសេស ប្រសិនបើមានជ្រូកដែលប្រលែងសេរី និងជ្រូកព្រៃច្រើននៅក្នុងមូលដ្ឋាន។ ត្រូវធ្វើការពិនិត្យ និងបាចកំបោរឡើងវិញឱ្យបានទៀងទាត់ (Matsuzaki et al. 2021)។

## ៣.៨ ការគ្រប់គ្រងសំណល់ពីកន្លែងចិញ្ចឹមជ្រូក

- ASFV អាចមានសកម្មភាពរយៈពេលវែង នៅក្នុងទឹកមាត់ សំបោរ ទឹកនោម និងលាមកសត្វ។ ដូច្នេះ ត្រូវពិចារណាចោលលាមកជ្រូកដោយប្រុងប្រយ័ត្ន និងអនុវត្តតាមកម្មវិធីជីវសុវត្ថិភាព។
- គួរធ្វើប្រព្រឹត្តកម្មលាមកជ្រូកនៅក្នុងឡជីវឧស្ម័ននៅនឹងកសិដ្ឋានផ្ទាល់។
- មិនគួរស្ដុកទុក ឬ ចោលលាមកជ្រូកនៅក្រៅកសិដ្ឋានឡើយ។
- ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពទៅប្រើនៅកសិដ្ឋានដាំដំណាំ ឬ កប់

ក្នុងរណ្ដៅ និងប្រព្រឹត្តកម្មសំណល់លាមកជ្រូកបានត្រឹមត្រូវ អាចជាផ្នែកមួយនៃការគ្រប់គ្រងលាមកជ្រូក។

### ៣.៩ នីតិវិធីសម្អាតទូទៅ និងការរំងាប់មេរោគ

- ដើម្បីបង្ការការចម្លង ASFV ការសម្អាតដើម្បីកំចាត់សារធាតុសរីរាង្គទាំងអស់ ដូចជា លាមកជ្រូក ទឹកនោម ចំបើង និងកម្រាលសត្វដេកជាដើម គឺជាជំហានដ៏សំខាន់មួយ មុនពេលធ្វើការរំងាប់មេរោគ។
- មន្ត្រីបសុពេទ្យគ្រប់លំដាប់ថ្នាក់ និងសហគមន៍កសិករ ឬសមាគមអ្នកចិញ្ចឹមសត្វ គួរវិនិយោគលើការ បណ្ដុះបណ្ដាលកសិករចិញ្ចឹមជ្រូកអំពីកិច្ចការនេះ។
- ត្រូវធ្វើការសម្អាតឱ្យបានពិស្ដារនិងគ្រប់ជ្រុងជ្រោយ។ គួរធ្វើការសម្អាតសំភារៈបរិក្ខារនីមួយៗ ផ្នែកនីមួយៗនៃទ្រុង និងកន្លែងនានាឱ្យបានពេញលេញ ដើម្បីកំចាត់រាល់សារធាតុសរីរាង្គទាំងអស់ ដោយប្រើសាប៊ូ ជាពិសេសនៅមុនការប្រើថ្នាំរំងាប់មេរោគ។

## ៤. ជីវសុវត្ថិភាពក្នុងអំឡុងពេលផ្ទុះជំងឺ (សម្រាប់មន្ត្រីបសុពេទ្យ)

វិធានការជីវសុវត្ថិភាព មានសារៈសំខាន់ណាស់ ក្នុងការត្រួតពិនិត្យ និងរាំងខ្ទប់ស្ថានភាពផ្ទុះឡើងនៃជំងឺ ASF។ ការឆ្លើយតបនឹងការផ្ទុះជំងឺ ASF អាចតម្រូវឱ្យធ្វើសកម្មភាពនៅក្នុងបរិវេណនៃកន្លែងឆ្លង ASFV កន្លែងដែលមានការប៉ះពាល់ ASFV ឬបរិវេណដែលគ្មានការឆ្លង នៅក្នុងប្រទេសឬតំបន់ណាមួយ។ ដូច្នេះ បុគ្គលិកដែលធ្វើការឆ្លើយតប ត្រូវតែប្រុងប្រយ័ត្ន ដើម្បីបញ្ចៀសការចម្លងមេរោគជាបន្តបន្ទាប់។ ប្រទេសនីមួយៗអាចអនុវត្តផែនការជាតិសម្រាប់ឆ្លើយតបនឹង ASF ក្នុងករណីមានផែនការបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្បួនជីវសុវត្ថិភាពដែលត្រូវអនុវត្ត ត្រូវតែជាការរៀបចំដោយឡែកសម្រាប់ផលិតកម្មជ្រូកលក្ខណៈគ្រួសារដោយពិចារណាគ្រប់លំនាំហានិភ័យនៃការឆ្លងនៅតាមខ្សែសង្វាក់តម្លៃសាច់ជ្រូក។

### ៤.១ ការកំណត់អត្តសញ្ញាណទីកន្លែង ឬតំបន់មានមេរោគ

- បន្ទាប់ពីបានកំណត់កន្លែងឆ្លងមេរោគនៅក្នុងការផ្ទុះជំងឺASF កិច្ចប្រឹងប្រែង និងវិធានការត្រួតពិនិត្យទាំងអស់ ត្រូវផ្ដោតលើទីតាំងទាំងនេះ ក្នុងកិច្ចប្រឹងប្រែងទប់ស្កាត់ការរាតត្បាតឱ្យបានឆាប់រហ័ស។

- វិធានការតឹងរ៉ឹងនៅក្នុងកន្លែងឆ្លងមេរោគ និងតំបន់ជុំវិញ គួរតែផ្តោតលើប្រព័ន្ធកសិដ្ឋានលក្ខណៈគ្រួសារ ជាពិសេស ក្នុងការទប់ស្កាត់ការប៉ះពាល់ផ្ទាល់ជាមួយជ្រូកដែលដើររកស៊ីសេរី និងជ្រូកព្រៃ។
- ក្នុងករណីគ្មានទីធ្លាទុកដាក់សត្វជាប់ដោយឡែក គេអាចប្រើវិធីដាក់ស្លែង និងការចងសត្វឱ្យនៅមួយកន្លែង។ វិធីទាំងនេះសំខាន់ណាស់ ដើម្បីទប់ស្កាត់ការប៉ះពាល់ជាមួយជ្រូកដែលដើររកស៊ីសេរី ជ្រូកព្រៃ និងថែ។ កសិដ្ឋានលក្ខណៈគ្រួសារដែលមានរបងព័ទ្ធជុំវិញ គួរតែកែលំអរបងរបស់ខ្លួននៅក្នុងអំឡុងពេលមានការផ្ទុះជំងឺ។

### ៤.១.១ ការបែងចែកជាតំបន់

- ក្នុងអំឡុងពេលមានការផ្ទុះជំងឺ ASF តំបន់ភូមិសាស្ត្រដែលមានព្រំប្រទល់ជាក់លាក់ ជាកន្លែងដែល ឆ្លងរោគ ត្រូវបានកំណត់ថាជា 'តំបន់មានមេរោគ' ដែលត្រូវមានវិធានខ្លាំងក្លាដើម្បីទប់ស្កាត់ការរាលដាលបន្ថែមទៀត។
- អាចប្រើប្រាស់ព្រំប្រទល់រដ្ឋបាល ឬវិធានផ្សេងទៀតដែលពាក់ព័ន្ធនឹងអេពីដេមីសាស្ត្រដើម្បីកំណត់វិសាលភាពនៃតំបន់នោះ។
- វិធានការត្រួតពិនិត្យដាក់ស្លែងនៅក្នុងតំបន់មានមេរោគបែបនេះ គួរផ្តោតលើផ្លូវដែលមានចរាចរមមាញឹកដែលស្ថិតនៅជិតសត្តឃាតដ្ឋាន តំបន់មានដង់ស៊ីតេជ្រូកខ្ពស់ ផ្លូវសំខាន់ៗ និងផ្លូវរថភ្លើង។
- នៅក្នុងប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារ ការកំណត់តំបន់មានមេរោគ អាចនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ ដោយសារកសិករ និងឈ្មួញកណ្តាលអាចនៅតែដឹកជញ្ជូនជ្រូកនិងផលិតផលជ្រូកឆ្លងមានមេរោគដោយល្មើសច្បាប់។
- ការដាក់របាំងបិទផ្លូវ ពង្រឹងការបិទផ្លូវជាបណ្តោះអាសន្ន និងបង្កើនការត្រួតពិនិត្យយានយន្ត អាចកាត់បន្ថយកម្រិតនៃភាពច្របូលច្របល់ក្នុងការលក់ ការពិឃាត និងការដឹកជញ្ជូនជាបន្ទាន់ នៅក្នុងករណីមានការផ្ទុះជំងឺ ASF។
- នៅពេលការផ្ទុះជំងឺចាប់ផ្តើមឡើង គួរធ្វើការពង្រីកតំបន់ដែលមានបានកំណត់ថាមានមេរោគ ដើម្បី អាចបញ្ចូលតំបន់ដែលនៅពុំទាន់ច្បាស់លាស់ថាមានការរាលដាលនៃមេរោគ។ បន្ទាប់មក គេអាចកាត់បន្ថយជាបណ្តើរៗនូវវិធីសាស្ត្របង្ការជាមុនបែបនេះ នៅពេលដែលមានព័ត៌មានបន្ថែម។

### ៤.១.២ ការកំណត់បរិវេណនៃកសិដ្ឋានលក្ខណៈគ្រួសារក្នុងពេលផ្ទុះជំងឺ

- ក្នុងអំឡុងពេលផ្ទុះជំងឺ ASF យ៉ាងសកម្ម គ្រប់គ្រួសារ កសិដ្ឋាន ឬសូម្បីតែភូមិទាំងមូល ក៏អាចនឹងត្រូវចាត់ទុកថាជា តំបន់មានមេរោគ សម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យ ដោយអាស្រ័យលើទំនាក់ទំនងនៃករណីជំងឺរាតត្បាតនោះ ជាមួយទីតាំងដែលជាប់សង្ស័យ។
- បរិវេណនានាអាចត្រូវចាត់ជា កន្លែងមានមេរោគ កន្លែងប៉ះពាល់ដ៏គ្រោះថ្នាក់ កន្លែងមានហានិភ័យ កន្លែងនៅក្រោមការតាមដាន ឬកន្លែងគ្មានការឆ្លងជំងឺ។

### ៤.២ ត្រួតពិនិត្យការចរាចរណ៍ក្នុងអំឡុងពេលផ្ទុះជំងឺ

- វិធានការចត្តាឡីស័ក និងការត្រួតពិនិត្យបម្លាស់ទី ក្នុងអំឡុងពេលឆ្លើយតបនឹងការផ្ទុះមេរោគ ASFV មានសារៈសំខាន់ចំពោះជោគជ័យនៃកិច្ចប្រឹងប្រែងដើម្បីបញ្ឈប់ការរាលដាលនេះ។ ការផ្លាស់ទីនៃជ្រូកដែលអាចមានមេរោគ ផលិតផលមានមេរោគ ចរាចរណ៍មនុស្សដែលមានមេរោគ និងការដឹកជញ្ជូនពីតំបន់ដែលមានមេរោគ អាចធ្វើឱ្យការរាលដាល ASF ប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស។
- មន្ត្រីបសុពេទ្យ ដោយផ្អែកលើច្បាប់ដែលមានស្រាប់ គួរចេញវិធានការអនាម័យតឹងរ៉ឹងភ្លាមៗ ដើម្បីតម្រូវឱ្យធ្វើចត្តាឡីស័ក និងបញ្ឈប់ជាបណ្តោះអាសន្ន នូវការធ្វើចរាចរណ៍ចូល និងចេញពីតំបន់ត្រួតពិនិត្យ និងកន្លែងប៉ះពាល់ដែលពាក់ព័ន្ធ។
- ការចេញវិធានការអនាម័យ ដែលមានបំណងលុបបំបាត់ការឆ្លង អាចមិនសម្រេចទៅបានទេ។ ដូច្នេះ គួរពិចារណាយុទ្ធសាស្ត្រត្រួតពិនិត្យជាជំនួសដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្ទុះជំងឺ ASF លើផលិតកម្មសត្វជ្រូក។
- ទោះជាប្រើយុទ្ធសាស្ត្រត្រួតពិនិត្យបែបណាក៏ដោយ ប្រការសំខាន់គឺត្រូវធានាថា កសិករផ្តល់កិច្ចសហប្រតិបត្តិការជាអតិបរមា។ នេះជាគន្លឹះដើម្បីកាត់បន្ថយការរត់ពន្ធជ្រូក និងផលិតផលជ្រូក ដែលអាចមានមេរោគ ASFV។
- មន្ត្រីបសុពេទ្យ គួរផ្តល់លទ្ធភាពដល់កសិដ្ឋានដែលគ្មានទំនាក់ទំនងជាមួយការឆ្លងរោគ គ្មានការប៉ះពាល់ដ៏គ្រោះថ្នាក់និងគ្មានហានិភ័យខ្ពស់ ដើម្បីទទួលបានការអនុញ្ញាតពិសេសសម្រាប់ដឹកជញ្ជូនជ្រូកទៅសត្តឃាតដ្ឋាននៅក្រោមលក្ខខណ្ឌជីវសុវត្ថិភាពតឹងរ៉ឹង។

### ៤.៣ ការត្រៀមក្នុងការដឹកជញ្ជូនជ្រូករស់

- មានតែជ្រូកពីតំបន់ ឬកន្លែងគ្មានមេរោគ ASFV ដែលរួមទាំងតំបន់នៅក្រោមការត្រួតពិនិត្យ ដែលមានលិខិតអនុញ្ញាតសមស្រប ទើបអាចដឹកជញ្ជូនជ្រូកទៅកសិដ្ឋានផ្សេងបាន។ មុនពេលដឹកជញ្ជូន គួរមានការដាក់ជ្រូកទាំងនោះនៅដាច់ដោយឡែកពីគ្នា យ៉ាងហោចណាស់ ១៤ ថ្ងៃ ដើម្បីធានាថា គ្មានមេរោគ ASFV។ ការធ្វើបែបនេះចាំបាច់ខ្លាំងណាស់ ដើម្បីអាចរកមើលរោគសញ្ញាបន្ទាប់បន្សំ។
- ទោះជាយ៉ាងណាក៏ដោយ កសិដ្ឋានប្រភពដើម គួរធានាអនុលោមភាពជាមួយលក្ខខណ្ឌអប្បបរមានៃជីវសុវត្ថិភាព ក្នុងអំឡុងពេលដឹកជញ្ជូន ក្រោមការត្រួតពិនិត្យតឹងរ៉ឹងនៃមន្ត្រីបសុពេទ្យ។
- ឡានដឹកទំនិញត្រូវប្រើតែផ្លូវដែលកំណត់ដោយមន្ត្រីបសុពេទ្យ ប្រសិនបើមានការកំណត់បែបនេះ និងកាត់បន្ថយការឈប់តាមផ្លូវ មកត្រឹមកម្រិតអប្បបរមា ប្រសិនបើចាំបាច់។

## ៥. ការពិឃាតសត្វក្នុងកន្លែងមានផ្ទុះជំងឺ

- សកម្មភាពពិឃាតសត្វ ក្នុងកំឡុងពេល ដែលផ្ទុះយ៉ាងសកម្មនៃជំងឺ ASF មានសក្តានុពលក្នុងការបង្កើនអត្រានៃការរាលដាល ASFV ជាពិសេសក្នុងករណីដែលគ្មានសេវាពិនិត្យសាច់សត្វដោយមន្ត្រីបសុពេទ្យ។
- កម្មករនៅសត្តឃាតដ្ឋាន អ្នកផ្តល់សេវាពិឃាតសត្វ និងកសិករចិញ្ចឹមជ្រូកដែលពិឃាតជ្រូកដោយខ្លួនឯងដើម្បីយកសាច់ អាចមានមេរោគឆ្លង ដូច្នេះអាចជាភ្នាក់ងារចម្លងមេរោគ ASFV។
- កន្លែងពិឃាតសត្វយកសាច់ គួរស្ថិតនៅឆ្ងាយពីកន្លែងរក្សាទុកជ្រូក និងជាដំណើរការដែលមានលំហូរឯកទិស ពីកន្លែងកខ្វក់ (កន្លែងពិឃាតជ្រូក) ទៅកន្លែងស្អាត(កន្លែងកាត់ច្រៀកសាច់)។
- មន្ត្រីបសុពេទ្យគួរធានាថា សាច់ជ្រូកដែលមានគោលដៅសម្រាប់លក់មានដាក់សញ្ញាសម្គាល់ដោយឡែក ជាមួយត្រា និងការយល់ដឹងដែលបង្កើតឡើង ក្នុងចំណោមសាធារណៈជនទូទៅ។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយការកាប់ជ្រូកដែលមានផ្ទុកមេរោគដើម្បីយកសាច់ ដោយសារភាពស្លន់ស្លោចំពោះស្ថានភាពនេះ។

- សម្រាប់ការធ្វើពិឃាតសត្វតាមផ្ទះ គួរបញ្ចុះបញ្ចូលកសិករ ដោយបង្កើតការយល់ដឹងប្រកបដោយប្រសិទ្ធភាព និងការបណ្តុះបណ្តាលពីការកំណត់រោគសញ្ញាជំងឺមុនពេលពិឃាតជ្រូក។
- ម្ចាស់សត្តឃាតដ្ឋានត្រូវធានាឱ្យមានការសម្អាត និងរំងាប់មេរោគឱ្យបានហ្មត់ចត់ ចំពោះយានដឹកជញ្ជូនទាំងអស់ (ខាងក្នុង និងខាងក្រៅ) ដែលនាំជ្រូកមកកន្លែងរបស់ខ្លួន ដោយយកចិត្តទុកដាក់ជាពិសេសចំពោះ កង់ ផ្ទៃខាងក្នុងកាប៊ីន ផ្នែកកន្លៀតនានា និងផ្ទៃខាងក្រោម។
- ម្ចាស់សត្តឃាតដ្ឋាន ត្រូវត្រួតពិនិត្យរាល់ការចូល និងការចរាចរណ៍បុគ្គលិកនៅក្នុងបរិវេណនៃសត្តឃាតដ្ឋានរបស់ខ្លួន។ ត្រូវហាមបុគ្គលិកពីការចូលទស្សនាកសិដ្ឋានចិញ្ចឹមជ្រូក និងបរបាញ់សត្វ។

## ៥.១ ការពិឃាតសត្វនៅតាមផ្ទះ

- មន្ត្រីបសុពេទ្យគួរធានាថា សាច់ទាំងអស់សម្រាប់មនុស្សបរិភោគ មានប្រភពពីសត្វដែលបានពិឃាតក្នុងសត្តឃាតដ្ឋានដែលមានការអនុញ្ញាត ក្រោមការពិនិត្យនៃមន្ត្រីជំនាញនៅមូលដ្ឋាន។
- គួរជៀសវាងការផ្លាស់ទីនៃអ្នកកាប់ជ្រូកក្នុងមូលដ្ឋាន ពីកន្លែងមួយទៅកន្លែងមួយទៀត។ ក្នុងអំឡុងពេលមានកម្មវិធីប្រពៃណីក្នុងភូមិ គ្រួសារនានាតែងពិឃាតជ្រូកសម្រាប់បរិភោគនៅផ្ទះ ហើយអាចជួលអ្នកកាប់ជ្រូកមកពិឃាតសត្វសម្រាប់គ្រួសារខ្លួន។ អ្នកភូមិអាចរៀបចំផែនការដើម្បីឱ្យមន្ត្រីបសុពេទ្យពិនិត្យជ្រូក និងវិធីពិឃាតសត្វ ដែលគ្រប់គ្រងការចរាចរណ៍របស់អ្នកពិឃាតសត្វ ឬចាត់តាំងអ្នកពិឃាតសត្វច្រើននាក់ ដើម្បីផ្តល់សេវាដល់គ្រួសារមួយក្នុងពេលតែមួយ។
- គួរហាមឃាត់យ៉ាងតឹងរ៉ឹងនូវការពិឃាតជ្រូកតាមផ្ទះ(ច្រើនជាងមួយក្បាល) សម្រាប់លក់។
- ម្ចាស់អាជីវកម្មលក្ខណៈគ្រួសារដែលពិឃាតជ្រូកតាមផ្ទះ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន គួរធានាថា៖
  - មានតែជ្រូកដែលមានសុខភាពល្អ ដែលគ្មានរោគសញ្ញាប៉ុណ្ណោះដែលត្រូវបានពិឃាតយកសាច់។
  - ការពិឃាតធ្វើឡើងនៅឆ្ងាយគ្រប់គ្រាន់ពីកន្លែងស្តុកជ្រូក និងនៅលើផ្ទៃរឹង ដែលងាយស្រួលបង្ហូរទឹកចេញ សម្អាត និងរំងាប់មេរោគ។
  - ការសម្អាត និងការរំងាប់មេរោគ ធ្វើឡើងបន្ទាប់ពីការពិឃាតជ្រូក។ និង
  - គ្មានការចរាចរណ៍ដោយខុសច្បាប់នូវជ្រូកទាំងមូលឬសាច់ជ្រូកឡើយ។

- កសិករ អ្នកកាប់ជ្រូក ឈ្មួញកណ្ដាល និងអ្នកទិញ ត្រូវទទួលការបណ្ដុះបណ្ដាល ដើម្បីបង្កើនការយល់ដឹងពីមូលហេតុដែលត្រូវហាមឃាត់ការពិឃាតជ្រូកតាមផ្ទះ សម្រាប់លក់ជាលក្ខណៈពាណិជ្ជកម្ម និងការបន្តអនុវត្តបែបនេះអាចមានផលវិបាកចំពោះការរាលដាលនៃជំងឺ។
- មន្ត្រីបសុពេទ្យ គួរចាត់ចែងឱ្យមានដំណើរការចុះបញ្ជីសត្តឃាតដ្ឋានជាក់ស្ដែង និងអាចធ្វើទៅបាន ដើម្បីបង្កើនទំនុកចិត្តក្នុងចំណោមអាជីវករក្នុងស្រុក។

## ៥.២ ការដឹកជញ្ជូនទៅសត្តឃាតដ្ឋាន

- ម្ចាស់កសិដ្ឋានលក្ខណៈគ្រួសារដែលមានទំនាក់ទំនងផ្ទាល់ជាមួយសត្តឃាតដ្ឋាន និងដឹកជញ្ជូនជ្រូកដោយផ្ទាល់ គួរមានលិខិតអនុញ្ញាតជាចាំបាច់ពីមន្ត្រីបសុពេទ្យ។
- រថយន្តដឹកទំនិញ រ៉ឺម៉ក និងរទេះរុញ គួរតែត្រូវបានសម្អាត និងរំងាប់មេរោគឱ្យបានហ្មត់ចត់ បន្ទាប់ពីប្រើប្រាស់សម្រាប់ការដឹកជញ្ជូន។
- សត្តឃាតដ្ឋានជាគោលដៅ គួរមានប្លង់បង្ហាញពីការដឹកជញ្ជូនដែលអាចធ្វើទៅបាន ដោយគ្មាន ឬមានការប៉ះពាល់តិចតួចបំផុតជាមួយរថយន្តដឹកទំនិញផ្សេងទៀត។ ចំណុចផ្ទេរទំនិញនៅសត្តឃាតដ្ឋាន មិនគួរឱ្យមានយានយន្ត អ្នកបើកបរ និងជ្រូកផ្សេងជួបគ្នា ឬលាយច្របល់គ្នាឡើយ។
- បើអាចធ្វើបាន សត្តឃាតដ្ឋានគួរផ្ដល់មធ្យោបាយរំងាប់មេរោគសម្រាប់យានយន្តនីមួយៗ មុនពេលចូលផ្ទេរទំនិញ ក៏ដូចជា នៅពេលចេញពីសត្តឃាតដ្ឋានផងដែរ។
- ត្រូវមានការត្រួតពិនិត្យយានយន្តដឹកជញ្ជូនយ៉ាងហ្មត់ចត់ដោយកសិករ ឬអ្នកជំនួយការនៅកន្លែងផ្ទុកទំនិញដែលបានកំណត់។ ត្រូវជូនដំណឹងដល់កសិករ អ្នកបើកបរ និងអ្នកជំនួយការ អំពីកន្លែងដែលអាចអនុញ្ញាត និងមិនអនុញ្ញាតចេញចូល បើអាចធ្វើបាន និងអនុញ្ញាតឱ្យប្រើតែផ្លូវដែលអាចបញ្ចៀសតំបន់ដែលមានមេរោគ។ កសិដ្ឋានជាប្រភពដើម ត្រូវប្រាស្រ័យទាក់ទងគ្នាជាប្រចាំជាមួយចំណុចសត្តឃាតដ្ឋានជាគោលដៅ រហូតមានការប្រគល់ទំនិញដោយសុវត្ថិភាព។

## ៥.៣ ការរំងាប់មេរោគនៅសត្តឃាតដ្ឋាន

- ការចាត់ចែងឱ្យមានកម្មវិធីអប់រំ និងបណ្ដុះបណ្ដាលជាក់លាក់ដល់សត្តឃាតដ្ឋាន និងជីវសុវត្ថិភាព ASFV សម្រាប់កម្មករទាំងអស់ និងអ្នកគ្រប់គ្រងសត្តឃាតដ្ឋាន គឺជាប្រការសំខាន់។

- អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន គួរចងក្រងឯកសារអំពីការអនុវត្តជាប្រចាំនូវជីវសុវត្ថិភាពរបស់ខ្លួននៅក្នុងកម្មវិធីសម្អាតលម្អិតដែលគិតគូរពីបរិបទជាក់លាក់នៃសត្តឃាតដ្ឋាន រួមទាំងធានាថា៖
  - មានក្រុមទទួលខុសត្រូវសម្អាត និងរំងាប់មេរោគ ដែលម្នាក់ៗយល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន។
  - មានរបៀបសមស្របសម្រាប់ការរាយការណ៍ និងស្ថានភាពមិនប្រក្រតីឡើងវិញ។
  - មានចែងច្បាស់លាស់ពីគោលការណ៍នៃការលាងសម្អាត និងការរំងាប់មេរោគ។
  - មានការចូលរួមនៃកម្មករទាំងអស់ក្នុងអំឡុងពេល និងក្រោយពេលកាប់សាច់ដែលពិឃាតរួច។
- អ្នកគ្រប់គ្រងសត្តឃាតដ្ឋានគួរធានាឱ្យមានការសម្អាត និងរំងាប់មេរោគ (មិនត្រូវរំលងដំណើរការនេះឡើយ)។ គួរយកចិត្តទុកដាក់ចំពោះតម្រូវការថាមពល អាស្រ័យតាមប្រភេទសត្តឃាតដ្ឋាន។ ទីសត្តឃាតនៅតាមផ្ទះ និងក្នុងទីចំហ តាមធម្មតាអាចគ្មានឧបករណ៍សម្រាប់សម្អាត។
- បុគ្គលិក និងអ្នកសម្អាត គួរបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវអំពីដំណើរការសម្អាត និងការរំងាប់មេរោគដែលសមស្រប ជាពិសេសរបៀបប្រើប្រាស់ឧបករណ៍ និងបរិក្ខារដែលមានស្រាប់។
- គួរដាក់ឱ្យអនុវត្តនីតិវិធីសម្អាត និងរំងាប់មេរោគជាក់លាក់ជាប្រចាំ បន្ទាប់ពីមានការចាត់ចែងនៅមុនវគ្គសម្អាត ការសម្អាតនិងរំងាប់មេរោគ និងសកម្មភាពក្រោយការសម្អាតនិងរំងាប់មេរោគ។

## ៦. ការចិញ្ចឹមសត្វឡើងវិញក្នុងតំបន់មានមេរោគ និងការប៉ះពាល់ដ៏គ្រោះថ្នាក់

- បន្ទាប់ពីការកំណត់អត្តសញ្ញាណទីកន្លែងមានមេរោគ និងប៉ះពាល់ដ៏គ្រោះថ្នាក់ ត្រូវធ្វើសត្តឃាតជ្រូកទាំងអស់ក្នុងកន្លែងនោះភ្លាមៗ បន្តដោយនីតិវិធីនៃការបោលសាកសព និងការកំចាត់មេរោគ។
- មន្ត្រីបសុពេទ្យ ត្រូវបង្ហាញកន្លែងដែលមានមេរោគ និងកន្លែងប៉ះពាល់មេរោគពីមុនមកទាំងនេះ ថាលែងមានហានិភ័យនៃជំងឺ ASFV ទៀតហើយ ជាមួយភាពប្រាកដប្រជាសមហេតុផល។

- បន្ទាប់មក ត្រូវទុកកន្លែងដែលមានមេរោគ និងកន្លែងប៉ះពាល់ដ៏គ្រោះថ្នាក់ទាំងនេះ ចោលទំនេរយ៉ាងហោចណាស់រយៈពេល ៤០ថ្ងៃ ប្រសិនបើគ្មានភ្នាក់ងារបង្ករោគណាមួយជាប់ទាក់ទងនឹងការផ្ទុះជំងឺនៅក្នុងបរិវេណនៃកន្លែងនោះ។
- ក្រោយផុតរយៈពេលតម្រូវឱ្យទុកនៅទំនេរគ្មានសត្វចិញ្ចឹម កសិករអាចបន្តការចិញ្ចឹមសត្វនៅក្នុងកសិដ្ឋានរបស់ខ្លួនឡើងវិញ នៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីបសុពេទ្យ ដោយដាក់ជ្រូកដែលមានសុខភាពល្អ និងដែលគ្មានមេរោគ ASF តាមនីតិវិធីនៃការចិញ្ចឹមសត្វឡើងវិញជ្រូកឡើងវិញ។
- មន្ត្រីបសុពេទ្យអាចអនុញ្ញាតឱ្យដាក់ជ្រូកសង់ទីណែល ត្រឹម ១០% នៃសមត្ថភាពស្តុកធម្មតានៅក្នុងកន្លែងទាំងនេះ ដើម្បីកាត់បន្ថយហានិភ័យនៃការកើត ASFV ឡើងវិញ។ ក្នុងករណីពុំអាចធ្វើបែបនេះបាន គួរអនុញ្ញាតឱ្យកសិករទិញជ្រូកសង់ទីណែល តាមចំនួនដែលពួកគេមានលទ្ធភាពទិញ។
- មន្ត្រីបសុពេទ្យគួរធ្វើការតាមដានជ្រូកសង់ទីណែលទាំងនេះដើម្បីរកមើល ASFV យ៉ាងហោចណាស់ប្រាំមួយ(៦)សប្តាហ៍ មុនអនុញ្ញាតឱ្យដាក់សត្វចិញ្ចឹមឡើងវិញទាំងស្រុង។ គួរបន្តតាមដានឃ្លាំមើល ASFV នៅកសិដ្ឋានដែលបានដាក់ជ្រូកចិញ្ចឹមសាកល្បងឡើងវិញទាំងស្រុង ដរាបណានៅតែមានហានិភ័យនៃការឆ្លង មេរោគមកកន្លែងនេះឡើងវិញ។
- ក្នុងករណីដែលមានការរកឃើញថា ស្ថានភាពនៃ ASFV ជាប់ពាក់ព័ន្ធជាមួយចៃតុកកែ (ពុំទាន់បានរកឃើញពីទំនាក់ទំនងនេះនៅអាស៊ីអាគ្នេយ៍នៅឡើយទេ) ត្រូវមានការរឹតត្បិតលើការបង្កើនចំនួនជ្រូក រហូតដល់មន្ត្រីបសុពេទ្យ បានត្រួតពិនិត្យ និងលុបបំបាត់ចៃតុកកែ និងភ្នាក់ងារចម្លងរោគផ្សេងទៀតពីកន្លែងនោះបានទាំងស្រុង។
- ការរឹតត្បិតលើកសិដ្ឋានដែលដាក់ចិញ្ចឹមជ្រូកឡើងវិញ គួរតែអាចបន្ធូរបន្ថយបាននៅពេលដែលមន្ត្រីបសុពេទ្យបានបញ្ជាក់ថា មេរោគត្រូវបានកំចាត់ ហើយការឃ្លាំមើលជ្រូកសង់ទីណែលទាំងអស់បានអនុវត្តក្នុងរយៈពេលយ៉ាងតិច ៦០ ថ្ងៃបន្ទាប់ពីការចិញ្ចឹមសត្វឡើងវិញជ្រូកឡើងវិញ។

## ៧. អនាគតនៃនិរន្តរភាពជីវសុវត្ថិភាព ASFV

គោលការណ៍ណែនាំស្តីពីជីវសុវត្ថិភាព ការចិញ្ចឹមជ្រូកឡើងវិញ និងការពិឃាតជ្រូក នៅក្នុងប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ត្រូវបានរៀបរៀងឡើងសម្រាប់ប្រើប្រាស់ដោយមន្ត្រីបសុពេទ្យថ្នាក់ជាតិ ឬថ្នាក់កណ្តាល (មន្ត្រីបសុពេទ្យ) កសិករ និងអ្នកពាក់ព័ន្ធក្នុងផលិតកម្មជ្រូកនៅអាស៊ីអាគ្នេយ៍។ ឯកសារនេះផ្តល់ការណែនាំអំពីការអនុវត្តល្អលើការគ្រប់គ្រងជីវសុវត្ថិភាព និងសកម្មភាពពាក់ព័ន្ធនៅក្នុងទីតាំងតូចៗ ឬភូមិនានា ដូចជា ការចរាចរណ៍ និងការធ្វើសត្តឃាតជ្រូក ដើម្បីការពារ និងត្រួតពិនិត្យការរាលដាលនៃមេរោគប៉េស្តជ្រូកអាហ្វ្រិក។ ការអនុវត្តល្អដែលស្នើឡើងក្នុងកម្រិតអប្បបរមានេះ ឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃខ្សែសង្វាក់ទីផ្សារជ្រូកលក្ខណៈគ្រួសារ ដោយគិតគូរពីកត្តាសេដ្ឋកិច្ចសង្គម និងអាកប្បកិរិយាដែលអាចប៉ះពាល់ដល់ការលក់ជ្រូកទាំងនេះ។ យើងរំពឹងថា ការអនុវត្តវិធានការទាំងនេះ រួមជាមួយ ស្តង់ដារដែលមានស្រាប់សម្រាប់ការបង្ការ និងត្រួតពិនិត្យជំងឺឆ្លង នឹងនាំឱ្យមានការបង្កើន ផលិតកម្មជ្រូក និងលើកកម្ពស់ជីវភាពរស់នៅជារួម។

# ផែនទីគំនិត



ការសម្អាត & រំងាប់មេរោគ
• ការគ្រប់គ្រងលាមកសត្វ
• ជំហាននៃការសម្អាត & រំងាប់មេរោគសម្រាប់៖
•បរិវេណនៃកសិដ្ឋាន
•យានយន្ត
•សំភារៈបរិក្ខារ
• ជម្រើសថ្នាំរំងាប់ ASFV
ធាតុចូល
• ការនាំចូលជ្រូករស់
• ការប្រើកម្រាលសម្រាប់ជ្រូកដេក
• ការពិចារណាអំពីចំណី & ទឹក
• ការចំអិនចំណីជ្រូក
• ការទទួលទំនិញ &សម្ភារៈផ្គត់ផ្គង់
ការបណ្តុះបណ្តាល
• អាណាព្យាបាល & សមាជិកគ្រួសារ
• ម្ចាស់កសិដ្ឋាន
• បង្កើតការយល់ដឹង
ការចរាចរណ៍
• បុគ្គលិក & ភ្ញៀវ
• ការចរាចរណ៍សត្វព្រៃ & សត្វចិញ្ចឹម
1 ការគ្រប់គ្រងជីវសុវត្ថិភាពក្នុងកសិដ្ឋាន
តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ
ពិចារណាអំពីរោគឆ្លង
អំឡុងពេលការចិញ្ចឹមសត្វឡើងវិញ
4 ការពិចារណាអំពីការចិញ្ចឹមសត្វឡើងវិញសម្រាប់ត្រួតពិនិត្យ ASF
ជីវសុវត្ថិភាព ASF
ការចូលរួមនៃអ្នកពាក់ព័ន្ធ
ការឃ្លាំមើលជ្រូកសង់ទីណែល ឬការផ្តល់សំណង
ការពិឃាតសត្វនៅតាមគ្រួសារ
3 ការពិចារណាអំពីការពិឃាតជ្រូក ដើម្បីត្រួតពិនិត្យ ASF
2 ជីវសុវត្ថិភាព ASF ក្នុងអំឡុងពេលផ្ទុះជំងឺ
ជីវសុវត្ថិភាពក្នុងការដឹកជញ្ជូន
ជីវសុវត្ថិភាព ASF ក្នុងសត្តឃាតដ្ឋាន និងពេលពិឃាត
ការឆ្លើយតប ឬគ្រប់គ្រងការផ្ទុះជំងឺ
ការសម្អាតនិងរំងាប់មេរោគ នៅកន្លែងពិឃាតសត្វ
ការកំណត់តំបន់និងបរិវេណនានាទៅតាមស្ថានភាព
ការរឹតត្បិតលើការចរាចរណ៍ជ្រូករស់ ឬសាច់ជ្រូក
ការពិឃាតសត្វឈឺ ការកំចាត់មេរោគនិងការកំទេចចោលសាកសពសត្វ


© FAO/R. Willis

# ១ សេចក្ដីផ្ដើម

ការអនុវត្តវិធានការជីវសុវត្ថិភាព គឺជាការចាំបាច់សម្រាប់ថែរក្សាសត្វអោយមានសុខភាពល្អ នៅក្នុងប្រព័ន្ធចិញ្ចឹមលក្ខណៈគ្រួសារ និងក្នុងបំណាងត្រួតពិនិត្យ និងលុបបំបាត់ជំងឺ។ ទោះបីជាវិធានការជីវសុវត្ថិភាពជាមូលដ្ឋានដែលមានស្រាប់ អាចការពារទល់នឹងជំងឺឆ្លងផ្សេងទៀតក៏ដោយ ការបង្ការនូវការនាំចូល និងការរាលដាលនៃ ASFV តាមខ្សែសង្វាក់តម្លៃសាច់ជ្រូក តម្រូវឱ្យមានវិធានការជីវសុវត្ថិភាពដ៏រឹងមាំបន្ថែមទៀត (FAO, 2010)។ វិធានការទាំងនេះគួរតែអាចធ្វើទៅបាន សមស្របតាមថ្លៃចំណាយ និងអាចអនុវត្តបាន សម្រាប់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ និងតួអង្គពាក់ព័ន្ធនានានៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក (FAO, 2010)។

វិធានការល្អលើផ្នែកជីវសុវត្ថិភាព ត្រូវបានបង្កើតឡើងដោយផ្អែកលើចំណេះដឹងអំពីការរាតត្បាតនៃជំងឺ (Bellini et al., 2016)។ វិធានការទាំងនេះរួមមាន លក្ខណៈជីវសាស្ត្រនៃភ្នាក់ងារបង្ករោគ លក្ខខណ្ឌបរិស្ថានដែលភ្នាក់ងារបង្ករោគអាចនៅមានសកម្មភាព របៀបឆ្លង និងរយៈពេលសម្ងំនៃមេរោគ (Bellini et al., 2016; FAO, 2010)។ គោលការណ៍ជីវសុវត្ថិភាពទូទៅអាចអនុវត្តបានចំពោះគ្រប់ប្រព័ន្ធចិញ្ចឹមសត្វ និងជំងឺទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យមានប្រសិទ្ធភាពសម្រាប់ការបង្ការ និងត្រួតពិនិត្យ វិធានការជីវសុវត្ថិភាពជាក់ស្តែងត្រូវផ្តោតឱ្យចំគោលដៅ ដោយពិចារណាអំពីជំងឺ ប្រភេទសត្វ និងប្រព័ន្ធនៃការចិញ្ចឹមដែលពាក់ព័ន្ធ (Bellini et al., 2016; FAO, 2010)។ ការអនុវត្តវិធានការជីវសុវត្ថិភាពនៅក្នុង ផលិតកម្មលក្ខណៈគ្រួសារ ជួបការលំបាកដោយឡែក។ ជាទូទៅ ការអនុវត្តបានល្អនូវវិធានការជីវសុវត្ថិភាពភាគច្រើនស្ថិតក្រោម ឥទ្ធិពលនៃលក្ខខណ្ឌសង្គម-វប្បធម៌នៃក្រុមមនុស្សគោលដៅនីមួយៗ។

ចាប់តាំងពីឆ្នាំ ២០០៩ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) បានគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំជីវសុវត្ថិភាពជាក់លាក់សម្រាប់ការចិញ្ចឹមជ្រូក ដើម្បីជួយគ្រប់គ្រងជំងឺឆ្លងជ្រូកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ គោលការណ៍ណែនាំទាំងនេះ រួមមានការអនុវត្តល្អសម្រាប់ជីវសុវត្ថិភាពក្នុងការចិញ្ចឹមជ្រូក ដែលចេញផ្សាយដោយ FAO អង្គការសុខភាពសត្វពិភពលោក (OIE) និងធនាគារពិភពលោក និងឯកសារចំនួនបីភាគ ស្តីពីការគ្រប់គ្រងសុខភាពជ្រូក ដែល បានចេញផ្សាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងជំងឺជ្រូកក្នុងការចិញ្ចឹមលក្ខណៈគ្រួសារ នៅអាស៊ី (FAO, 2012)។ ការចេញផ្សាយនេះ ធ្វើឡើងស្របតាមអាណត្តិរបស់ FAO ក្នុងការធានាផលិតភាពកសិកម្ម សន្តិសុខស្បៀង និងការធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចនិងជីវភាពរស់នៅក្នុងមូលដ្ឋាន។ ប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារសម្រាប់ការផ្គត់ផ្គង់ក្នុងគ្រួសារ មានសារៈសំខាន់ចំពោះអត្តសញ្ញាណសង្គម-វប្បធម៌នៅអាស៊ីអាគ្នេយ៍ (FAO, 2012, 2020)។ ដូច្នេះផលប៉ះពាល់នៃមេរោគ ASFV មកលើចំនួនជ្រូកក្នុងតំបន់នេះ

មានទំហំធំធេងណាស់ ជាពិសេស វាបង្កផលវិបាកជាសកល និងទូលំទូលាយចំពោះសន្តិសុខស្បៀង (FAO, 2020)។ វត្តមានយ៉ាងច្រើននៃប្រព័ន្ធចិញ្ចឹមសត្វលក្ខណៈគ្រួសារក្នុងតំបន់នេះ ដែលជារឿយៗអាចគ្មាន ឬមានជីវសុវត្ថិភាពក្នុងកម្រិតអប្បបរមា នាំឱ្យមានការរាលដាលនៃ ASFV ឆាប់រហ័ស។ ដូច្នេះ កិច្ចប្រឹងប្រែងទប់ស្កាត់ និងត្រួតពិនិត្យនៅក្នុងប្រព័ន្ធចិញ្ចឹមលក្ខណៈគ្រួសារ ដែលជាកម្មវត្ថុនៃការអនុវត្តវិធានការជីវសុវត្ថិភាពដែលជាក់លាក់សម្រាប់ ASF គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុត (FAO, 2012)។

## ១.១ និយមន័យជីវសុវត្ថិភាព

ជីវសុវត្ថិភាព សំដៅលើបណ្តុំនៃវិធានការគ្រប់គ្រង និងវិធានការអនុវត្តផ្សេងៗ ដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យនៃចម្លងជំងឺ ការកកើតជំងឺ និងការរីករាលដាលនៃជំងឺសត្វ ការឆ្លងមេរោគ ឬការបំបែកខ្លួនរបស់មេរោគ ក្នុងហ្វូងសត្វមួយ ឬពីហ្វូងសត្វមួយទៅហ្វូងសត្វមួយទៀត (OIE, 2019c)។ នៅកម្រិតផលិតកម្មជ្រូកលក្ខណៈគ្រួសារ គោលគំនិតនៃជីវសុវត្ថិភាព ត្រូវបានចាត់ទុកថា រាល់ការអនុវត្តនានាដែលការពារការចិញ្ចឹមសត្វរបស់កសិករដោយទប់ស្កាត់ជំងឺឆ្លងនៅក្នុងហ្វូងជ្រូករបស់ពួកគាត់។ ជីវសុវត្ថិភាពជាមូលដ្ឋាន មានសារៈសំខាន់ជាចាំបាច់ សម្រាប់ផលិតកម្មសត្វប្រកបដោយនិរន្តរភាព និងសន្តិសុខស្បៀង។ តាមរយៈការអនុវត្តល្អនូវវិធានការជីវសុវត្ថិភាពជាប្រចាំ អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ អាចទ្រទ្រង់ខ្សែសង្វាក់ទីផ្សាររបស់ខ្លួន នឹងរួមចំណែកចំពោះយុទ្ធសាស្ត្រជាតិគ្រប់គ្រង ASF ផងដែរ (Deka et al., 2014; FAO, 2010)។

ជីវសុវត្ថិភាព ពាក់ព័ន្ធនឹងការសម្រេចចិត្តជាយុទ្ធសាស្ត្រ ការវិនិយោគ ការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍ និងបុគ្គលិក (USDA & CFSPH, 2016)។ វាទាមទារឱ្យមានការត្រួតពិនិត្យពីមន្ត្រីបសុពេទ្យដើម្បីពង្រឹងការអនុវត្ត ការបណ្តុះបណ្តាល និងការលើកទឹកចិត្តដល់កសិករ និងអ្នកពាក់ព័ន្ធ។ យោងតាមក្រមសុខភាពសត្វលើគោក ដើម្បីឱ្យវិធានការជីវសុវត្ថិភាពមានប្រសិទ្ធភាព និងមានសមត្ថភាពការពារហ្វូងសត្វពីជំងឺឆ្លងនានា គេត្រូវមានផែនការយុទ្ធសាស្ត្រ (OIE, 2019c)។ ផែនការនេះត្រូវផ្តល់ដំណោះស្រាយ សម្រាប់គ្រប់គ្រងផ្លូវចូលដែលមានហានិភ័យខ្ពស់ អាកប្បកិរិយា ការអនុវត្ត និងឥរិយាបថ ដែលផ្តល់ភាពងាយស្រួលដល់ការនាំចូល ការលួតលាស់ និងការរាតត្បាតជំងឺ (Bellini et al., 2016; Jurado et al., 2018)។

ការត្រួតពិនិត្យ ASF នៅតែមានបញ្ហា ជាពិសេស ក្នុងប្រទេសដែលបណ្តាញពាណិជ្ជកម្មផ្ទៃក្នុងមានលក្ខណៈស្មុគស្មាញ (Bellini et al., 2016)។ លើសពីនេះ ភាពខ្វះចន្លោះនៅតាមព្រំប្រទល់ដីគោក អនុញ្ញាតឱ្យមានការដឹកជញ្ជូនជ្រូក និងផលិតផលជ្រូកឆ្លងដែនដោយល្មើសច្បាប់ (Deka et al., 2014)។

ឯកសារនេះបង្ហាញពីវិធានការជីវសុវត្ថិភាព ដែលអាចអនុវត្តបានក្នុងផលិតកម្មជ្រូកលក្ខណៈគ្រួសារ ដើម្បីកាត់បន្ថយការរាលដាលនៃ ASFV នៅទូទាំងអាស៊ីអាគ្នេយ៍។ វិធានការទាំងនេះមានបំណងរារាំង ASFV ពីកសិដ្ឋាន ទប់ស្កាត់មេរោគពីការចរាចរនៅក្នុងកសិដ្ឋាន និងនៅទីបំផុត បង្ការការរាលដាលនៃមេរោគទៅប្រទេសជិតខាង ប្រសិនបើមានវត្តមាន។ ធាតុផ្សំគ្រួតគ្នាចំនួនបីនៃជីវសុវត្ថិភាព៖ ការបង្ខាំងជីវសាស្ត្រ ការគ្រប់គ្រងជីវសាស្ត្រ និងការហ៊ុមព័ទ្ធជីវសាស្ត្រ គឺជាគោលការណ៍ចម្បងដែលគួសបញ្ជាក់ពីវិធានការដែលបានស្នើឡើងនៅក្នុងគោលការណ៍ណែនាំទាំងនេះ។ អនុសាសន៍ជាក់ស្តែងដែលសម្របតាមភាពចាំបាច់នៃផលិតកម្មជ្រូកលក្ខណៈគ្រួសារត្រូវបានរៀបរាប់ខាងក្រោម។

## ការបង្ខាំងជីវសាស្ត្រ

ការដាក់នៅដាច់ដោយឡែក ទាក់ទងជាមួយវិធានការជាក់ស្តែងដែលធ្វើឡើងដើម្បីទប់ស្កាត់ការបញ្ចូល ASFV ទៅក្នុង កសិដ្ឋានចិញ្ចឹមជ្រូក (Levis & Baker, 2011)។ សម្រាប់អ្នកចិញ្ចឹមសត្វភាគច្រើន ការដាក់នៅដាច់ដោយឡែក ផ្តោតជាសំខាន់ នៅពេលអនុវត្តវិធានការជីវសុវត្ថិភាព។ វិធានការទាំងនេះ ផ្អែកលើផ្លូវចំលងរបស់មេរោគ។ ទោះបីផ្លូវមួយចំនួនមានលក្ខណៈរួមរវាងភ្នាក់ងារបង្កជំងឺនានាក៏ដោយ ផ្លូវចំលងខ្លះមានភាពជាក់លាក់ចំពោះ ASFV។ ដូច្នេះ ការដាក់នៅដាច់ដោយឡែក អាចមានលក្ខណៈឯកទេសជាង ដោយកំណត់អត្តសញ្ញាណផ្លូវចំលងជាក់លាក់នៃ ASFV។ ឯកសារនេះផ្តល់អនុសាសន៍អំពីការដាក់នៅដាច់ដោយឡែកជាក់ស្តែង ដែលអនុវត្តចំពោះ ASFV ។ ការធ្វើបែបនេះអនុញ្ញាតឱ្យពួកគេកំណត់ផ្លូវចំលងមេរោគដែលមានសក្តានុពលសម្រាប់ជំងឺ និងវិធានការកាត់បន្ថយសមស្រប។ ការធ្វើរបងព័ទ្ធសមស្រប ការប្រើប្រាស់អាងទឹកថ្នាំលាងជើង ការគ្រប់គ្រងបុគ្គលិក និងដាក់ជ្រូកនាំចូលថ្មីនៅដាច់ដោយឡែក គឺជាឧទាហរណ៍ពីទម្រង់ធម្មតានៃការបង្ខាំងជីវសាស្ត្រ(Levis & Baker, 2011)។

## ការគ្រប់គ្រងជីវសាស្ត្រ

ធាតុផ្សំនៃការគ្រប់គ្រងជីវសាស្ត្រនៃជីវសុវត្ថិភាពទាក់ទងនឹងការគ្រប់គ្រងកន្លែងដែលស្ថិតនៅជាប់នឹងកសិដ្ឋានដើម្បីទប់ស្កាត់ការបង្កើតភ្នាក់ងារបង្ករោគឬដើម្បីរក្សាលក្ខខណ្ឌអនាម័យនៃបរិវេណជិតៗកសិដ្ឋាន (Levis & Baker, 2011)។ វិធានការនេះអាចចាត់ជាជីវសុវត្ថិភាពផ្ទៃក្នុងរបស់កសិដ្ឋាន។ ការគ្រប់គ្រងជីវសាស្ត្រ ផ្សំឡើងពីវិធានការជាច្រើន ដូចជាការសម្អាត និងការរំងាប់មេរោគ ការកំណត់តំបន់ស្អាតនិងកខ្វក់ និងការគ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវ ដែលអាចត្រូវបានអនុវត្តរួមគ្នា ឬដោយឡែកពីគ្នា (Levis & Baker, 2011)។

## ការហ៊ុមព័ទ្ធជីវសាស្ត្រ

ការហ៊ុមព័ទ្ធជីវសាស្ត្រ ដែលច្រើនត្រូវបានមើលរម្លងបំផុតក្នុងចំណោមកត្តាជីវសុវត្ថិភាព ជួយទប់ស្កាត់ការរាលដាលនៃភ្នាក់ងារបង្កជំងឺទៅកសិដ្ឋាននៅជិតខាង។ ការអនុវត្តវិធានការហ៊ុមព័ទ្ធជីវសាស្ត្រ នឹងកំហិតលើការរាលដាលនៃជំងឺទៅកសិដ្ឋានផ្សេងទៀតនៅក្នុងមូលដ្ឋាន (Levis & Baker, 2011)។ នៅក្នុងកន្លែងផលិតជ្រូកលក្ខណៈគ្រួសារ ដូចជា ភូមិមួយ ការហ៊ុមព័ទ្ធជីវសាស្ត្រ គឺជាការអនុវត្តដ៏សំខាន់មួយ ដែលផ្តល់អត្ថប្រយោជន៍ដល់កសិករទាំងអស់។ វិធានការដែលប្រើដើម្បីហ៊ុមព័ទ្ធជីវសាស្ត្រនៅក្នុងកសិដ្ឋានលក្ខណៈគ្រួសារណាមួយ រួមមានការព័ទ្ធរបង និងការដឹកជញ្ជូនជ្រូកដោយសុវត្ថិភាព ពីកន្លែងមួយទៅកន្លែងមួយទៀត (Levis & Baker, 2011)។



© FAO/D. Caro

# ២ តួនាទី និងការទទួលខុសត្រូវនៃអ្នកពាក់ព័ន្ធលើជីវសុវត្ថិភាព ASF ក្នុងការចិញ្ចឹមជ្រូកនៅអាស៊ីអាគ្នេយ៍

ជីវសុវត្ថិភាពដែលមានប្រសិទ្ធភាព ឆ្ពោះទៅរកការទប់ស្កាត់ និងត្រួតពិនិត្យ ASF នៅកម្រិតកសិដ្ឋានលក្ខណៈគ្រួសារ តម្រូវឱ្យមានកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងតួអង្គទាំងអស់នៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក និងមន្ត្រីបសុពេទ្យ (FAO, 2017)។ ការចុះឈ្មោះអ្នកចិញ្ចឹមជ្រូកនៅក្នុងកម្មវិធីជាតិជីវសុវត្ថិភាព ASF នឹងរួមចំណែកឆ្ពោះទៅទប់ស្កាត់ និងត្រួតពិនិត្យជំងឺ ទាំងនៅកម្រិតជាតិ និងអន្តរជាតិ។ កសិករគួរតែចុះឈ្មោះក្នុងកម្មវិធីជីវសុវត្ថិភាពតាមសហគមន៍ និង/ឬប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតផងដែរ។ ការធ្វើបែបនេះអាចឱ្យកសិករចិញ្ចឹមសត្វទទួលបានអត្ថប្រយោជន៍ពីការកែលំអផលិតកម្មជ្រូក និងឱកាសពាណិជ្ជកម្ម ដែលភាគច្រើនមាននៅតាមមូលដ្ឋាន (Deka et al., 2014)។

ការអនុវត្តវិធានការជីវសុវត្ថិភាពដែលសមស្របសម្រាប់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ គឺជាដំណើរការអប់រំដ៏ស្មុគស្មាញដែលធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ដែលនឹងកាត់បន្ថយហានិភ័យ ASF (Deka et al., 2014; FAO, 2010)។ ការអនុវត្តវិធានការជីវសុវត្ថិភាព ត្រូវតែស្របជាមួយគ្នា និងការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងអស់ពោលគឺ អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ មន្ត្រីបសុពេទ្យ សមាគមអ្នកចិញ្ចឹមសត្វ និងតួអង្គនៃទីផ្សារ នៅក្នុងខ្សែសង្វាក់តម្លៃជ្រូកចិញ្ចឹមលក្ខណៈគ្រួសារ។ ការអនុវត្តវិធានការជីវសុវត្ថិភាព ត្រូវតែបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់អំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យក្នុងរយៈពេលខ្លី ដែលបង្កើនចំណាប់អារម្មណ៍របស់ពួកគាត់លើការអនុវត្ត ទន្ទឹមនឹងការលើកទឹកចិត្តដល់ការវិនិយោគនានាផងដែរ (FAO, 2010)។

## ២.១ មន្ត្រីបសុពេទ្យថ្នាក់ជាតិ/ថ្នាក់កណ្តាល

តួនាទីរបស់មន្ត្រីបសុពេទ្យនៅថ្នាក់ជាតិ/ថ្នាក់កណ្តាល(មន្ត្រីបសុពេទ្យ) គឺបង្កើត រក្សា និងពង្រឹងការអនុវត្តវិធានការជីវសុវត្ថិភាពជាក់ស្តែង ក្នុងភាពជាដៃគូជាមួយអ្នកអនុវត្ត និងតួអង្គសំខាន់ៗ ក្នុងខ្សែសង្វាក់តម្លៃជ្រូកនៅតាមកសិដ្ឋាន ការវិនិយោគក្នុងតំបន់ និងនៅថ្នាក់ជាតិ ( FAO, 2010)។

### តួនាទីរបស់មន្ត្រីបសុពេទ្យនៅកម្រិតផលិតកម្មជ្រូកលក្ខណៈគ្រួសារ

តួនាទីជាក់លាក់របស់មន្ត្រីបសុពេទ្យនៅកម្រិតផលិតកម្មជ្រូកលក្ខណៈគ្រួសារ មានជាអាទិ៍ (OIE, 2017)៖

១ ការទទួលខុសត្រូវក្នុងការបង្កើតកម្មវិធីជីវសុវត្ថិភាព ជាមួយវិធានការគ្រប់គ្រងហានិភ័យច្បាស់លាស់ និងសាមញ្ញ។ កម្មវិធីទាំងនេះ ត្រូវផ្តល់អត្ថប្រយោជន៍ភ្លាមៗ និងជាបន្តបន្ទាប់។

២ បង្កើតសារផ្សព្វផ្សាយអំពីវិធានសំខាន់ៗនៃជីវសុវត្ថិភាព ដូចជា អនាម័យកសិដ្ឋានជាប្រចាំ ការធ្វើចត្តាឡីស័ក សម្រាប់ជ្រូកដែលបញ្ចូលមកថ្មី ការដាក់សត្វឈឺឱ្យនៅដាច់ដោយឡែក ការគ្រប់គ្រងហានិភ័យនៃអាហារជាសំណល់ពីផ្ទះបាយដល់ជ្រូក និងការលើកកម្ពស់សារៈសំខាន់នៃការរក្សាកំណត់ត្រាត្រឹមត្រូវអំពីបញ្ហាសុខភាពសត្វ។

៣ ការទទួលខុសត្រូវក្នុងការលើកទឹកចិត្តឱ្យមានកិច្ចសហការក្នុងមូលដ្ឋាន រវាងបសុពេទ្យរបស់រដ្ឋាភិបាល មន្ត្រីតាមមូលដ្ឋាន កសិករ និងសមាគមអ្នកចិញ្ចឹម។ កិច្ចការនេះគួរតែផ្តល់មាគ៌ាសម្រាប់អ្នកពាក់ព័ន្ធ ដើម្បីកសាងសមត្ថភាពអនុវត្តជីវសុវត្ថិភាពដែលអាចទទួលយកបាន ក្នុងចំណោមអ្នកចិញ្ចឹមលក្ខណៈគ្រួសារ។ កិច្ចការនេះមានជាអាទិ៍ ការបណ្តុះបណ្តាលគ្រូបង្គោល ដែលនឹងផ្ទេរចំណេះដឹង ទៅអ្នកអនុវត្តវិធានការជីវសុវត្ថិភាពបឋម។

៤ ការវាយតម្លៃ និងការចែករំលែកមេរៀនដែលទទួលបាន ដែលទាក់ទងនឹងការអនុវត្តល្អខាងជីវសុវត្ថិភាពក្នុងកសិដ្ឋាននៅទូទាំងប្រទេស ដែលរួមទាំង អត្ថប្រយោជន៍ពីការសហការរបស់ភាគីពាក់ព័ន្ធផងដែរ។

៥ ការទទួលខុសត្រូវលើវិធានការត្រួតពិនិត្យ បន្ទាប់ពីមានការផ្ទុះ ASFV។ មន្ត្រីបសុពេទ្យត្រូវកំណត់តំបន់ និងបរិវេណដែលមានមេរោគ តំបន់ដែលមានការប៉ះពាល់ដ៏គ្រោះថ្នាក់ ឬតំបន់គ្មានមេរោគ និងធានាឱ្យមានការពង្រឹងការអនុវត្តស្តង់ដារអនាម័យ ។

## ២.២ សមាគមអ្នកចិញ្ចឹមជ្រូក និងអង្គការក្រៅរដ្ឋាភិបាល

តាមធម្មតា អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ មិនមែនជាសមាជិកនៃសមាគមអ្នកចិញ្ចឹមជ្រូក ឬគម្រោងធានាគុណភាពឡើយ ហើយភាគច្រើនពុំមែនជាអ្នកចិញ្ចឹមសត្វជំនាញឡើយ (Correia-Gomes et al., 2017)។ ស្ថានភាពនេះនាំឱ្យពួកគេមានចំណេះដឹង និងការយល់ដឹងក្នុងកម្រិតកំណត់ អំពីច្បាប់ និងលក្ខខណ្ឌតម្រូវ ដែលដាក់ចេញដោយមន្ត្រីបសុពេទ្យ។ អវត្តមានកាតព្វកិច្ចតឹងរ៉ឹងក្នុងការធានាគុណភាពនៅកម្រិតនេះ មានន័យថាកសិករមួយចំនួនពុំជឿជាក់លើសារៈសំខាន់នៃការអនុវត្តវិធានការជីវសុវត្ថិភាព និងការគ្រប់គ្រងឡើយ (Correia-Gomes

et al., 2017)។ ដើម្បីបង្កើនការទទួលយកវិធានការជីវសុវត្ថិភាព អង្គការក្រៅរដ្ឋាភិបាលអាចរៀបចំវគ្គបណ្តុះបណ្តាលដល់កសិករ អំពីវិធានការជីវសុវត្ថិភាព ដែលស្នើឡើងដោយមន្ត្រីបសុពេទ្យ។ កសិករក៏ត្រូវតែបានទទួលការលើកទឹកចិត្ត ឱ្យចូលរួមជាមួយសមាគមអ្នកចិញ្ចឹមសត្វក្នុងមូលដ្ឋាន ឬប្រព័ន្ធខ្សែសង្វាក់ស្អាត ដែលមាននាទីជាប្រព័ន្ធគាំទ្រអ្នករួមអាជីព ដែលមានឥទ្ធិពលលើកសិករ ក្នុងការអនុវត្តវិធានការជីវសុវត្ថិភាពសមស្របផងដែរ។

## ២.៣ មន្ត្រីបសុពេទ្យ និងមន្ត្រីតាមមូលដ្ឋាន

មន្ត្រីបសុពេទ្យរបស់រដ្ឋាភិបាល ឬមន្ត្រីតាមមូលដ្ឋាន (ឬមន្ត្រីថ្នាក់ខេត្ត ឬអ្នកបច្ចេកទេស) តំណាងឱ្យមន្ត្រីបសុពេទ្យនៅថ្នាក់មូលដ្ឋាន នឹងជួយកសិករលើការអនុវត្តវិធានការជីវសុវត្ថិភាព (OIE, 2017)។ អ្នកទាំងនេះផ្តល់យោបល់ជំនាញអំពីហានិភ័យនៃ ASFV ដល់កសិដ្ឋានក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន ដោយផ្អែកលើការវាយតម្លៃទីតាំងកសិដ្ឋាន ការប្រឈមនឹងកត្តាហានិភ័យ និងការគ្រប់គ្រងសុខភាពនៃហ្វូងជ្រូក។ អ្នកទាំងនេះក៏ណែនាំកសិករអំពីវិធានការល្អសម្រាប់ការអនុវត្តផងដែរដូចជា ការសម្អាត និងការរំងាប់មេរោគ ដើម្បីជួយគ្រប់គ្រងហានិភ័យ និងជួយការពារការវិនិយោគរបស់កសិករ។

បសុពេទ្យមួយចំនួន ជាពិសេស ប្រតិបត្តិករឯកជន ឬបុគ្គលិកផ្សព្វផ្សាយ តំណាងឱ្យសមាគមអ្នកចិញ្ចឹមសត្វ ដើម្បីធ្វើឱ្យមានការអនុវត្តគម្រោងជានាគុណភាពនៅនឹងកន្លែង។ ក្នុងករណីបែបនេះ បសុពេទ្យ និងអ្នកជំនាញនៅមូលដ្ឋាន អាចធ្វើការដោយផ្ទាល់ជាមួយមន្ត្រីបសុពេទ្យ ដើម្បីធានាថា កសិករបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ និងមានការកាត់បន្ថយហានិភ័យនៃការចម្លង ASFV រវាងកសិដ្ឋាន។ ដោយសារនៅក្នុងប្រទេសខ្លះនៅអាស៊ីអាគ្នេយ៍ អាចពុំមានមន្ត្រីបសុពេទ្យគ្រប់គ្រាន់ មន្ត្រីបសុពេទ្យ អាចធ្វើទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយបណ្តុះបណ្តាលកសិករក្នុងមូលដ្ឋានអំពីប្រតិបត្តិការដោយនិរន្តរភាពនៃការអនុវត្តល្អលើផ្នែកជីវសុវត្ថិភាពនៅកម្រិតនៃការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ។

## ២.៤ អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ (កសិករ)

កសិករនៅកម្រិតផលិតកម្មលក្ខណៈគ្រួសារ គឺជាចំណុចស្នូលនៃកិច្ចសហការរវាងមន្ត្រីបសុពេទ្យ សមាគមអ្នកចិញ្ចឹមសត្វបសុពេទ្យ និងអ្នកជំនាញក្នុងមូលដ្ឋាន។ ពួកគាត់មានការទទួលខុសត្រូវចម្បងក្នុងកិច្ចការពារជ្រូករបស់ខ្លួនពី ASFV ហើយជាទូទៅ គឺជាបុគ្គលិកជីវសុវត្ថិភាពចម្បងសម្រាប់កសិដ្ឋានរបស់ខ្លួន។ កសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ចង់ឱ្យការចិញ្ចឹមរបស់ខ្លួន មានសុវត្ថិភាពពីហានិភ័យនៃ ASFV ដោយអនុវត្តគោលការណ៍ណែនាំជីវសុវត្ថិភាពជាក់លាក់ចំពោះ ASFV ដែលកំណត់ដោយមន្ត្រីបសុពេទ្យ។ កសិករត្រូវធានាថាពួកគាត់ ទទួលបានការបណ្តុះបណ្តាលជាប្រចាំ អំពីវិធានការជីវសុវត្ថិភាពជាក់ស្តែង។

វិធានការជីវសុវត្ថិភាពជាក់ស្តែងនៅកម្រិតអ្នកចិញ្ចឹមលក្ខណៈគ្រួសារ ត្រូវពិចារណាពីលក្ខណៈនៃប្រព័ន្ធផលិតកម្ម អាកប្បកិរិយារបស់កសិករក្នុងមូលដ្ឋាន ថ្លៃដើម និងនៅទីបំផុត ភាពងាយស្រួលនៃការអនុវត្តដើម្បីឱ្យមានប្រសិទ្ធភាព (FAO, 2010)។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងព្រឹត្តិការណ៍នៃការផ្ទុះជំងឺ ASF មន្ត្រីបសុពេទ្យ ត្រូវមានវិធានការកាន់តែខ្លាំងក្លា ដើម្បីធានាឱ្យមានការត្រួតពិនិត្យសមស្រប។ តាមរយៈការទទួលយក និងអនុវត្តកម្មវិធីជីវសុវត្ថិភាព កសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសាររួមចំណែកក្នុងការត្រួតពិនិត្យជំងឺ ASFV និងជំងឺជ្រូកឆ្លងផ្សេងទៀតនៅថ្នាក់ជាតិ ដែលជាការរួមចំណែកដល់ផលិតភាព និងស្ថិរភាពសេដ្ឋកិច្ចផងដែរ។

## ២.៥ អ្នកជំនាញនៅមូលដ្ឋាន (បុគ្គលិកពេទ្យសត្វភូមិ ឬ អ្នកស្ម័គ្រចិត្តសុខភាពសត្វសហគមន៍)

អ្នកជំនាញក្នុងមូលដ្ឋាន ដែលត្រូវបានគេស្គាល់ជាទូទៅថាជា បុគ្គលិកពេទ្យសត្វតាមភូមិ ឬអ្នកស្ម័គ្រចិត្តសុខភាពសត្វសហគមន៍ក្នុងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួន បានទទួលការបណ្តុះបណ្តាល លើការផ្សព្វផ្សាយអំពីសុខភាពសត្វដល់កសិករលក្ខណៈគ្រួសារ។ ពួកគាត់គឺជាប្រតិបត្តិករឯកជន ដែលឆ្លើយតបនឹងតម្រូវការចាំបាច់របស់អ្នកផលិតលក្ខណៈគ្រួសារ មិនថានៅក្នុងការផ្តល់ឱសថ ឬវីតាមីន ការផ្តល់ដំបូន្មាន និងសូម្បីតែរាយការណ៍ពីការរកឃើញបញ្ហាសុខភាពសត្វទៅមន្ត្រីបសុពេទ្យផងដែរ។ អ្នកជំនាញក្នុងមូលដ្ឋានចុះតាមគ្រួសារមួយចំនួននៅក្នុងភូមិមួយក្នុងថ្ងៃណាមួយ ដើម្បីរកប្រាក់ចំណូលបានគ្រប់គ្រាន់ពីសេវាកម្មដែលគេផ្តល់ឱ្យកសិករ។ ក្នុងករណីមានជំងឺ ASF ការចុះតាមគ្រួសារត្រូវបានកំហិតត្រឹមអំឡុងពេលដែលខ្លួនទំនេរ (សម្រាក ៤៨ម៉ោង) ដោយគោរពតាមវិធានការជីវសុវត្ថិភាពត្រឹមត្រូវ នៅក្នុងពេលចុះពិនិត្យតាមគ្រួសារ ដើម្បីបញ្ចៀសការរាលដាលជំងឺទៅកសិដ្ឋានផ្សេងទៀត។



© FAO/B. Simon

# ៣ លក្ខខណ្ឌអប្បបរមានៃជីវសុវត្ថិភាព ASF សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ

ផែនការជីវសុវត្ថិភាពដែលជាក់លាក់ចំពោះ ASFV សម្រាប់ចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ រួមមាន ការបង្ការជីវសាស្ត្រ ការហ៊ុមព័ទ្ធជីវសាស្ត្រ និងវិធានការគ្រប់គ្រងជីវសាស្ត្រឱ្យបានសមស្រប (Delsart et al., 2020)។ វិធានការដែលបានរៀបរាប់ខាងក្រោម គឺជាការណែនាំចំបងអំពីជីវសុវត្ថិភាពសម្រាប់កសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ វិធានការនេះមិនពេញលេញទេ ដោយសារជីវសុវត្ថិភាពពុំមាន "ដំណោះស្រាយទូទៅមួយសម្រាប់គ្រប់ករណី"ឡើយ។ ទីតាំង បរិវេណ និងអាកប្បកិរិយា អាចខុសគ្នារវាងកសិដ្ឋានលក្ខណៈគ្រួសារនានា។ អាស្រ័យហេតុនេះ គេចាំបាច់ត្រូវកែសម្រួលអនុសាសន៍ទាំងនេះ និងអនុសាសន៍ផ្សេងទៀត ឱ្យស្របនឹងលក្ខខណ្ឌជាក់លាក់នៃកសិដ្ឋាននីមួយៗ ដោយគិតគូរពីហានិភ័យ ASF ដែលកំពុងកើតមាន។ ប្រភព ASFV ដែលអាចគំរាមកំហែងដល់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ មានបង្ហាញដូចខាងក្រោម៖

កន្លែងដែលអាចជាប្រភពជំងឺ ASF ដែលអាចគំរាមកំហែងដល់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ។

- ចំណីកាកសំណល់ផ្ទះបាយ
- កសិករ
- យានយន្ត
- សាកសពសត្វដែលបោល
- ទឹក
- សម្ភារៈផ្គត់ផ្គង់ដល់កសិដ្ឋាន
- សត្វកកេរ/សត្វស្លាប/ចៃ/រុយ
- ទឹកមេជីវិតសត្វឈ្មោល
- ចំណីសត្វ
- សត្វចូលថ្មី
- ខ្យល់
- បរិក្ខារ
- សត្វចេញក្រៅ

## ៣.១ ការនាំចូលជ្រូកថ្មីទៅក្នុងហ្វូងណាមួយ

- កសិករគួរតែទទួលបានជ្រូកថ្មីយ៉ាងច្រើនតាមតែអាចធ្វើទៅបាន ពីប្រភពដែលអាចទុកចិត្តបានថាគ្មាន ASF (Bellini et al., 2016; Jurado et al., 2018; SPS, 2019)។ មន្ត្រីបសុពេទ្យគួរតែអាចផ្តល់បញ្ជីឈ្មោះក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់ជ្រូកដែលគ្មានមេរោគ ASF ដែលកំពុងដំណើរការល្អ។
- ត្រូវធានាឱ្យមានវិធានការជីវសុវត្ថិភាពល្អនៅមុន ក្នុងអំឡុងពេល និងក្រោយពេលដឹកជញ្ជូនពីអ្នកផ្គត់ផ្គង់ទៅកសិករ។ ត្រូវលាងសម្អាត និងរំងាប់មេរោគលើយានយន្ត ម៉ូតូ និងទ្រុងជ្រូកឱ្យបានហ្មត់ចត់ (SPS, 2019)។
- ប្រសិនបើមានទីធ្លាធំ កសិករលក្ខណៈគ្រួសារគួរតែកំណត់កន្លែងមួយនៅឆ្ងាយពីកន្លែងស្តុកជ្រូក សម្រាប់ការផ្ទេរទំនិញ។ ប្រសិនបើគ្មានទីធ្លាធំទេនោះ គួរសម្អាតយានយន្តដឹកជញ្ជូន និងជ្រូក មុនពេលអនុញ្ញាតឱ្យចូលក្នុងទីធ្លានៃទ្រុងដែលបានកំណត់។
- ត្រូវដាក់ជ្រូកដែលទើបមកដល់ថ្មី ក្នុងទ្រុងមួយ ឬទីកន្លែងមួយដាច់ដោយឡែក ក្នុងកសិដ្ឋាន ឬបរិវេណនៃផ្ទះ និងធ្វើការសង្កេតសញ្ញាជំងឺក្នុងរយៈពេល ១៤-៣០ថ្ងៃ (DEFRA, 2020; SPS, 2019)។ ការអនុវត្តល្អក្នុងការគ្រប់គ្រងសុខភាព មានជាអាទិ៍ ការរក្សាកំណត់ត្រាប្រចាំថ្ងៃអំពីជ្រូកឈឺ និងស្លាប់។ ក្រោយពេលកសិករពេញចិត្តចំពោះស្ថានភាពសុខភាពរបស់ជ្រូកទើបមកដល់ថ្មី ពួកគេអាចបញ្ចូលជ្រូកថ្មីៗទាំងនោះទៅក្នុងហ្វូងធំបាន (Levis & Baker, 2011)។
- ជាការល្អ មិនគួរបញ្ចូលជ្រូកថ្មីបន្ថែម លើជ្រូកដែលទើបនាំចូលនោះទេ រហូតរយៈពេលចត្តាឡីស័កបានកន្លងផុត។
- ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លង ASFV ទៅក្នុងហ្វូងជ្រូក កសិករលក្ខណៈគ្រួសារគួរតែកំហិតភាពញឹកញាប់នៃការនាំចូលជ្រូកថ្មីទៅក្នុងហ្វូងដែលមានស្រាប់ (SPS, 2019)។ បើអាចធ្វើបាន កសិករអាចរៀបចំរចនាសម្ព័ន្ធកសិដ្ឋានរបស់ខ្លួន និងផែនការសម្រាប់ការនាំចូលសត្វថ្មី ការចិញ្ចឹម និងលក់ចេញ ជាវគ្គដាច់ពីគ្នា។
- មិនគួរប្រើប្រាស់ជ្រូកបារ្សមគ្នាឡើយ លើកលែងតែនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត។ ក្នុងប្រព័ន្ធបែបនេះ វិធានការសម្រាប់ការបញ្ចូលជ្រូកថ្មីទៅក្នុងហ្វូងណាមួយ គួរត្រូវបានអនុវត្តនៅក្នុងគ្រប់ដំណាក់កាលនៃការចរាចរណ៍ជ្រូកបារ្សម។

**ចំណុចគន្លឹះ**

គួរដាក់ជ្រូកមកដល់ថ្មីឱ្យនៅដាច់ពីគេក្នុងទ្រុងផ្សេង និងសង្កេតមើលរោគសញ្ញាជំងឺក្នុងរយៈពេល១៤-៣០ថ្ងៃ។ ការអនុវត្តល្អក្នុងការគ្រប់គ្រងសុខភាព មានជាអាទិ៍ ការរក្សាកំណត់ត្រាប្រចាំថ្ងៃអំពីជ្រូកឈឺ និងស្លាប់។ បន្ទាប់ពីពេញចិត្តចំពោះស្ថានភាពសុខភាពជ្រូកមកដល់ថ្មី កសិករអាចបញ្ចូលជ្រូកថ្មីៗទាំងនោះទៅក្នុងហ្វូងធំបាន។

## ៣.២ ចំណី និងទឹក

- វត្ថុធាតុដើមនៃចំណីអាចឆ្លងមេរោគយ៉ាងងាយ ប្រសិនបើមិនបានរក្សាទុកឱ្យបានត្រឹមត្រូវ។ ជ្រូកព្រៃ ជ្រូកដែលដើររកចំណីសេរី សត្វស្លាប សត្វកកេរ និងសត្វព្រៃផ្សេងទៀត អាចចូលមកស៊ី និងធ្វើឱ្យចំណីឆ្លងមេរោគ។ ករណីនេះអាចជាប្រភពនៃការចម្លង និងរាលដាលមេរោគ (Bellini et al., 2016; FAO, 2010; Jurado et al., 2018)។
- ចំណីក្នុងបាវ គួរតែដាក់ក្នុងធុងបិទជិត ឬ ក្នុងឃ្លាំងដែលសត្វកកេរមិនអាចចូលបាន (Bellini et al., 2016; Jurado et al., 2018)។
- ត្រូវតែមានវិធានការ ដើម្បីសម្អាតចំណីដែលកំពប់ភ្លាមៗ ដើម្បីកាត់បន្ថយការទាក់ទាញសត្វកកេរ និងសត្វព្រៃដទៃទៀត (FAO, 2010)។
- វត្ថុធាតុដើមនៃចំណី ដូចជា គ្រាប់ធញ្ញជាតិ ដំណាំ បន្លែ ស្មៅ និងចំបើង មានហានិភ័យតិចតួចបំផុតក្នុងការចម្លងរោគ ASFV។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើ មានហានិភ័យអំពី ASFV នៅក្នុងមូលដ្ឋាន គេពុំគួរប្រើចំណីស្រស់ឡើយ។ គួរហាលធាតុផ្សំនៃចំណីយ៉ាងតិច ៣០ ថ្ងៃ ដើម្បីកំចាត់សកម្មភាពមេរោគពីខាងក្រៅ (FAO, 2010)។
- វត្ថុធាតុដើម នៃចំណីដែលត្រូវដឹកជញ្ជូនចូលកសិដ្ឋាន គួរតែត្រូវបានផ្ទេរនៅកន្លែងដែលបានកំណត់ (Bellini et al., 2016) ដែលជាធម្មតានៅមាត់ច្រកទ្វារ ឬ ក្នុងកន្លែងស្តុក។ ចំណីក្នុងបាវដែលកសិករ ដឹកមកផ្ទាល់ពីហាងផ្គត់ផ្គង់ គួរតែយកទៅទុកក្នុងឃ្លាំងដោយផ្ទាល់តែម្តង។
- តាមតែអាចធ្វើបាន មន្ត្រីបសុពេទ្យ និងអ្នកជំនាញក្នុងមូលដ្ឋាន គួរលើកទឹកចិត្តកសិករម្ចាស់សត្វ ឱ្យប្រើប្រាស់ចំណីពីក្រុមហ៊ុនដែលមានអាចទុកចិត្តបាន (European Commission, 2020)។
- គួរលើកទឹកចិត្តឱ្យកសិករម្ចាស់សត្វប្រើប្រាស់សំណល់ ឬអនុផលកសិកម្ម សម្រាប់ជាចំណីជ្រូករបស់ខ្លួន ជំនួសឲ្យការប្រើសំណល់អាហារពីផ្ទះបាយ។
- ក្នុងករណីប្រើប្រាស់សំណល់ពីផ្ទះបាយសម្រាប់ជាចំណី ត្រូវចម្អិនឱ្យពុះយ៉ាងហោចណាស់ ៣០នាទីដើម្បីរំងាប់មេរោគ (European Commission, 2020) និងទុកឱ្យត្រជាក់ចុះមុនពេលផ្តល់ឱ្យជ្រូកស៊ី។
- មន្ត្រីបសុពេទ្យ ឬអ្នកជំនាញក្នុងមូលដ្ឋាន គួរផ្តល់ការបណ្តុះបណ្តាលដល់កសិករអំពីវិធីជាក់ស្តែង ក្នុងការចំអិនសំណល់អាហារពីផ្ទះបាយសម្រាប់ជាចំណីជ្រូករបស់ខ្លួន។
- មន្ត្រីបសុពេទ្យត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដាក់វិធានការហាមឃាត់កសិករមិនឱ្យចិញ្ចឹមជ្រូកតាមវិធីលែងឱ្យរកស៊ីសេរី។ វាលស្មៅ និងទីកន្លែងនានា ដែលជ្រូកលែងសេរីទៅរកចំណី គឺជាតំបន់គ្រោះថ្នាក់ ហើយអាចមាន មេរោគ (European Commission, 2020)។
- ត្រូវធានាថា មានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់ ហើយបើត្រូវរក្សាទឹកទុក ត្រូវគ្របធុងឱ្យបានជិត (FAO, 2010; Jurado et al., 2018)។



កុំឱ្យជ្រូកស៊ីកាកសំណល់ផ្ទះបាយ



ជម្រើសដ៏ល្អ និងសុវត្ថិភាពបំផុតគឺ ផ្ដល់ចំណីរោងចក្រ



មិនត្រូវយកទឹកដែលលាងសាច់រួចធ្វើជាចំណីសម្រាប់ជ្រូកទេ




បើឱ្យកាកសំណល់ផ្ទះបាយ ត្រូវដាំឱ្យពុះ ១០០អង្សាសេ រយៈពេល ៣០នាទីមុនឱ្យទៅជ្រូកស៊ី

## ៣.៣ កម្រាលក្នុងទ្រុងជ្រូក

- កម្រាលដេកសម្រាប់ជ្រូកនៅក្នុងការបង្ខាំង ក៏ដូចជា ចំណី និងទឹកផងដែរ អាចជាភ្នាក់ងារចម្លង ASFV ទៅក្នុងហ្វូងជ្រូកដែលមានសុខភាពល្អ។ កំទេចរណា ចំណិតឈើ និងចំបើងត្រូវបានគេរកឃើញយ៉ាងច្បាស់ថា អាចមានផ្ទុកមេរោគផ្សេងទៀតផងដែរ (European Commission, 2020)។
- សម្ភារៈសម្រាប់ជាកម្រាលទ្រុង ត្រូវរក្សាទុកឱ្យនៅឆ្ងាយពីអាកាសធាតុខាងក្រៅ និងឆ្ងាយពីជ្រូកព្រៃ ជ្រូកដែលដើររកស៊ីសេរី និងសត្វល្អិត។ គេអាចវេចខ្ចប់កម្រាលទ្រុងដាក់ក្នុងបាវ ឬថង់បិទជិត ឬចងមាត់យ៉ាងជាប់ ហើយទុកនៅលើដំបូល ឬធ្នើរ។
- ប្រសិនបើប្រើចំបើងជាកម្រាលទ្រុង កសិករត្រូវដឹងច្បាស់ពីប្រភពដើមរបស់វា។ ជាការល្អចំបើងទាំងនោះគួរបានមកពីប្រភពដែលមិនប៉ះពាល់ជាមួយជ្រូកព្រៃ ជ្រូកដើររកស៊ីសេរី ឬបសុសត្វដទៃទៀត។
- ដូចគ្នានេះដែរ បើទិញសម្ភារៈកម្រាលមកពីក្រៅ កសិករគួរតែដឹងពីប្រភពដើមរបស់វា ដើម្បីឱ្យប្រាកដថា អ្នកផ្គត់ផ្គង់មានរថយន្ត ឬ រ៉ឺម៉កដោយឡែកសម្រាប់ដឹកជញ្ជូនតែទំនិញសម្រាប់ធ្វើកម្រាលទ្រុង (Levis & Baker, 2011)។
- បើអាចធ្វើបាន ត្រូវជៀសវាងចំបើង ឬសម្ភារៈធ្វើកម្រាលទ្រុង ដែលមានប្រភពមកពីតំបន់ដែលមានឆ្លង ASF (European Commission, 2020)។ ប្រសិនបើ ASF ជាជំងឺដែល

មានដោយឡែកក្នុងតំបន់នោះ សូមស្វែងរកប្រភព សម្ភារៈក្នុងមូលដ្ឋាន ឬនៅជិតកសិដ្ឋាននោះបំផុត តាមដែលអាចធ្វើទៅបាន។

## ៣.៤ យានយន្ត និងបរិក្ខារនានា

- អ្នកបើកបរ និងយានយន្តរបស់ខ្លួន ដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនជ្រូក ឬចំណីសត្វ គឺជាហានិភ័យដ៏សំខាន់សម្រាប់ការរាលដាលមេរោគ ASFV។
- មន្ត្រីបសុពេទ្យ ត្រូវសហការជាមួយភាគីនានាដែលពាក់ព័ន្ធក្នុងខ្សែសង្វាក់តម្លៃជ្រូកក្នុងមូលដ្ឋាន ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលដល់អ្នកបើកបរ និងឈ្មួញកណ្ដាលអំពីវិធានការជីវសុវត្ថិភាព។ វគ្គបណ្ដុះបណ្ដាលបែបនេះគួរមានបញ្ចូលវិធីសាស្ត្រសមស្របសម្រាប់កំចាត់មេរោគ និងការចរាចរណ៍ពីកសិដ្ឋានមួយទៅកសិដ្ឋានផ្សេងទៀតប្រកបដោយសុវត្ថិភាពដើម្បីទប់ស្កាត់ការរាលដាលនៃមេរោគ ASFV។
- អ្នកបើកបរគួរមានការទទួលខុសត្រូវក្នុងការប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងជាប្រចាំទៅតាមស្តង់ដារជីវសុវត្ថិភាព និងមានវិធានការត្រឹមត្រូវ សម្រាប់ការដឹកជញ្ជូនជ្រូកចូលក្នុងបរិវេណនៃកសិដ្ឋាន។
- នៅពេលប្រគល់ទំនិញ អ្នកបើកបរគួរស្ថិតនៅត្រឹមច្រកចូលផ្ទះកសិដ្ឋាន ឬ ស្ថិតនៅឆ្ងាយពីកន្លែងដាក់សត្វជ្រូក។ ប្រសិនបើចាំបាច់ត្រូវទាក់ទងផ្ទាល់ជាមួយកសិករ ពួកគេគួររក្សាចម្ងាយសុវត្ថិភាពដើម្បីទប់ស្កាត់ការប៉ះពាល់ផ្ទាល់។
- ត្រូវធ្វើការសម្អាត និងរំងាប់មេរោគពីយានយន្ត ម៉ូតូ រទេះ និងមធ្យោបាយដឹកជញ្ជូនផ្សេងទៀតទាំងអស់នៅមុន និងក្រោយពេលប្រើប្រាស់ប្រចាំថ្ងៃ។
- ត្រូវរក្សាទុកនៅក្នុងកសិដ្ឋាន និងមិនត្រូវផ្លាស់ទី ឬប្រើប្រាស់រួមគ្នារវាងកសិដ្ឋានឡើយ នូវឧបករណ៍ ឬបរិក្ខារទាំងអស់ដែលអាចមានការប៉ះពាល់ផ្ទាល់ជាមួយជ្រូក ដូចជាខ្សែក្រៀកជ្រូក វត្ថុមុតស្រួច និងចំណី និងស្នូកទឹក។
- ក្នុងករណីដែលចាំបាច់ដែលកសិករត្រូវប្រើប្រាស់រួមគ្នានូវឧបករណ៍មួយចំនួន គេត្រូវសម្អាត និងរំងាប់មេរោគឱ្យបានហ្មត់ចត់នៅចន្លោះពេលប្រើប្រាស់។

**ចំណុចគន្លឹះ**

ត្រូវរក្សាទុកនៅក្នុងកសិដ្ឋាន និងមិនត្រូវផ្លាស់ទី ឬប្រើប្រាស់រួមគ្នារវាងកសិដ្ឋានឡើយ នូវឧបករណ៍ ឬបរិក្ខារទាំងអស់ដែលអាចមានការប៉ះពាល់ផ្ទាល់ជាមួយជ្រូក ដូចជា ខ្សែចងជ្រូក វត្ថុមុតស្រួច និងចំណី និងស្នូកទឹក។

## ៣.៥ ការប្រគល់ទំនិញ និងសម្ភារៈផ្គត់ផ្គង់នានា

- កសិដ្ឋានលក្ខណៈគ្រួសារគួរធានាថា មានការបាញ់ថ្នាំរំងាប់មេរោគយ៉ាងមានសុវត្ថិភាព លើរាល់ទំនិញអសរីរាង្គដែលបានទិញ និង/ឬទទួលបានមកពីក្រៅ។
- ក្នុងករណីមានទីធ្លាសមស្រប ត្រូវធ្វើការកំណត់ទីតាំងសមស្រប សម្រាប់ទទួលទំនិញដែលដឹកមកដល់តាមរទេះរុញ រថយន្ត រ៉ឺម៉ក ឬម៉ូតូជាដើម។
- កសិករលក្ខណៈគ្រួសារគួរពិចារណាបែងចែកផ្នែកខ្លះនៃផ្ទះរបស់ខ្លួន សម្រាប់សម្ភារៈផ្គត់ផ្គង់ និងសម្ភារៈប្រើប្រាស់ ដែលពួកគេអាចត្រួតពិនិត្យ និងរំងាប់មេរោគ មុនពេលដឹកជញ្ជូនដោយសុវត្ថិភាពទៅកាន់ទីតាំងកសិដ្ឋាននោះ។
- កសិករលក្ខណៈគ្រួសារអាចពុំមានឧបករណ៍ និងបរិក្ខារទូទៅដែលចាំបាច់សម្រាប់បុគ្គលិកក្នុងពេលផ្តល់សេវាកម្ម។ ដូច្នេះពួកគេត្រូវតែប្រាកដថា ឧបករណ៍ និងបរិក្ខារទាំងអស់សម្រាប់បុគ្គលិក ត្រូវបានសម្អាត និងរំងាប់មេរោគ។

## ៣.៦ បុគ្គលិក និងការបណ្តុះបណ្តាល

- ការចរាចរណ៍នៃមនុស្សនៅក្នុង និងក្រៅបរិវេណកសិដ្ឋាន រួមទាំង សមាជិកគ្រួសារ និងអ្នកថែទាំផ្សេងទៀត ជាការបង្កើនហានិភ័យនៃការចម្លងមេរោគ ASFV ទៅក្នុងកន្លែងរក្សាទុកសត្វជ្រូក។
- សមាជិកគ្រួសារ កម្មករ និងភ្ញៀវ ត្រូវតែដឹងពីវិធានការជីវសុវត្ថិភាព ដើម្បីកាត់បន្ថយហានិភ័យនៃការបញ្ជូន ASFV ចូលក្នុងកសិដ្ឋាន។ គេអាចធ្វើបែបនេះបាន ដោយដាក់ស្លាកសញ្ញាដែលអាចមើលឃើញ ជាមួយសារសមស្របនៅតាមទីតាំងសមរម្យ។ សារអាចសរសេរជាភាសាក្នុងស្រុក និងមានរូបភាពទាក់ទាញចំណាប់អារម្មណ៍។
- គួរមានដាក់ផ្លាកសញ្ញាចង្អុលបង្ហាញកន្លែងដែលត្រូវដើរផងដែរ ដើម្បីបញ្ចៀសការដើរត្រឡប់ក្រោយចុះឡើង ពីទ្រុងមួយ ទៅទ្រុងមួយទៀត។
- ការចូលទៅកាន់កសិដ្ឋាន និងទ្រុងនីមួយៗ គួរអនុញ្ញាតសម្រាប់តែម្ចាស់កសិដ្ឋាន និងអ្នកថែទាំសត្វប៉ុណ្ណោះ។ បុគ្គលិកសំខាន់ៗទាំងនេះ ត្រូវតែដឹងថា សកម្មភាពរបស់ខ្លួនមានសារៈសំខាន់ក្នុងការទប់ស្កាត់ការឆ្លងមេរោគASFV ។ ពួកគេគួរបានទទួលការរំលឹក ឱ្យជៀសវាងការចូលកសិដ្ឋានចិញ្ចឹមជ្រូកផ្សេងទៀត ការបរបាញ់ និងប៉ះពាល់ជ្រូកពីកសិដ្ឋានផ្សេង។
- គួរមានផ្តល់អាងទឹកថ្នាំលាងជើង នៅច្រកចូលកសិដ្ឋាន និងនៅច្រកចូលទ្រុងនីមួយៗ។ គួរដាក់សញ្ញាប្រាប់ទិសនៅច្រកចូលទាំងនេះ ដើម្បីណែនាំឱ្យអ្នកចូល ជ្រលក់ជើងក្នុងទឹកថ្នាំដើម្បីរំងាប់មេរោគ។ ប្រសិនបើពុំមានស្លាកសញ្ញាទេ អ្នកថែទាំត្រូវណែនាំដល់បុគ្គលនានាឱ្យជ្រលក់ជើងក្នុងអាងទឹកថ្នាំនោះ។
- ជនណាម្នាក់ដែលចូលទៅក្នុងកសិដ្ឋាន មិនត្រូវប៉ះពាល់ ឬ ចូលក្នុងទ្រុងជ្រូកផ្សេងទៀតណាមួយឡើយ ក្នុងរយៈពេល ៤៨ ម៉ោងចុងក្រោយនេះ។ គួររម្លឹកបែបនេះដល់អ្នកជំនាញ

ក្នុងមូលដ្ឋាន អំពីគោលការណ៍ដ៏សំខាន់នេះ។

- ត្រូវហាមការទទួលឱ្យភ្ញៀវចូលក្នុងទ្រុងនានា។
- ចំពោះការចូលទស្សនាក្នុងគោលបំណងទិញជ្រូក កសិករអាចជួបអ្នកទិញនៅច្រកចូលផ្ទះរបស់គាត់ ឬនៅឆ្ងាយពីកសិដ្ឋាន។ អ្នកទិញអាចធ្វើដំណើរពីកសិដ្ឋានមួយទៅកសិដ្ឋានផ្សេងទៀត និងបង្កហានិភ័យជាខ្លាំង ប្រសិនបើអនុញ្ញាតឱ្យចូលទៅក្នុងបរិវេណកសិដ្ឋាននេះ។ ជាមួយបច្ចេកវិទ្យាថ្មីៗ កសិករអាចថតរូប ឬ ផ្សាយរូបភាពជ្រូកដោយផ្ទាល់ សម្រាប់ឱ្យអ្នកទិញធ្វើការពិនិត្យ។
- កម្មករនៅខាងក្រៅកសិដ្ឋាន និងសមាជិកគ្រួសារដែលថែទាំជ្រូក ត្រូវមានសម្លៀកបំពាក់ និងស្បែកជើងដាច់ដោយឡែកពីគ្នានៅក្នុងកសិដ្ឋាន និងត្រូវប្តូរទៅពាក់សម្លៀកបំពាក់ទាំងនោះនៅពេលស្ថិតក្នុងកសិដ្ឋាន។ បើអាចធ្វើបាន ត្រូវមានកន្លែងផ្លាស់សម្លៀកបំពាក់នៅខាងក្រោម ឬ នៅក្រោយផ្ទះកសិដ្ឋាន។ អ្នកជំនួយពីក្រៅកសិដ្ឋានត្រូវលាងដៃជាមួយសាប៊ូ និងទឹកមុនពេលចូល ដើម្បីធានាថា គ្មានការចម្លងមេរោគតាមរយៈការចាប់កាន់ឧបករណ៍ ឬសត្វណាមួយឡើយ។
- ប្រសិនកន្លែងសម្រាប់ជ្រូក ក៏ជាកន្លែងសម្រាប់មនុស្សរស់នៅផងដែរនោះ ត្រូវមានអាងទឹកថ្នាំសម្រាប់លាងជើងនៅគ្រប់ច្រកចូល និងនៅគ្រប់ពេលវេលា។
- មន្ត្រីបសុពេទ្យ និងកម្មវិធីបណ្តុះបណ្តាលសមាគមអ្នកចិញ្ចឹមសត្វគួរសង្កត់ធ្ងន់លើវិធានការទាំងនេះ ដែលពាក់ព័ន្ធនឹងបុគ្គលិកនៅក្នុងកម្មវិធីបណ្តុះបណ្តាលជីវសុវត្ថិភាពរបស់ខ្លួន។ កសិករត្រូវបានទទួលការបណ្តុះបណ្តាលអំពីនីតិវិធីសម្អាត និងរំងាប់មេរោគឱ្យបានត្រឹមត្រូវសម្រាប់ស្បែកជើង និងបរិក្ខាររបស់ខ្លួន បន្ទាប់ពីធ្វើការនៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូក។



**ចំណុចគន្លឹះ**

កម្មករនៅខាងក្រៅកសិដ្ឋាន និងសមាជិកគ្រួសារដែលថែទាំជ្រូក ត្រូវមានសម្លៀកបំពាក់ និងស្បែកជើងដាច់ដោយឡែកពីគ្នានៅក្នុងកសិដ្ឋាន និងត្រូវប្តូរទៅពាក់សម្លៀកបំពាក់ទាំងនោះនៅពេលស្ថិតក្នុងកសិដ្ឋាន។ បើអាចធ្វើបាន ត្រូវមានកន្លែងផ្លាស់សម្លៀកបំពាក់នៅខាងក្រោម ឬ នៅក្រោយផ្ទះកសិដ្ឋាន។ អ្នកក្រៅ ត្រូវលាងដៃជាមួយសាប៊ូ និងទឹកមុនពេលចូលកសិដ្ឋាន ដើម្បីធានាថា គ្មានការចម្លងមេរោគតាមរយៈការចាប់កាន់ឧបករណ៍ ឬសត្វណាមួយឡើយ។

## ៣.៧ សត្វព្រៃ សត្វល្អិត និងការបរបាញ់

- ចៃតុកកែ អាចផ្ទុកមេរោគ ASFV ជាច្រើនខែ រហូតដល់ច្រើនឆ្នាំ ក្រោយពីមករស់នៅលើសត្វជ្រូកដែលមានមេរោគ។ ប្រការនេះធ្វើឱ្យចៃតុកកែ មានសមត្ថភាពក្នុងការចម្លងមេរោគនៅក្នុងរយៈពេលវែង។
- គេនៅពុំទាន់រកឃើញថា ចៃតុកកែ មានជាប់ពាក់ព័ន្ធក្នុងការរាលដាលមេរោគ ASFV នៅអាស៊ីនៅឡើយទេ។ ប៉ុន្តែ កសិករលក្ខណៈគ្រួសារគួរដាក់ចេញវិធានការបង្ការ ឬត្រួតពិនិត្យចៃតុកកែ ដែលជាផ្នែកមួយនៃការគ្រប់គ្រងល្អលើហ្វូងសត្វ។
- ការអនុវត្តល្អ ក្នុងការបង្ការចៃតុកកែ ពីកន្លែងចិញ្ចឹមជ្រូក រួមមាន ការថែរក្សានិងជួសជុលសម្ភារៈបរិក្ខារជាប្រចាំ និងការរក្សាអនាម័យល្អ រួមជាមួយ ការត្រួតពិនិត្យចៃតុកកែផងដែរ។
- គួរគ្រប់គ្រងចៃតុកកែដោយប្រើសមាសធាតុគីមីសម្រាប់កំចាត់ប៉ារ៉ាស៊ីត ដូចជា អ័រកាណូហ្វូស្វាត (គូម៉ាហ្វូស ឌីក្លរ៉ូស ពីរីមីហ្វូស) ពីរ៉េត្រូអ៊ីត (ស៊ីពែរមេទ្រីន ដែលតាមេទ្រីន ហ្វ្លូមេទ្រីន) ម៉ាក្រូស៊ីក្លីក ឡាក់តូន (អ៊ីវែរមិចទីន) និង ហ្វ័រម៉ាមីឌីណ (អាមីត្រាស)។ គេអាចប្រើផលិតផលមួយចំនួនសម្រាប់ងូតទឹកឱ្យជ្រូក ឬលាប 'ចាក់លើ' ឬ 'បន្តក់ពីលើ' សម្រាប់សត្វជ្រូក។ ត្រូវសុំការណែនាំពីបសុពេទ្យ មុនពេលប្រើប្រាស់។
- គេក៏អាចប្រើថ្នាំអិចតូប៉ារ៉ាស៊ីទីស៊ីដមួយចំនួន ដោយបាញ់លើស្នាមប្រេះ និងក្រហែងដែលចៃតុកកែលាក់ខ្លួនផងដែរ។
- កសិករគួរអានស្លាកផលិតផលដោយប្រុងប្រយ័ត្ន ឬពិគ្រោះជាមួយមន្ត្រីបសុពេទ្យ មុននឹងប្រើថ្នាំអិចតូប៉ារ៉ាស៊ីទីស៊ីដ។
- សត្វដែលដើររកស៊ីដោយសេរី ភាគច្រើនជា បសុបក្សី និងបសុសត្វ អាចប៉ះពាល់ផ្ទាល់ជាមួយចំណីដែលឆ្លងមេរោគ ASFV ឬ មានជាប់មេរោគ ASFV នៅលើខ្លួន/រោម ក្រចក បាតជើង ក្រញ៉ាជាដើម និងអាចចម្លងជំងឺដល់ជ្រូក។ ត្រូវមានរបងរាំងទីធ្លាក្នុងកន្លែងចិញ្ចឹមជ្រូក និងវាលស្មៅ ឱ្យបានគត់មត់ ដើម្បីបង្ការការប៉ះពាល់ជាមួយសត្វព្រៃ និងសត្វដើរស៊ីសេរី។
- បើមានជ្រូកព្រៃ ឬ សត្វផ្សេងទៀតដែលរកស៊ីសេរីនៅក្នុងមូលដ្ឋាន កសិករ ឬអ្នកជំនួយការ

ត្រូវលាងសម្អាតឱ្យបានហ្មត់ចត់ និងផ្លាស់ប្តូរសម្លៀកបំពាក់ និងស្បែកជើង ក្រោយបរបាញ់ និងមុនពេលចូលទៅជិតកន្លែងចិញ្ចឹមជ្រូក។

- កសិករអាចផ្លាស់គ្នាជាមួយអ្នកជំនួយការ ដើម្បីបញ្ចៀសអ្នកដែលទៅបរបាញ់ ពីការប៉ះពាល់ផ្ទាល់ជាមួយជ្រូកក្នុងកសិដ្ឋាន យ៉ាងហោចណាស់ ៤៨ម៉ោង។ មិនត្រូវអនុញ្ញាតឱ្យឆ្កែប្រមាញ់ចូលជិតកន្លែងចិញ្ចឹមជ្រូកទេ។
- ត្រូវជៀសវាងការពិឃាតជ្រូកព្រៃដើម្បីយកសាច់លក់ ឬចែកចាយសម្រាប់ការបរិភោគ។
- ជាវិធានការទប់ស្កាត់ គេអាចបាចកាល់ស្យូមអ៊ីដ្រាត (កំបោរ) នៅជុំវិញបរិវេណនៃកសិដ្ឋាន ជាពិសេសប្រសិនបើមានជ្រូកព្រៃ និងជ្រូករកស៊ីសេរីច្រើនក្នុងមូលដ្ឋាន។ គួរត្រួតពិនិត្យ និងបាចម្សៅកំបោរឡើងវិញជាទៀងទាត់។

**ចំណុចគន្លឹះ**

គេនៅពុំទាន់រកឃើញថា ចៃតុកកែ មានជាប់ពាក់ព័ន្ធក្នុងការរាលដាលមេរោគ ASFV នៅអាស៊ីនៅឡើយទេ។ ប៉ុន្តែ កសិករលក្ខណៈគ្រួសារគួរដាក់ចេញវិធានការបង្ការ ឬត្រួតពិនិត្យចៃតុកកែ។ គួរគ្រប់គ្រងចៃតុកកែ ដោយប្រើ សមាសធាតុគីមីសម្រាប់កំចាត់ប៉ារ៉ាស៊ីត ដូចជា អ័រកាណូហ្វូស្វាត (គូម៉ាហ្វូស ឌីក្លរ៉ូស ពីរីមីហ្វូស) ពីរ៉េត្រូអ៊ីត (ស៊ីពែរមេទ្រីន ដែលតាមេទ្រីន ហ្លូមេទ្រីន) ម៉ាក្រូស៊ីក្លីក ឡាក់តូន (អ៊ីវែរម៉ិចទីន) និងហ្វ័រម៉ាមីឌីណ (អាមីត្រាស)។ គេអាចប្រើផលិតផលមួយចំនួនសម្រាប់ងូតទឹកឱ្យជ្រូក ឬលាប ចាក់លើ ឬបន្តក់ពីលើ សម្រាប់សត្វជ្រូក។ ត្រូវសុំការណែនាំពីបសុពេទ្យ មុនពេលប្រើប្រាស់។



## ៣.៨ ការគ្រប់គ្រងសំណល់ពីកន្លែងចិញ្ចឹមជ្រូក

- មេរោគ ASFV អាចមានជីវិតរយៈពេលយូរនៅក្នុងសារធាតុរាវសំបោរ ទឹកមាត់ ទឹកនោម និងលាមក។ ដូច្នេះ ត្រូវពិចារណាការចោលសំណល់ពីកន្លែងចិញ្ចឹមជ្រូកដោយប្រុងប្រយ័ត្ន នៅពេលរៀបចំ និងអនុវត្តកម្មវិធីជីវសុវត្ថិភាព។
- មិនត្រូវបញ្ចេញចោលសំណល់ពីកន្លែងចិញ្ចឹមជ្រូក ដោយផ្ទាល់ទៅក្នុងបរិស្ថានខាងក្រៅឡើយ។
- មិនត្រូវប្រើប្រាស់រួមគ្នានូវបរិក្ខារគ្រប់គ្រងសំណល់ពីកន្លែងចិញ្ចឹមជ្រូករវាងកសិដ្ឋាន និងទីតាំងនានាឡើយ ព្រោះវាបង្កើនហានិភ័យនៃការឆ្លងមេរោគ ASFV។
- មិនត្រូវរក្សាទុក ឬចោលសំណល់ពីកន្លែងចិញ្ចឹមជ្រូកនៅខាងក្រៅកសិដ្ឋានឡើយ។ ត្រូវមានការគ្រប់គ្រងសំណល់ពីកសិដ្ឋានចិញ្ចឹមជ្រូក និងការធ្វើប្រព្រឹត្តកម្មសំណល់លាមកជ្រូកឱ្យបានត្រឹមត្រូវ តាមរយៈការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពទៅកសិដ្ឋានដាំដំណាំ ឬ ការទុកដាក់ និងការបិទបាំងឱ្យជិតនៅក្នុងរណ្ដៅ។
- គេអាចប្រើលាមកជ្រូកសម្រាប់ផលិតជីវឧស្ម័ន។ គេអាចសង់ឡជីវឧស្ម័នលក្ខណៈគ្រួសារនៅក្នុងបរិវេណកសិដ្ឋានចិញ្ចឹមជ្រូក (ដាច់ចេញពីកន្លែងដាក់ជ្រូក/ទ្រុងជ្រូក) ឬ នៅកម្រិតភូមិ។ ការសង់ឡទាំងនេះគួរតែធ្វើឡើងដោយមានការបណ្ដុះបណ្ដាលកសិករ ដើម្បីប្រើប្រាស់ឡទាំងនេះឱ្យមានប្រសិទ្ធភាព (Roubík et al., 2018)។
- ត្រូវសម្អាត និងរំងាប់មេរោគលើយានយន្ត និងបរិក្ខារទាំងអស់ដែលប្រើក្នុងការគ្រប់គ្រងលាមកជ្រូកឱ្យបានហ្មត់ចត់។ បុគ្គលិកត្រូវធ្វើការលាងសម្អាតឱ្យបានត្រឹមត្រូវ។
- មន្ត្រីបសុពេទ្យគួរសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល ដើម្បីបណ្ដុះបណ្ដាលកសិករអំពីការប្រើប្រាស់លាមកជ្រូកឱ្យបានត្រឹមត្រូវ សម្រាប់ជាជី ដូចជាក្នុងការដាំដំណាំ និងការផលិតជីវឧស្ម័ន។

**ចំណុចគន្លឹះ**

មិនត្រូវរក្សាទុក ឬចោលសំណល់ពីកន្លែងចិញ្ចឹមជ្រូកនៅខាងក្រៅកសិដ្ឋានឡើយ។ ត្រូវមានការគ្រប់គ្រងសំណល់ពី កសិដ្ឋានចិញ្ចឹមជ្រូក និងធ្វើប្រព្រឹត្តកម្មសំណល់លាមកជ្រូកឱ្យបានត្រឹមត្រូវ តាមរយៈការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពទៅកសិដ្ឋានដាំដំណាំ ឬការទុកដាក់ និងការបិទបាំងឱ្យជិតនៅក្នុងរណ្ដៅ។ ត្រូវសម្អាត និងរំងាប់មេរោគលើយានយន្ត និងបរិក្ខារទាំងអស់ដែលប្រើក្នុងការគ្រប់គ្រងលាមកជ្រូកឱ្យបានហ្មត់ចត់។ បុគ្គលិកត្រូវធ្វើការលាងសម្អាតឱ្យបានត្រឹមត្រូវ។

## ៣.៩ នីតិវិធីសម្អាតទូទៅ និងការរំងាប់មេរោគ

- ដើម្បីបង្ការការនាំចូលមេរោគ ASFV ការសម្អាតដើម្បីកំចាត់សារជាតុសរីរាង្គទាំងអស់ ដូចជា លាមកសត្វ ទឹកនោម ចំបើង និងកម្រាលសត្វដេកជាដើម គឺជាជំហានដំបូងដ៏សំខាន់មួយនៃនីតិវិធីទាំងនេះ (FAO, 2010; Levis & Baker, 2011; SPS, 2019)។
- ក្នុងន័យនេះ មន្ត្រីបសុពេទ្យគ្រប់លំដាប់ថ្នាក់ និងសហគមន៍កសិករ ឬសមាគមអ្នកចិញ្ចឹមសត្វគួរវិនិយោគលើការបណ្ដុះបណ្ដាលកសិករលក្ខណៈគ្រួសារ។ ដំណើរការសម្អាតត្រូវធ្វើឱ្យបានល្អិតល្អន់បំផុត។ គួរធ្វើការសម្អាតដើម្បីកំចាត់សារជាតុសរីរាង្គទាំងអស់ឱ្យបានហ្មត់ចត់ ពីគ្រឿងបរិក្ខារ កន្លែងដាក់សត្វ និងកន្លែងកៀនកោះនានា ដោយប្រើសាប៊ូ ក្នុងករណីចាំបាច់ មុននឹងប្រើថ្នាំរំងាប់មេរោគ។
- ប្រការចាំបាច់ គឺត្រូវទុកឱ្យឧបករណ៍ ឬគ្រឿងបរិក្ខារស្ងួតល្អ បន្ទាប់ពីការលាងសម្អាត និងរំងាប់មេរោគមុនយកមកប្រើប្រាស់ ព្រោះថាមេរោគ ASFV អាចរស់បាននៅក្នុងទីមានសំណើម និងបន្តឆ្លងទៅជ្រូក។
- គួរលើកទឹកចិត្តកសិករឱ្យប្រើផ្ទៃបេតុង ព្រោះវាជួយលុបបំបាត់សំណល់រាវ និងងាយស្រួលរំងាប់មេរោគ។
- គួរប្រើតែថ្នាំរំងាប់មេរោគដែលមានអនុញ្ញាត និងស្របតាមការណែនាំរបស់អ្នកផលិតប៉ុណ្ណោះ។ មន្ត្រីបសុពេទ្យ និងសមាគមអ្នកចិញ្ចឹមសត្វ គួររៀបចំកម្មវិធីបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវសារជាតុរំងាប់មេរោគដែលមានការអនុញ្ញាត និងដែលមានសមត្ថភាពកម្ចាត់ ASFV។
- នៅតាមជនបទ អាចគ្មានថ្នាំកម្ចាត់មេរោគដែលមានប្រសិទ្ធភាពប្រឆាំងនឹង ASFV ដូច្នេះមន្ត្រីបសុពេទ្យអាចណែនាំអំពីថ្នាំរំងាប់មេរោគដែលមានប្រសិទ្ធភាព និងបើអាចធ្វើបានសូមសម្រួលឱ្យមានលក់លើទីផ្សារក្នុងមូលដ្ឋាន។

**ចំណុចគន្លឹះ**

គួរប្រើតែថ្នាំរម្ងាប់មេរោគដែលមានអនុញ្ញាត និងស្របតាមការណែនាំរបស់អ្នកផលិតប៉ុណ្ណោះ។ មន្ត្រីបសុពេទ្យ និងសមាគមអ្នកចិញ្ចឹមសត្វ គួររៀបចំកម្មវិធីបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវសារជាតុរំងាប់មេរោគដែលមានការអនុញ្ញាត និងដែលមានសមត្ថភាពកម្ចាត់ ASFV។

1.



រៀបចំសម្ភារៈទាំងអស់សម្រាប់ការ
សម្អាតនិងការរំងាប់មេរោគ

2.



ជូតធូលី និងស្នាមប្រឡាក់ចេញ

3.



យកច្រាស់ដុស
ដោយប្រើសាប៊ូ និងទឹក

4.



បាញ់ថ្នាំរំងាប់មេរោគ

5.



លាងបរិក្ខារទាំងអស់ និង
ស្បែកជើង ក្រោយការសម្អាត
និងរំងាប់មេរោគ

**នេះជាវិធីត្រឹមត្រូវ សម្រាប់ការសម្អាត និងរំងាប់មេរោគនៅលើដៃរបស់អ្នក**

### ៣.៩.១ ការពិចារណាសម្រាប់ការសម្អាត និងការរំងាប់មេរោគ

ការរំងាប់មេរោគនឹងពុំមានប្រសិទ្ធភាពទេ ប្រសិនបើពុំប្រើប្រាស់សារធាតុគីមីសមស្រប។ សារធាតុគីមីបែបនេះអាចមានខុសៗគ្នានៅតាមប្រទេសផ្សេងៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ មន្ត្រីបសុពេទ្យគួរធានាថា មានការប្រើប្រាស់តែសារធាតុគីមីដែលបានទទួលការអនុញ្ញាត ដោយអាជ្ញាធរនិយតកម្មមានសមត្ថកិច្ចនៅក្នុងប្រទេស អាចរកបានក្នុងមូលដ្ឋាន និងដែលមានការផ្សព្វផ្សាយប៉ុណ្ណោះ។

ជំហានសំខាន់ៗក្នុងការសម្អាត និងរំងាប់មេរោគ មានជាអាទិ៍ (FAO, 2010)៖

១ មុនសម្អាត ត្រូវយកអ្វីៗទាំងអស់ចេញជាមុន។ ត្រូវកំចាត់ចោលសារធាតុសរីរាង្គដូចជា ដី លាមកសត្វ កម្រាលសត្វដេក និងកំទេចកំទីចំណី ដូចជាតាមរយៈការបោសសំអាត យកច្រាសដុស និងជូត។ អង្គធាតុសរីរាង្គអាចស្រូបយកថ្នាំរំងាប់មេរោគ និងកាត់បន្ថយផ្ទៃដែលប៉ះជាមួយថ្នាំ ដែលធ្វើឱ្យថ្នាំមិនសូវមានប្រសិទ្ធភាពក្នុងការរំងាប់មេរោគ។

២ សម្រាប់កន្លែងដែលមានផ្ទៃបេតុង ត្រូវមានប្រព័ន្ធលូ ឬបណ្តាញទឹក សម្រាប់បង្ហូរចេញសំណល់រាវ។

៣ ចំពោះកន្លែងដែលគ្មានផ្ទៃបេតុង ត្រូវយកចេញនូវសារធាតុសរីរាង្គឱ្យអស់ តាមដែលអាចធ្វើទៅបាន ដូចជា កម្រាលសម្រាប់សត្វដេក លាមកជ្រូក ជាដើម។

៤ ត្រូវលាងសម្អាតស្បែកជើងកវែងឱ្យបានហ្មត់ចត់ ដើម្បីកំចាត់សារធាតុសរីរាង្គទាំងអស់ចេញ មុនពេលចូល និងក្រោយចេញពីទ្រុងជ្រូក។ សិនបើមានអាងទឹកថ្នាំលាងជើង ត្រូវប្តូរទឹកថ្នាំនេះឱ្យបានញឹកញាប់។

៥ ដើម្បីមានប្រសិទ្ធភាពខ្ពស់ ត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ ក្រោយពេលបាញ់ថ្នាំកម្ចាត់មេរោគ។ព័ត៌មានអំពីរយៈពេលដែលត្រូវទុកចោលក្រោយបាញ់ថ្នាំ គួរតែមានបញ្ជាក់នៅលើស្លាកផលិតផល។

៦ ជាទូទៅ ប្រសិទ្ធភាពរបស់ថ្នាំសំលាប់មេរោគ នឹងថយចុះនៅក្នុងរដូវវស្សា ដោយសារទឹកភ្លៀងអាចកាត់បន្ថយកំហាប់ថ្នាំរំងាប់មេរោគ ជាពិសេស ប្រសិនបើប្រើក្នុងអាងទឹកថ្នាំលាងជើង។ ម្យ៉ាងវិញទៀត នៅរដូវក្តៅ ថ្នាំកម្ចាត់មេរោគអាចហួត ឬស្ងួតយ៉ាងឆាប់រហ័ស។ ជាការល្អ ត្រូវពិនិត្យទឹកថ្នាំនៅក្នុងអាងលាងជើងជាប្រចាំ។

៧ ជាការល្អ មិនត្រូវលាយថ្នាំរំងាប់មេរោគផ្សេងគ្នានៅនឹងកន្លែងផ្ទាល់ឡើយ។ ក្រៅពីបញ្ហាសុវត្ថិភាព ប្រសិទ្ធភាពនៃទឹកថ្នាំនឹងអាចថយចុះផងដែរ។

៨ គួរលើកទឹកចិត្តឱ្យអនុវត្តវិធានការសុវត្ថិភាពនៅគ្រប់ពេលប្រើប្រាស់ថ្នាំរំងាប់មេរោគ។ ឧទាហរណ៍ ការលាយថ្នាំរំងាប់មេរោគដែលជាអាល់កាឡាំង ជាមួយអាស៊ីត នឹងបន្សាបឥទ្ធិពលរបស់វា។ គួរអនុវត្តតាមការណែនាំដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងការបង្កគ្រោះថ្នាក់ដល់ខ្លួនឯងនិងសត្វ។ ត្រូវពាក់ស្រោមដៃកៅស៊ូ និងរបាំងមុខនៅគ្រប់ពេលពេលប្រើសារធាតុគីមី។

៩ ក្រោយធ្វើការរំងាប់មេរោគ ត្រូវបើកឱ្យខ្យល់ចេញចូល ហើយទុកឱ្យស្ងួតមុននឹងអនុញ្ញាតឱ្យជ្រូកចូល។

១០ ក្រោយធ្វើការរំងាប់មេរោគ ត្រូវបើកឱ្យខ្យល់ចេញចូល ហើយទុកឱ្យស្ងួតមុននឹងអនុញ្ញាតឱ្យជ្រូកចូល។

### ៣.៩.២ គន្លឹះសម្រាប់ការរំងាប់មេរោគ ASFV

មេរោគ ASFV អាចរស់នៅរយៈពេលយ៉ាងយូរនៅក្នុងឈាម លាមក ទឹករំអិល និងជាលិកាសត្វ។ ដូច្នេះ ត្រូវពិចារណាចំណុចនេះ នៅពេលជ្រើសរើសថ្នាំរំងាប់មេរោគសម្រាប់ប្រឆាំងនឹង ASFV។ គោលបំណងនៃការរំងាប់មេរោគគឺ ធ្វើឱ្យមេរោគលែងមានសកម្មភាព។ គេអាចសម្រេចគោលដៅនេះបាន តាមវិធីរូប (កំដៅ) ឬវិធីគីមី ឬ ការបញ្ចូលវិធីទាំងពីរជាមួយគ្នា។ សារធាតុគីមីដូចខាងក្រោមអាចត្រូវបានប្រើដើម្បីរំងាប់មេរោគលើសម្ភារៈ និងរចនាសម្ព័ន្ធសំណង់រឹង បន្ទាប់ពីបានសម្អាតចេញសារធាតុសរីរាង្គយ៉ាងហ្មត់ចត់។ ជម្រើសសារធាតុគីមីអាស្រ័យលើវត្តមានសារធាតុគីមី ថ្លៃចំណាយ និងវត្តមាននៃឧបករណ៍សមស្របសម្រាប់ប្រើជាមួយសារធាតុគីមីនោះ។ មន្ត្រីបសុពេទ្យ ឬអ្នកជំនាញនៅមូលដ្ឋាន អាចណែនាំ និងបណ្តុះបណ្តាលកសិករអំពីជម្រើសទាំងនេះ។

#### សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសផ្សេងទៀត |
|---|---|
| សូដ្យូមអ៊ីដ្រុកស៊ីត (NaOH) | ▪ សារធាតុគីមីនេះត្រូវបានចាត់ថា ជាមុខសញ្ញាគ្រោះថ្នាក់ ដោយស្តង់ដារមុខសញ្ញាគ្រោះថ្នាក់ OSHA ឆ្នាំ ២០១២ (29 CFR 1910.1200)។<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្តាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ អាចបង្កច្រេះលោហធាតុ<br>▫ អាចបណ្តាលឱ្យរលាកផ្លូវដង្ហើម<br>▪ ការប្រុងប្រយ័ត្ន<br>▫ ពាក់ស្រោមដៃការពារ/សម្លៀកបំពាក់ការពារបាំងការពារភ្នែក/ការពារមុខ<br>▫ ប្រើតែនៅទីចំហ ឬក្នុងកន្លែងដែលមានខ្យល់ចេញចូលបានល្អ<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ ហាមចាក់ចោលក្នុងលូទឹក។ មានផ្ទុកសារធាតុដែលបង្កគ្រោះថ្នាក់ដល់សារពាង្គកាយក្នុងទឹក និងបង្កគ្រោះថ្នាក់ដល់បរិស្ថាន។ រលាយក្នុងទឹក។ ផ្អែកលើព័ត៌មានដែលមាន វាមិនទំនងជាអាចនៅស្ថិតស្ថេរបានយូរឡើយ។ វាអាចជាចរាចរណ៍នៅក្នុងបរិស្ថាន ដោយសារវាងាយរលាយក្នុងទឹក។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសដទៃទៀត |
|---|---|
| **អ៊ីប៉ូក្លរីត (NaOCl, Ca(ClO)2)** | ▪ ក្លរីនមានប្រសិទ្ធភាពប្រឆាំងនឹងមេរោគ ASFV នៅកំហាប់ពី ០,០៣% ទៅ ០,០០៧៥% និងត្រូវបានសង្កេតឃើញមានប្រតិកម្មតបបានល្អ ពេលប្រើបានមួយដូស។<br>▪ អត្តសញ្ញាណគ្រោះថ្នាក់ជំពូក ១<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ សេចក្តីថ្លែងការណ៍អំពីគ្រោះថ្នាក់៖ អាចបង្កជាច្រេះចំពោះលោហធាតុ<br>▫ បណ្តាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ បណ្តាលឱ្យខូចភ្នែកធ្ងន់ធ្ងរ<br>▪ កម្រិតពុល និងច្រេះនៃសូដ្យូមអ៊ីប៉ូក្លរីត កើនឡើងទៅតាមកំហាប់។ ផលិតផលដែលមានប្រើក្នុងឧស្សាហកម្ម និងដែលមានកំហាប់ខ្ពស់ជាងម្សៅដែលប្រើតាមផ្ទះ មានកម្រិតពុលខ្លាំង និងច្រេះខ្លាំង។<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ នេះជាសារធាតុអសរីរាង្គ និងមិនរលាយតាមរយៈប្រតិកម្មជីវសាស្ត្រឡើយ។ គេជឿថា សារធាតុនេះមិន ស្ថិតស្ថេរបានយូរក្នុងបរិស្ថានឡើយ។ គេមិនរំពឹងថា សារធាតុនេះប្រមូលផ្តុំនៅក្នុងសារពាង្គកាយរស់ឡើយ។ សារធាតុនេះអាចបង្កគ្រោះថ្នាក់ចំពោះត្រី សត្វគ្មានឆ្អឹងកង ថលជលិក និងរុក្ខជាតិ។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសផ្សេងទៀត |
|---|---|
| **ប៉ូវីដូន អ៊ីយ៉ូឌីន** | ▪ ប៉ូវីដូន អ៊ីយ៉ូឌីន ៥% គឺជាសារធាតុគីមីដែលបំផ្លាញ និងរារាំងការលូតលាស់នៃមេរោគ។ វាផ្សំដោយប៉ូវីដូន អ៊ីយ៉ូឌីន ដែលរារាំងការបង្ករោគដោយបាក់តេរី។ វាបំផ្លាញ និងរារាំងការលូតលាស់នៃមេរោគៈ ជួយកាត់បន្ថយបាក់តេរី និងវីរុស។<br>▪ សារធាតុគីមីនេះត្រូវបានចាត់ទុកថា មានគ្រោះថ្នាក់ បើគិតតាមស្តង់ដារមុខសញ្ញាគ្រោះថ្នាក់ OSHA ឆ្នាំ ២០១២ (29 CFR 1910.1200)<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បង្កការខូចខាតដល់សរីរាង្គ តាមរយៈការប៉ះពាល់រយៈពេលវែង ឬ ប៉ះពាល់ជាច្រើនលើក<br>▫ បណ្ដាលឱ្យរលាកភ្នែកធ្ងន់ធ្ងរ<br>▫ បណ្ដាលឱ្យរលាកស្បែក<br>▫ មានគ្រោះថ្នាក់ បើស្រូបចូល<br>▫ មានគ្រោះថ្នាក់ បើលេបចូល<br>▫ មានគ្រោះថ្នាក់ បើប៉ះលើស្បែក<br>▫ មានច្រេះចំពោះលោហធាតុ<br>▫ អាចបង្កឱ្យងងុយដេក ឬវិលមុខ<br>▫ អាចបង្កឱ្យរលាកផ្លូវដង្ហើម |
| **ប៉ូតាស្យូម តេត្រាគ្លីស៊ីន ទ្រីអ៊ីយ៉ូដាយ (I3K)** | ▪ អ៊ីយ៉ូត មានប្រសិទ្ធភាពខ្លាំងក្នុងការប្រឆាំងនឹង ASFV នៅកំហាប់ពី ០,០១៥% ទៅ ០,០០៧៥% ប៉ុន្តែពុំបានសង្កេតឃើញមានការឆ្លើយតបឡើយ បើប្រើបានត្រឹមមួយដូស។<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ ជៀសវាងការស្រូបយកចំហាយទឹក អ័ព្ទ ឬឧស្ម័ននៃសារធាតុគីមីនេះ។ ត្រូវធ្វើឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់។<br>▫ វាអាចបែកធាតុដោយបង្កើតជាផលិតផលដែលបង្កគ្រោះថ្នាក់នៅក្រោមលក្ខខណ្ឌដែលមានភ្លើង។ |

### សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសដទៃទៀត |
|---|---|
| | ▪ ការពិចារណាអំពីបរិស្ថាន<br>▫ ពុលខ្លាំងនៅក្នុងទឹក (ក្រុមទី ៣)<br>▫ គ្រោះថ្នាក់ដល់សារពាង្គកាយមានជីវិតនៅក្នុងទឹក<br>▫ ត្រូវជៀសវាងការបញ្ចេញទៅក្នុងបរិស្ថាន<br>▫ មានគ្រោះថ្នាក់ចំពោះបរិស្ថានក្នុងទឹក គ្រោះថ្នាក់ខ្លាំងក្លាទប់ស្កាត់ការលេចធ្លាយ ឬកំពប់បន្ថែមទៀត ប្រសិនបើធ្វើបែបនេះបានដោយសុវត្ថិភាព។ ហាមកំពប់ចូលក្នុងបំពង់លូ។ ត្រូវជៀសវាងការបង្ហូរចូលទៅក្នុងបរិស្ថាន។ (ក្រុមទី ៣) |
| **អាល់គីលបង់ហ្សីនស៊ុលហ្វូណាត ($C_{18}H_{29}NaO_3S$): ម្សៅសាប៊ូ** | ▪ សាប៊ូបោកខោអាវ គឺជាសារធាតុ ឬល្បាយនៃសារធាតុដែលជួយនៅក្នុងការលាងសម្អាត។<br>▪ វាពុកផុយដោយសារសកម្មភាពជីវសាស្ត្រ ដោយសារការកាត់ផ្តាច់អ៊ីសូមែរ ហើយនៅក្នុងករណីនេះ គឺការកាត់ផ្តាច់ខ្នែងនៃម៉ូលេគុល។ សមាសធាតុដែលគ្មានខ្នែងម៉ូលេគុល ងាយបំប្លែងជាងសមាសធាតុដែលមានខ្នែងម៉ូលេគុល ដូច្នេះវាជាជម្រើសដែលមានសុវត្ថិភាពជាងគេ។<br>▪ វាងាយពុកផុយយ៉ាងឆាប់រហ័សនៅក្រោមលក្ខខណ្ឌដែលមានខ្យល់ ក្នុងនោះពាក់កណ្តាលអាយុកាលរបស់វាមានប្រហែល ១-៣សប្តាហ៍។ ប្រតិកម្មអុកស៊ីតកម្មចាប់ផ្តើមនៅត្រង់ខ្សែប្រវាក់អាល់គីល។<br>▪ នៅក្នុងលក្ខខណ្ឌគ្មានខ្យល់ វាពុកផុយយឺតណាស់ ឬ មិនពុកផុយតែម្តង ដែលបណ្តាលឱ្យវាស្ថិតនៅដោយមានកំហាប់ខ្ពស់ក្នុងភក់លូទឹកសំអុយ ប៉ុន្តែចំណុចនេះពុំត្រូវគេចាត់ថាជាមូលហេតុនៃការព្រួយបារម្ភឡើយ ព្រោះវានឹងពុកផុយយ៉ាងឆាប់រហ័សនៅពេលវិលមកស្ថានភាពដែលមានអុកស៊ីសែនវិញ។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសផ្សេងទៀត |
| --- | --- |
| ល្បាយរវាងសូដ្យូមអ៊ីដ្រុកស៊ីត និងប៉ូលីអេទីឡែនអុកស៊ីត | ▪ សូដ្យូមអ៊ីដ្រុកស៊ីត ៥-១០%, ប៉ូលីអេទីឡែនអុកស៊ីដ ២,៥-៥%<br>▪ វាជាល្បាយអាល់កាឡាំងកម្រិតខ្ពស់ នៃសារធាតុដែលមានបន្ទុកងាយប្រែប្រួល រវាងបន្ទុកដក ណឺត និងបូក នៅក្នុងសូលុយស្យុងរាវដែលរួមទាំង ជាសារធាតុសម្រាប់បង្កើនសកម្មភាពនៅក្នុងទឹករឹងផងដែរ។<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្តាលអោយរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ បណ្តាលឱ្យរលាកធ្ងន់ធ្ងរ<br>▪ ងាយមានប្រតិកម្មដែលអាចបង្កគ្រោះថ្នាក់ក្នុងករណីមានភ្លើង៖ កាបូនឌីអុកស៊ីត កាបូនម៉ូណូអុកស៊ីត<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ តាមធម្មតា ទម្រង់បែបបទនេះត្រូវបានបង្កើតឡើងសម្រាប់ស្ថានភាពបរិស្ថានរបស់វា ដូចជា ការពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ។ ការបង្កើតឡើងនេះ ស្របតាមលក្ខខណ្ឌតម្រូវនៃការពុកផុយក្នុងលក្ខខណ្ឌជីវសាស្ត្រ ដែលចែងដោយបទប្បញ្ញត្តិរបស់អ៊ឺរ៉ុបស្តីពីសាប៊ូបោកខោអាវ (648/2004/EC)។<br>▫ ហាមធ្វើឱ្យក្រខ្វក់ទឹកលើផ្ទៃដី។ ហាមចាក់ផលិតផលនេះចូលក្នុងបំពង់លូ។<br>▪ ការចាក់ចោល៖ រលាយក្នុងបរិមាណតិចតួចនៅក្នុងសំណល់រាវតាមរយៈ លូទឹកសំអុយ ឬ កន្លែងប្រព្រឹត្តកម្មសំណល់រាវផ្សេងទៀត ស្របតាមបទប្បញ្ញត្តិរបស់អាជ្ញាធររដ្ឋាករទឹកនៅក្នុងមូលដ្ឋាន។ |
| ល្បាយអូហ្សូន (2KHSO5• KHSO4• K2SO4) | ▪ ផ្សំដោយអុកសូន (ប៉ូតាស្យូម ពីរ៉ូស៊ីម៉ូណូស៊ុលហ្វាត) សូដ្យូមដូដេស៊ីលបេនហ្សេនស៊ុលហ្វូណាត អាស៊ីតស៊ុលហ្វាមីក និងស្រទាប់ទ្រនាប់អសរីរាង្គ<br>▪ សារធាតុគីមី ប៉េរ៉ុកស៊ីស្សែន ផ្តល់នូវប្រសិទ្ធភាពក្នុងវិសាលគមធំទូលាយដែលវិវត្តជាបន្តបន្ទាប់ ប្រឆាំងទល់នឹងសារពាង្គកាយដែលបង្កជំងឺដែលមានស្រាប់ និងដែលកំពុងឡើងថ្មី ដោយផ្តោតជាពិសេសលើភ្នាក់ងារបង្កជំងឺ ដូចជា ASF, FMD និងប្រភេទជាក់លាក់នៃ HPAI។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសដទៃទៀត |
|---|---|
| | ▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ ម្សៅនេះមានលក្ខណៈកំណូត។ បង្កឱ្យរលាកស្បែក និងការខូចខាតភ្នែកដែលមិនអាចព្យាបាលបាន។ វាបង្កគ្រោះថ្នាក់ប្រសិនបើលេប ជ្រាបចូលតាមស្បែក ឬ ស្រូបចូលពេលដកដង្ហើម។<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ អាចពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ។ គ្មានឥទ្ធិពលលើស្ថានីយប្រព្រឹត្តកម្មសំណល់ឡើយ។ |
| **សមាសធាតុអាម៉ូញ៉ូមបួន (ឌីដេស៊ីលឌីមេទីលអាម៉ូញ៉ូមក្លរីដ)** | ▪ សមាសធាតុអាម៉ូញ៉ូមវ៉ាឡង់បួន មានប្រសិទ្ធភាពខ្លាំងនៅកំហាប់ទាបត្រឹម 0,00៣% ប្រឆាំងនឹង ASFV<br>▪ មាសធាតុផ្សំ<br>▫ ឌីដេស៊ីលឌីមេទីលអាម៉ូញ៉ូម ក្លរីដ ងាយពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ<br>▫ អាល់គីល ឌីមេទីល បេនហ្ស៊ីល អាម៉ូញ៉ូម ក្លរីដ ងាយពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ<br>▫ តេត្រាសូដ្យូម អេទីឡែន ឌីយ៉ាមីន តេត្រាអាសេតាត ងាយពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ<br>▫ អេទីលអាល់កុល ងាយពុកផុយក្រោមលក្ខខណ្ឌជីវសាស្ត្រ<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្តាលឱ្យខូចភ្នែកធ្ងន់ធ្ងរ<br>▫ បណ្តាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ អង្គធាតុរាវ និងចំហាយដែលអាចឆេះបាន<br>▫ គ្រោះថ្នាក់ បើលេបចូល<br>▫ គ្រោះថ្នាក់ បើប៉ះស្បែក<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ ក្រៅពីការប្រើប្រាស់ធម្មតា ត្រូវជៀសវាងការបញ្ចេញចោលទៅក្នុងបរិស្ថាន។ មិនរំពឹងថា មានផលអវិជ្ជមានចំពោះបរិស្ថានឡើយ ក្នុងករណីប្រើប្រាស់ ទៅតាមការណែនាំលើស្លាកសញ្ញា។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសផ្សេងទៀត |
|---|---|
| **សូដ្យូម ឌីក្លរ៉ូអ៊ីសូស្យានូរ៉ាត (C3Cl2N-3NaO3)៖ ម្សៅកំចាត់ពណ៌** | ▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្តាលឱ្យខូចភ្នែកធ្ងន់ធ្ងរ<br>▫ បណ្តាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ បង្កគ្រោះថ្នាក់ បើលេបចូល<br>▪ អាចធ្វើឱ្យឆាបឆេះកាន់តែខ្លាំង។ អុកស៊ីតកម្ម<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ ពុលខ្លាំងដល់សារពាង្គកាយមានជីវិតក្នុងទឹក ដោយមានផលប៉ះពាល់រយៈពេលវែង<br>▫ ទប់ស្កាត់ការលេចធ្លាយ ឬកំពប់បន្ថែមទៀត ប្រសិនបើមានសុវត្ថិភាពក្នុងការធ្វើបែបនេះ។ មិនត្រូវឱ្យផលិតផលនេះចូលក្នុងបំពង់លូឡើយ។ ត្រូវជៀសវាង ការបង្ហូរចូលទៅក្នុងបរិស្ថាន។<br>▫ ហាមបញ្ចេញទៅក្នុងបរិស្ថាន។ ត្រូវទប់ស្កាត់សារធាតុនេះពីការហូរចូលទៅក្នុងប្រភពទឹក និងត្រូវចាប់ ផ្តើមត្រួតពិនិត្យវត្តមានក្លរីន និង pH ភ្លាមៗ។ ត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់នៅខ្សែទឹកខាងក្រោម អំពីលទ្ធភាពនៃការឆ្លងរោគ។ |
| **អាស៊ីតស៊ីទ្រិក (C6H8O7)** | ▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្តាលឱ្យខូចភ្នែកធ្ងន់ធ្ងរ<br>▫ បណ្តាលឱ្យរលាកស្បែក<br>▫ អាចបណ្តាលឱ្យរលាកផ្លូវដង្ហើម<br>▪ ប្រសិនបើផលិតផលនេះប៉ះភ្លើង វាអាចបំភាយឧស្ម័នកាបូនម៉ូណូអុកស៊ីត និងកាបូនឌីអុកស៊ីត<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ មិនអនុញ្ញាតឱ្យបញ្ចេញសារធាតុនេះទៅក្នុងបរិស្ថាន ដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលឡើយ។ មិនត្រូវទុកឱ្យផលិតផលនេះដែលមិនរលាយ ឬ ផលិតផលនេះក្នុងបរិមាណយ៉ាងច្រើនជ្រាបចូលដល់ខ្សែទឹកក្រោមដី ផ្លូវទឹក ឬប្រព័ន្ធលូ។ ជៀសវាងការបញ្ចេញទៅក្នុងបរិស្ថាន។ |

## សារធាតុគីមីដែលប្រើជាថ្នាំប្រឆាំង ASF (ត)

| ថ្នាំរំងាប់មេរោគ | លក្ខណៈបច្ចេកទេសដទៃទៀត |
|---|---|
| **អាស៊ីត ហ្វ័រមិក (HCOOH)** | ▪ ត្រូវចាត់ទុកសារធាតុគីមីនេះ ថាមានគ្រោះថ្នាក់ យោងតាមស្តង់ដារ មុខសញ្ញាគ្រោះថ្នាក់ OSHA ឆ្នាំ ២០១២ (29 CFR 1910.1200)<br>▪ មុខសញ្ញាគ្រោះថ្នាក់<br>▫ បណ្ដាលឱ្យរលាកស្បែកធ្ងន់ធ្ងរ និងខូចភ្នែក<br>▫ អង្គធាតុរាវ និងចំហាយអាចឆាបឆេះបាន<br>▫ គ្រោះថ្នាក់បើលេបចូល<br>▫ អាចបណ្ដាលឱ្យរលាកផ្លូវដង្ហើម<br>▫ បង្កឱ្យពុល ប្រសិនបើស្រូបចូលតាមដង្ហើម<br>▪ ផលិតផលនេះអាចឆេះដោយបង្កគ្រោះថ្នាក់៖ ការបែកធាតុនៃកាបូនម៉ូណូអុកស៊ីត (CO) កាបូនឌីអុកស៊ីត ($CO_2$) អ៊ីដ្រូសែននៅក្រោមលក្ខខណ្ឌនៃកំដៅ អាចបញ្ចេញឧស្ម័ន និងចំហាយដែលបង្កឱ្យរលាក។<br>▪ អង្គធាតុដែលងាយមានប្រតិកម្មអុកស៊ីតកម្ម។ ហានិភ័យនៃការឆេះ និងការផ្ទុះ នៅប៉ះជាមួយភ្នាក់ងារអុកស៊ីតកម្ម។ ងាយស្រូបយកចំហាយទឹក។ ងាយប្រែប្រួលក្រោមកំដៅ។ រលាយក្នុងទឹកនិងកាបូនឌីអុកស៊ីត។<br>▪ ត្រូវដាក់ឱ្យឆ្ងាយពីអណ្ដាតភ្លើង ផ្ទៃក្ដៅ និងប្រភពនៃការចំហេះ។ ជៀសវាងការប៉ះជាមួយខ្យល់ ឬទឹក។<br>▪ ការពិចារណាអំពីបរិស្ថាន<br>▫ ផ្សំដោយសារធាតុដែលបង្កគ្រោះថ្នាក់ដល់សារពាង្គកាយនៅក្នុងទឹក<br>▫ ងាយរលាយស្មើសាច់នៅក្នុងទឹក។ ផ្អែកលើព័ត៌មានដែលមាន វាពុំទំនងជាស្ថិតស្ថេរបានយូរឡើយ<br>▫ ទំនងជាអាចចរាចរណ៍បាននៅក្នុងបរិស្ថាន ដោយសារវាងាយរលាយក្នុងទឹក។ |

## ការរំងាប់មេរោគនៅក្នុងបរិវេណនៃកសិដ្ឋាន/ទ្រុងជ្រូក

- គួរយកសំណល់ចេញពីទ្រុងភ្លាមៗ ដើម្បីបង្កើនអនាម័យ និងភាពស្អាតនៅក្នុងបរិវេណនៃកសិដ្ឋាន។
- គួរមានការកំណត់កន្លែងណាមួយ ឱ្យឆ្ងាយពីទ្រុង តាមតែអាចធ្វើបាន ឬពីផុងសម្រាមប្រសិនបើមានទីធ្លាតូច ដើម្បីទុកដាក់សំណល់ជាបណ្ដោះអាសន្ន មុនយកទៅចោល។ បើអាចធ្វើបាន ចូរយកសំណល់ទៅចោលភ្លាមៗ ឬយ៉ាងហោចណាស់រៀងរាល់ព្រឹក។
- ត្រូវតែសម្អាត និងពិឃាតមេរោគក្នុងបរិវេណនៃកសិដ្ឋាន ជាមួយទ្រុងជ្រូក អាវជាប់ខោ ស្បែកជើងកវែង និងបរិក្ខារនានា ឱ្យបានទៀងទាត់។ តាមធម្មតាកសិករមានសំលៀកបំពាក់ធម្មតា នៅពេលចាត់ចែងសត្វ។
- បន្ទាប់ពីធ្វើការ កសិករគួរផ្លាស់ចេញ និងដាក់សំលៀកបំពាក់ការងារដែលប្រើរួច សម្រាប់បោកអ៊ុតជាបន្ទាន់។
- នៅពេលបាញ់ថ្នាំរំងាប់មេរោគ គួរទុកពេលឱ្យបានយូរសមស្រប ដើម្បីថ្នាំប៉ះជាមួយផ្ទៃនានាបានយូរ ដោយពិចារណាសីតុណ្ហភាពនៃទីជុំវិញ និងវិធានការសុវត្ថិភាព ដើម្បីធានាថាការរំងាប់មេរោគ ធ្វើឱ្យមេរោគលែងមានសកម្មភាព។
- ត្រូវតែយកចេញ និងទុកដាក់ចំណីដែលជ្រូកស៊ីមិនអស់ លាមកជ្រូក កម្រាលជ្រូកដេកឱ្យបានត្រឹមត្រូវ (សូមអានចំណុចទីពីរខាងលើ) ដោយសារវាអាចមានការចម្លងរោគក្នុងអត្រាខ្ពស់។ បើមិនដូច្នោះទេ វាអាចរំខានដល់ឥទ្ធិពលនៃថ្នាំកម្ចាត់មេរោគ។
- គួរយកបរិក្ខារដែលមាននៅក្នុងទីធ្លានានាដូចបានរៀបរាប់ខាងលើចេញមកក្រៅ ហើយសម្អាត និងធ្វើការរំងាប់មេរោគដាច់ដោយឡែក ។ ត្រូវលាងសម្អាតជាន់ក្រោមឱ្យហ្មត់ចត់ ជាមួយម្សៅសាប៊ូ បន្ទាប់មកធ្វើការរំងាប់មេរោគ។
- បង្វែរ និងបង្ហូរចំណីទាំងអស់ចេញពីក្បាលម៉ាស៊ីនផ្ដល់ចំណី ដើម្បីអាចសម្អាតផ្ទៃខាងក្រោមឱ្យបានត្រឹមត្រូវ។
- បើអាចធ្វើបាន ជាការល្អ គួរលាងសម្អាតឱ្យបានហ្មត់ចត់ជាមួយទឹកសាប៊ូក្ដៅនៅក្រោមសំពាធខ្យល់ មុនធ្វើការរំងាប់មេរោគ ដើម្បីយកសំណល់ចេញឱ្យអស់។ម្យ៉ាងវិញទៀត គេក៏អាចប្រើច្រាសដុសសម្អាតជាមួយសាប៊ូ និងទឹកផងដែរ។
- ត្រូវប្រើថ្នាំរំងាប់មេរោគសមស្រប លើគ្រប់ឧបករណ៍ និងផ្ទៃទាំងអស់ដែលជ្រូកអាចប៉ះ។
- ត្រូវទុកពេលឱ្យបានគ្រប់គ្រាន់ រវាងការលាងសម្អាត និងការរំងាប់មេរោគក្នុងបរិវេណនានា មុនបញ្ចូលជ្រូកថ្មី។ ក្នុងអំឡុងពេលទុកឱ្យស្ងួត ការប្រើពន្លឺព្រះអាទិត្យធម្មជាតិ អាចជួយបង្កើនការកំចាត់មេរោគដែលមានក្នុងក្រហែងសើម និងងងឹត។
- ការលាងសម្អាត បោកគក់សម្លៀកបំពាក់កសិដ្ឋាន និងការលាងស្បែកជើងកវែង គួរតែបានធ្វើជាប្រក្រតី ដើម្បីកំចាត់ស្នាមប្រឡាក់ ដែលអាចជាកំណកឈាម លាមក ទឹករំអិលពីជ្រូកជាដើម។

- ត្រូវតែលាងសម្អាត និងរំងាប់មេរោគលើគ្រឿងបរិក្ខារទាំងអស់ដែលប្រើចំពោះសត្វឈឺ និងសត្វក្នុងចត្តាឡីស័ក មុនពេលប្រើលើហ្វូងជ្រូកដែលមានសុខភាពល្អ។

## អាងទឹកថ្នាំលាងជើង

- កសិករត្រូវលាងសម្អាតស្បែកជើងកវែងឱ្យបានស្អាត និងកម្ចាត់សារធាតុសរីរាង្គទាំងអស់ មុនដាក់ជើងចូលក្នុងអាងសូលុយស្យុងរំងាប់មេរោគ នៅពេលដើរចូលក្នុងបរិវេណនៃកសិដ្ឋាន។ តាមធម្មតា ការត្រាំជើង ៥នាទី ក្នុងអាងទឹកថ្នាំ អាចគ្រប់គ្រាន់ដើម្បីធ្វើឱ្យវីរុសលែងមានសកម្មភាព។
- កសិករ និងកម្មកររបស់ពួកគេ ត្រូវតែជៀសវាងការត្រាំជើងក្នុងអាងថ្នាំឆាប់ពេក ហើយចាកចេញភ្លាមៗ (ការរាប់ថយក្រោយពី ៦០ រហូតដល់ ១ នៅពេលត្រាំជើងក្នុងអាងទឹកថ្នាំ អាចជាវិធីជាក់ស្តែងមួយ ដើម្បីកំណត់រយៈពេល អប្បបរមាសម្រាប់ត្រាំជើងក្នុងអាងទឹកថ្នាំ នៅពេលចូលក្នុងបរិវេណកសិដ្ឋាន)។ ក្នុងកសិដ្ឋានលក្ខណៈគ្រួសារជាច្រើន ការចាត់ចែងអាងទឹកថ្នាំ អាចធ្វើឡើងមិនបានត្រឹមត្រូវ។
- ប្រសិនបើ មិនអាចដាក់អាងទឹកថ្នាំឱ្យដំណើរការបានត្រឹមត្រូវទេនោះ ចូរប្តូរស្បែកជើងនៅត្រង់ច្រកចូលទ្រុងជ្រូក។ នីតិវិធីសម្រាប់ការប្រើអាងទឹកថ្នាំ មានជាអាទិ៍៖
  - ជៀសវាងការប្រើស្បែកជើងកវែងដែលធ្លុះធ្លាយ។
  - ត្រូវដាក់សញ្ញាសម្គាល់ និងពង្រឹងការអនុវត្តកន្លែងស្អាត និងកន្លែងកខ្វក់នៅជុំវិញអាងទឹកថ្នាំ។ និង
  - លាងសម្អាតសារធាតុសរីរាង្គចេញពីស្បែកជើងកវែង មុនពេលដាក់ជើងចូលទៅក្នុងអាងទឹកថ្នាំ (ដោយប្រើច្រាស់ និងទឹក)។ ការធ្វើបែបនេះអាចជួយគ្រប់គ្រងការចំណាយ ព្រោះអាចពុំចាំបាច់ប្តូរទឹកថ្នាំពិឃាតមេរោគញឹកញាប់ពេក។



## ការរំងាប់មេរោគលើឡានដឹកទំនិញ/យានយន្ត/រ៉ឺម៉ក/ម៉ូតូ

យានយន្ត ឡានដឹកទំនិញ និងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត សម្រាប់ដឹកចំណី កម្រាលសត្វដេក ជ្រូករស់។ល។ រួមជាមួយ អ្នកបើកបរ គឺជាប្រភពហានិភ័យនៃការបញ្ចូល ASFV ទៅក្នុងកសិដ្ឋានជាគោលដៅ។ យានយន្តទាំងនេះអាចជាកម្មសិទ្ធិឯកជន ឬ យានជំនិះដែលកំពុងដំណើរការពាណិជ្ជកម្ម។ គ្រោះថ្នាក់កើតឡើង នៅពេលដែលយានយន្តទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនសម្ភារៈផ្គត់ផ្គង់ផ្សេងៗរវាងកសិដ្ឋាននានា។ នីតិវិធីលាងសម្អាត និងរំងាប់មេរោគសម្រាប់មធ្យោបាយដឹកជញ្ជូនផ្សេងៗគ្នា មានជាអាទិ៍៖

- មធ្យោបាយដឹកជញ្ជូនទាំងអស់ដែលចូលមកកសិដ្ឋាន ត្រូវតែផ្ទុក និងផ្ទេរទំនិញ នៅឆ្ងាយសមរម្យពីបរិវេណកសិដ្ឋាន។
- បើអាចធ្វើបាន ត្រូវកំណត់កន្លែងដែលមានផ្ទៃបាតរឹងខាងក្រៅកសិដ្ឋាន ជាកន្លែងសម្រាប់សម្អាតសម្រាប់យានយន្ត និងឧបករណ៍ទាំងអស់ដែលត្រលប់មកពីក្រៅវិញ ប្រសិនបើជាកម្មសិទ្ធិឯកជន។
- គួរលើកទឹកចិត្តដល់ម្ចាស់យានយន្តពាណិជ្ជកម្មឱ្យរំងាប់មេរោគនៅលើកង់យានយន្តទាំងនោះ រវាងកសិដ្ឋាននានា ដោយប្រើ ថ្នាំបាញ់ពិឃាតមេរោគសមស្រប។
- រាល់យានយន្តឯកជនទាំងអស់ ដែលត្រូវចតនៅកន្លែងដែលបានកំណត់របស់គ្រួសារ និងឧបករណ៍ដែលនាំយកមកជាមួយ ត្រូវតែបានសម្អាត លាង និងរំងាប់មេរោគឱ្យបានត្រឹមត្រូវ និងទុកឱ្យស្ងួត នៅក្នុងចន្លោះពេលប្រើប្រាស់។
- ផ្នែកនានានៃយានយន្ត ដែលប៉ះពាល់ជាមួយជ្រូករស់ នៅក្នុងអំឡុងពេលដឹកជញ្ជូនត្រូវតែបានសម្អាតឱ្យស្អាតដែលរួមទាំង កង់រថយន្ត ផ្ទៃខាងក្រោម និងកៀនកោះនានាផងដែរ។
- មិនត្រូវអនុញ្ញាតឱ្យសមាជិកគ្រួសារ ឬអ្នកថែទាំដែលធ្វើការសម្អាត និងរំងាប់មេរោគចូលធ្វើការក្នុងទ្រុងជ្រូកទេ។ ប្រសិនបើមិនអាចជៀសវាងបាន កម្មករនោះត្រូវបោកខោអាវប្តូរសម្លៀកបំពាក់ និងរំងាប់មេរោគមុនចូលទ្រុងជ្រូក។
- ការសម្អាតផ្នែកខាងក្នុងនៃយានយន្តដឹកជញ្ជូន អាចជួបការលំបាក។ កសិករអាចពិចារណាប្រើកម្រាលផ្លាស្ទិកដែលងាយស្រួលសម្អាត លាង និងសម្ងួត។ ត្រូវប្រើថ្នាំពិឃាតមេរោគដែលសមស្រប ដោយគិតគូរពីសម្ភារៈ ប្រភេទ និងរន្ធ/ប្រហោងលើតួរថយន្ត ឧ. ផ្ទៃឈើ ដែក ឬផ្លាស្ទិច។
- កសិករលក្ខណៈគ្រួសារ អាចមិនសុទ្ធតែមានសិទ្ធិស្នើសុំម្ចាស់យានយន្តដឹកជញ្ជូនឱ្យសម្អាត និងរំងាប់មេរោគលើយានយន្តទាំងនោះ មុនពេលមកដល់កសិដ្ឋានឡើយ។ ទោះជាយ៉ាងនេះក្តី មេភូមិ អាចប្រាប់ពីនីតិវិធីចាំបាច់ សម្រាប់ការសម្អាត និងរំងាប់មេរោគ នៅតំបន់ភូមិដែលបានកំណត់ ដែលមានកសិករលក្ខណៈគ្រួសារនៅក្នុងភូមិនោះ (រូបភាពទី ១០ និង១១)។ ដោយសារភូមិមួយ មានគ្រួសារជាច្រើនចិញ្ចឹមជ្រូក មេភូមិអាចចាត់ចែងឱ្យមានវិធីសាស្ត្ររួមមួយ ដោយអាចស្នើឱ្យឈ្មួញលក់ជ្រូក និងក្រុមសម្ព័ន្ធមិត្តផ្សេងទៀត ចូលរួមនៅក្នុងការអនុវត្តវិធានការជីវសុវត្ថិភាពងាយៗ។




© FAO & GDAHP

## នីតិវិធីសំអាតយានយន្ត

### ជំហានទី ១

ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួនដែលសមរម្យ (ខោជាប់អាវ របាំងការពារភ្នែក ស្បែកជើងកវែង និងស្រោមដៃ)។



### ជំហានទី ២

កោស និងយកប្រាសដុសផ្ទៃខាងក្នុង និងខាងក្រៅរថយន្ត រួមទាំងផ្ទៃបាត ពិដាន ជញ្ជាំង ចំហៀងនិងច្រកទ្វារ ខណ្ឌចែក។



### ជំហានទី ៣

កោសនិងយកប្រាសដុសផ្ទៃនៃកន្លែងផ្ទុកទំនិញ / ឧបករណ៍ / ទ្រុង (ប្រសិនបើមាន)។



### ជំហានទី ៤

យកដីភក់ ចំបើងជាដើមចេញពីកង់ ផ្ទៃកោងលើកង់ គម្របភក់ និងឆ្អឹងតួរថយន្ត។



# ការលាងជាមួយសាប៊ូ និងទឹកនៅក្រោមសម្ពាធខ្ពស់

## ជំហានទី ១

សម្អាតផ្នែកខាងក្រៅ ចាប់ពីលើចុះក្រោម ដោយយកចិត្តទុកដាក់លើកង់ ផ្នែកកោងលើកង់ និងគម្របភក់។



## ជំហានទី ២

លាងសម្អាតផ្ទៃខាងក្នុង និងខាងក្រៅនៃយានយន្ត រួមទាំង ផ្ទៃបាតពិដាន ជញ្ជាំងចំហៀង និងទ្វារខណ្ឌចែក។



## ជំហានទី ៣

លាងសម្អាតកន្លែងផ្ទុក / បរិក្ខារ (ប្រសិនបើមាន)។



## ជំហានទី ៤

លាងសម្អាតបរិក្ខារ និងឧបករណ៍ទាំងអស់លើយានយន្ត។



## ជំហានទី ៥

ប្រើសាប៊ូដើម្បីលាងសម្អាតយានយន្ត ហើយទុកឱ្យស្ងួត យ៉ាងតិច ២០នាទី។




## ជំហានទី ៦

លាងជម្រះផ្ទៃ និងបរិក្ខារទាំងអស់ ដោយប្រើទឹកស្អាត (គួរប្រើទឹកនៅក្រោមសម្ពាធខ្ពស់ ប្រសិនបើអាចធ្វើបាន)។



## ជំហានទី ៧

ពិនិត្យផ្ទៃខាងក្នុង និងខាងក្រៅទាំងអស់ដើម្បីធានាថាបានសម្អាតយ៉ាងហ្មត់ចត់។



# នីតិវិធីរំងាប់មេរោគលើយានយន្ត

## ជំហានទី ១

ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួនដែលសមរម្យ (ខោជាប់អាវ របាំងការពារភ្នែក ស្បែកជើងកវែង និងស្រោមដៃ)។



## ជំហានទី ២

សម្អាតផ្នែកខាងក្រៅពីលើចុះក្រោម ដោយយកចិត្តទុកដាក់លើកង់ ផ្ទៃកោងលើកង់ និងគម្របកក់ និងផ្នែកខាងក្រោមរថយន្ត។



## ជំហានទី ៣

នៅខាងក្នុង ចាប់ផ្តើមពីដាន់ខាងលើ ហើយបន្តចុះក្រោម រម្ងាប់មេរោគលើពិដាន ជញ្ជាំងចំហៀង របាំងខណ្ឌ ផ្ទៃបាត និងទ្វារក្រោយ



## ជំហានទី ៤

រំងាប់មេរោគលើឧបករណ៍ និងបរិក្ខារទាំងអស់លើយានយន្ត។



# ការរំងាប់មេរោគលើទ្រុងឡាន និងជំហានចុងក្រោយ

## ជំហានទី ១

យកកន្ទេលចេញ និងយកច្រាសដុសកំទេចកំទី និងសារធាតុសរីរាង្គ បញ្ចូលទៅក្នុងបាវ ដើម្បីយកទៅចោល។



## ជំហានទី ២

លាងសម្អាតផ្ទៃបាតនៃទ្រុងឡាន កម្រាល និងឈ្នាន់រថយន្ត។



## ជំហានទី ៣

ប្រើក្រណាត់ស្អាត ជ្រលក់ទឹកថ្នាំពិឃាតមេរោគ រម្ងាប់មេរោគលើផ្ទៃបាត កម្រាល និងឈ្នាន់រថយន្ត។



## ជំហានទី ៤

ចតយានយន្តនៅលើជម្រាលដើម្បីបង្ហូរទឹកឱ្យអស់ និងទុកឱ្យស្ងួត។



## ជំហានទី ៥

ក្រោយយករថយន្តចេញហើយ ត្រូវលាងសម្អាតកំទេចកំទីដែលនៅសល់ក្នុង
កន្លែងនោះ។



## ជំហានទី ៦

រំងាប់មេរោគលើអាវជាប់ខោ និងស្បែកជើងកវែង។



## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **ការនាំចូល/ដាក់ចូលជ្រូកថ្មីៗ** | | | | | | |
| ទទួលបានជ្រូកជំនួសពីប្រភពដែលទុកចិត្តបានថាគ្មាន ASF។ | +++ | +++ | ++ | $$$ | -- | +++ |
| លាងសម្អាត និងរំងាប់មេរោគលើយានយន្តនិងអ្នកបើកបរ មុន និងក្រោយពេលដឹកជញ្ជូនជ្រូក | +++ | ++ | ++ | $$$ | -- | ++ |
| កំណត់កន្លែងសម្រាប់ផ្ទុក និងផ្ទេរទំនិញ | ++ | ++ | + | ∅ | - | + |
| ដាក់ជ្រូកថ្មីក្នុងទ្រុងផ្សេង | +++ | +++ | + | $ | - | ++ |

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការ ជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុង ការកាត់បន្ថយហានិភ័យ | រយៈពេល/ ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការ អនុវត្តបានឆាប់រហ័ស និងងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខាន ចំពោះផលិតកម្ម | កម្រិតនៃការទទួលយក ពាននៅម្ចាស |
| គ្មានការបញ្ចូលជ្រូកថ្មីរហូតដល់ផុតរយៈពេលបត្តាឡីស័ក | ++ | + | + | $$ | --- | + |
| កំហិតលើភាពញឹកញាប់នៃការបញ្ចូលជ្រូកថ្មីៗ | ++ | + | + | $ | --- | + |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូក លក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **ចំណី និងទឹក** | | | | | | |
| រារាំងសត្វកកេរមិនឱ្យចូលមកកន្លែងទុកដាក់ចំណី | + | + | ++ | $$ | – | +++ |
| ជៀសវាងធ្លាយ/កំពប់ចំណី/សម្អាតកន្លែងកំពប់ភ្លាមៗ | + | + | +++ | ∅ | – | +++ |
| ហាលចំណីក្រោមកំដៅព្រះអាទិត្យ | ++ | ++ | + | ∅ | – | ++ |
| ប្រើតែចំណីពីប្រភពដែលទុកចិត្តបាន | ++ | + | + | $ | ––– | + |
| ប្រគល់ចំណីនៅកន្លែងដែលបានកំណត់ទុកជាមុន | ++ | ++ | +++ | $ | – | + |

# ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូក លក្ខណៈគ្រួសារ (ត)

| វិធានការ ជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុង ការកាត់បន្ថយហានិភ័យ | រយៈពេល/ ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការ អនុវត្តបានទាប់ប៉ះស់ និងងាយយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខាន ចំពោះផលិតកម្ម | កម្រិតនៃការទទួលយក ពានទៅអ្នកផ្សេង |
| **ចំណី និងទឹក** | | | | | | |
| ចៀសវាងផ្តល់ ចំណីកាក សំណល់ផ្ទះបាយ ឬត្រូវចំអិន យ៉ាងតិច៣០នាទី | +++ | +++ | + | $ | – | ++ |
| បង្ខាំងសត្វជ្រូក និងបង្ការពីការ ប្រលែងសេរី | +++ | +++ | +++ | $$ | – | +++ |
| ធានាមានទឹក ស្អាតប្រើប្រាស់ គ្របធុងទឹក និង dfrរក្សាទឹកទុក | ++ | ++ | +++ | $ | – | ++ |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្ដែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្ដានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្ដានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្ដានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **កម្រាលទ្រុង** | | | | | | |
| ទុកកម្រាលឱ្យឆ្ងាយពីបរិយាកាសខាងក្រៅ | ++ | ++ | +++ | ø | – | ++ |
| ជានាប្រភពដើមនៃកម្រាលសម្រាប់សត្វគ្មាន ASF | +++ | ++ | ++ | $ | – | + |
| **យានយន្ត និងបរិក្ខារ** | | | | | | |
| ផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក | +++ | +++ | ++ | $$$ | – | ++ |
| ធានាថា អ្នកបើកបរអនុវត្តតាមវិធានការជីវសុវត្ថិភាព | +++ | +++ | ++ | $$ | –– | ++ |

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| សម្អាត និងរំងាប់មេរោគលើយានយន្ត ម៉ូតូ និងរទេះ | +++ | +++ | ++ | $$ | −− | ++ |
| ជៀសវាងការប្រើឧបករណ៍ និងបរិក្ខាររួមគ្នារវាងកសិដ្ឋាន | +++ | +++ | +++ | $ | − | ++ |
| កំណត់កន្លែងសម្រាប់សម្អាតនិងរំងាប់មេរោគលើយានយន្ត និងឧបករណ៍នានា | ++ | ++ | ++ | $ | − | ++ |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **ការប្រគល់ និងផ្គត់ផ្គង់សម្ភារៈ** | | | | | | |
| រំងាប់មេរោគលើគ្រប់សម្ភារៈផ្គត់ផ្គង់នៅត្រង់ចំណុចប្រគល់/ទទួលសមស្រប | +++ | +++ | ++ | $$ | – | ++ |
| ការកំណត់ព្រំដែនសមស្របសម្រាប់ការមកដល់នៃសម្ភារៈការផ្គត់ផ្គង់សម្រាប់កសិដ្ឋាន | ++ | ++ | +++ | $ | – | ++ |
| សម្អាត និងរំងាប់មេរោគលើឧបករណ៍ និងបរិក្ខារប្រើប្រាស់ដោយបុគ្គលិកសេវាកម្មចូលក្នុងកសិដ្ឋាន | +++ | ++ | ++ | $$ | – | ++ |

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូក លក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **បុគ្គលិក និងការបណ្តុះបណ្តាល** | | | | | | |
| គ្រប់គ្រងការចរាចរណ៍នៃបុគ្គលិក | +++ | ++ | ++ | $ | – | ++ |
| វត្តមានស្លាកសញ្ញាច្បាស់លាស់ជាមួយសារណែនាំអំពីជីវសុវត្ថិភាពសមស្រប | +++ | +++ | +++ | $ | – | ++ |
| ទិសនៃចរន្តការងារសម្រាប់អ្នកមើលថែ និងកម្មករ | +++ | +++ | ++ | $ | – | + |
| ផ្តល់អាងទឹកថ្នាំនៅច្រកចូល កសិដ្ឋាន និងមាត់ទ្រុងជ្រូក | +++ | +++ | ++ | $$$ | – | ++ |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| ដាក់គោលការណ៍ណែនាំដល់អ្នកប្រមូលទិញ និងឈ្មួញកណ្តាល | +++ | +++ | + | $$ | −− | ++ |
| ធានានូវការស្លៀកពាក់ និងបោកគក់សមរម្យសម្រាប់កម្មករមុនពេលចូលកសិដ្ឋាន | +++ | +++ | ++ | $$ | − | ++ |
| ធានាផ្តល់ការបណ្តុះបណ្តាលអំពីការសម្អាត និងរំងាប់មេរោគដល់កសិករ និងកម្មករ | +++ | +++ | ++ | $$$ | −− | ++ |

**សត្វព្រៃ សត្វល្អិត និងការបរបាញ់**

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| មានវិធានការដើម្បីគ្រប់គ្រងចៃឆ្កែតុកកែនៅក្នុងកសិដ្ឋាន | ++ | ++ | + | $$$ | –– | + |
| វិធានការគីមីដើម្បីត្រួតពិនិត្យចៃតុកកែ | ++ | +++ | + | $$$ | –– | + |
| រក្សាអនាម័យល្អក្នុងបរិវេណកសិដ្ឋាន | +++ | +++ | ++ | $ | – | ++ |
| វិធានការរក្សាបក្សីនិងសត្វចិញ្ចឹមឆ្ងាយពីទ្រុងជ្រូក | +++ | +++ | ++ | $ | –– | + |
| វិធានការដើម្បីឱ្យអ្នកប្រមាញ់ រង់ចាំយ៉ាងហោចណាស់ ៤៨ ម៉ោង មុនពេលប៉ះពាល់ជ្រូក | +++ | +++ | ++ | $ | – | ++ |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង

## ៣.១០ វិធានការជីវសុវត្ថិភាពសំខាន់ៗអនុវត្តចំពោះ ASF សម្រាប់ប្រព័ន្ធចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ត)

| វិធានការជីវសុវត្ថិភាព | ប្រសិទ្ធភាព | | លទ្ធភាព/ភាពជាក់ស្តែង | | និរន្តរភាព | |
|---|---|---|---|---|---|---|
| | សក្តានុពលនៃឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យ | រយៈពេល/ភាពយូរអង្វែងនៃឥទ្ធិពល | សក្តានុពលសម្រាប់ការអនុវត្តបានឆាប់រហ័ស និងដោយងាយ | ថ្លៃអនុវត្ត | សក្តានុពលក្នុងការរំខានចំពោះផលិតកម្ម | កម្រិតនៃការទទួលយកបាននៅមូលដ្ឋាន |
| **ការគ្រប់គ្រងលាមកសត្វ** | | | | | | |
| វិធានការគ្រប់គ្រងលាមកសត្វឱ្យបានសមស្រប | +++ | +++ | ++ | $ | – | ++ |
| បង្កើតផែនការឡជីវឧស្ម័នដើម្បីគ្រប់គ្រងលាមកសត្វ | +++ | +++ | + | $$ | – | ++ |
| ការសម្អាត និងរំងាប់មេរោគឱ្យបានត្រឹមត្រូវលើយានយន្តដែលប្រើសម្រាប់ដឹកជញ្ជូនលាមកសត្វ | +++ | +++ | ++ | $$$ | – | ++ |

+++ ឥទ្ធិពលវិជ្ជមានខ្លាំង ++ ឥទ្ធិពលវិជ្ជមានមធ្យម + ឥទ្ធិពលវិជ្ជមានខ្សោយ
- ឥទ្ធិពលអវិជ្ជមានខ្សោយ -- ឥទ្ធិពលអវិជ្ជមានមធ្យម --- ឥទ្ធិពលអវិជ្ជមានខ្លាំង
$$$ ចំណាយខ្ពស់ $$ ចំណាយមធ្យម $ ចំណាយទាប ø ចំណាយអប្បបរមា ? មិនដឹង


© FAO/R. Willis

# ៤ ជីវសុវត្ថិភាពក្នុងអំឡុងពេល ផ្ទុះជំងឺ (សម្រាប់មន្ត្រីបសុពេទ្យ)

វិធានជីវសុវត្ថិភាព មានសារៈសំខាន់ក្នុងការគ្រប់គ្រងស្ថានភាពផ្ទុះជំងឺ ASF (USDA & CFSPH, 2016)។ ក្នុងករណីខ្លះ វិធានការដែលបានប្រើប្រាស់ អាចជាផ្នែកមួយនៃផែនការជាតិ ដែលមានគោលដៅលុបបំបាត់ក្នុងករណីនៃការផ្ទុះជំងឺ។ ការឆ្លើយតបនឹងការផ្ទុះជំងឺ ASF អាចតម្រូវឱ្យធ្វើការនៅក្នុងបរិវេណនៃកន្លែងដែលឆ្លងមេរោគ ដែលប៉ះពាល់ ឬដែលមិនប៉ះពាល់ជាមួយមេរោគ ASFV នៅក្នុងប្រទេស ឬតំបន់ណាមួយ ដូច្នេះប្រការសំខាន់គឺ បុគ្គលិកដែលធ្វើការឆ្លើយតបត្រូវប្រុងប្រយ័ត្នដើម្បីបញ្ចៀសការចម្លងមេរោគ។ នៅគ្រប់ស្ថានភាពទាំងអស់ វិធានការជីវសុវត្ថិភាពដែលប្រើប្រាស់ សុទ្ធតែមានបំណង ការពារការរាតត្បាតមេរោគ ASFV នៅក្នុងបរិវេណដែលមានមេរោគ ទន្ទឹមនឹងទប់ស្កាត់ការរាលដាលជាបន្តទៅកន្លែងដែលគ្មានការឆ្លងមេរោគ (USDA & CFSPH, 2016)។

តំបន់ភូមិសាស្ត្រណាមួយ អាចត្រូវបានចាត់ទុកថា មានមេរោគ ឬមិនឆ្លង និងមានការចាត់វិធានការត្រួតពិនិត្យ ប្រសិនបើកសិដ្ឋានណាមួយ នៅក្នុងតំបន់នោះមានឆ្លងមេរោគ (USDA & CFSPH, 2016)។ ក្រោយមានរបាយការណ៍ និងការកំណត់អត្តសញ្ញាណនៃការផ្ទុះជំងឺ វិធានការអង្កេតដានអាចអនុញ្ញាតឱ្យមានការកំណត់ភ្លាមៗនូវបរិវេណនៃកន្លែង'ឆ្លង' និង'ប៉ះពាល់ដ៏គ្រោះថ្នាក់'។ ការអង្កេតតាមដាន គួរតែអាចកំណត់អត្តសញ្ញាណគ្រប់ការចរាចរណ៍ជ្រូក និងផលិតផលសាច់ជ្រូកទៅ និងមកពីកន្លែងឆ្លងមេរោគ ហើយតាមធម្មតា ត្រូវតាមដានរយៈពេល ៣០ថ្ងៃចុងក្រោយ (FAO, 2009; USDA & CFSPH 2016)។ ប្រទេសនីមួយៗ អាចអនុវត្តតាមផែនការជាតិឆ្លើយតបនឹង ASF របស់ខ្លួន ប្រសិនបើមាន។ ទោះជាយ៉ាងណាក៏ដោយ វិធានការជីវសុវត្ថិភាពដែលយកមកអនុវត្ត ត្រូវតែរៀបចំឡើងឱ្យស្របតាមឯកត្តាផលិតកម្មជ្រូកលក្ខណៈគ្រួសារ ដោយគិតគូរពីផ្លូវហានិភ័យនៅតាមខ្សែសង្វាក់តម្លៃសាច់ជ្រូកទាំងមូល។ ការសម្អាត និងរំងាប់មេរោគ គឺជាជំហានដ៏សំខាន់នៅក្នុងវិធានការជីវសុវត្ថិភាពជាក់ស្តែងដែលប្រើប្រាស់ក្នុងអំឡុងពេលមានការផ្ទុះជំងឺ។




## ៤.១ ការកំណត់អត្តសញ្ញាណបរិវេណ ឬ តំបន់មានមេរោគ

បន្ទាប់ពីបានកំណត់អត្តសញ្ញាណបរិវេណនៃកន្លែងឆ្លងមេរោគនៅក្នុងការផ្ទុះជំងឺ ASF រួចមកកិច្ចប្រឹងប្រែង និងវិធានការត្រួតពិនិត្យទាំងអស់ត្រូវផ្តោតលើទីតាំងទាំងនេះ នៅក្នុងកិច្ចប្រឹងប្រែងការពារការរាតត្បាតឱ្យបានឆាប់រហ័ស (FAO, 2009)។ បទពិសោធន៍ពីប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារនៅអឺរ៉ុប និងអាស៊ីបច្ចុប្បន្ននេះបានបង្ហាញថា ប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារអាចរងគ្រោះពីការរាលដាល ASFV។ ដូច្នេះការយកចិត្តទុកដាក់គួរផ្តោតជាពិសេសលើប្រព័ន្ធផលិតកម្មទាំងនេះក្នុងអំឡុងពេលផ្ទុះជំងឺ។ អាស្រ័យលើស្ថានភាពជាក់លាក់នៃ ASF នៅក្នុងប្រទេស ការលុបបំបាត់ ASF នៅក្នុងបណ្តាប្រទេសដែលមានកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារជាច្រើន ប្រហែលមិនអាចធ្វើទៅបានឡើយ។ ដូច្នេះ ប្រទេសនានាត្រូវបង្កើតវិធានការត្រួតពិនិត្យជាក់លាក់សម្រាប់ប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារ បន្ថែមលើវិធានការអនាម័យដែលមានស្រាប់ ដែលជាផ្នែកមួយនៃផែនការជាតិយថាភាពសម្រាប់ ASF នៃប្រទេសទាំងនោះ។ អនុសាសន៍ជីវសុវត្ថិភាពសំខាន់ខ្លះៗដែលត្រូវគោរពតាម នៅក្នុងអំឡុងនៃការផ្ទុះជំងឺយ៉ាងសកម្មសម្រាប់មន្ត្រីបសុពេទ្យ និងមន្ត្រីតាមមូលដ្ឋាន មានជាអាទិ៍៖

- វិធានការតឹងរ៉ឹងនៅកន្លែងឆ្លងមេរោគ និងតំបន់ជុំវិញកសិដ្ឋាន គួរផ្តោតលើប្រព័ន្ធលក្ខណៈគ្រួសារ ជាពិសេសលើការទប់ស្កាត់ការប៉ះពាល់ជាមួយជ្រូកប្រលែងសេរី និងជ្រូកព្រៃ។
- ប្រការចាំបាច់គឺត្រូវត្រួតពិនិត្យជ្រូកដើររកស៊ីសេរីមុនពេលមានការផ្ទុះជំងឺ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីមានការផ្ទុះឡើងជាបន្តបន្ទាប់ ត្រូវធ្វើការបញ្ចុះបញ្ចូលឱ្យកសិករបង្ខាំងជ្រូករបស់ខ្លួន។

- នៅកសិដ្ឋានដែលខ្វះកន្លែងរក្សាទុកជ្រូក វិធីសាស្ត្រដាក់ស្តែង និងសមស្រប អាចជាការចងជ្រូកមិនឱ្យចេញដើរសេរី។ នេះជាចំណុចសំខាន់ ដើម្បីទប់ស្កាត់ការប៉ះពាល់ជាមួយជ្រូករកស៊ីសេរី ជ្រូកព្រៃ និងចៃតុកកែ។ កសិដ្ឋានលក្ខណៈគ្រួសារ ដែលមានរបងហ៊ុមព័ទ្ធ គួរត្រួតពិនិត្យរបងរបស់ខ្លួន នៅក្នុងអំឡុងពេលមានការផ្ទុះជំងឺ។
- ប្រសិនបើកសិករលក្ខណៈគ្រួសារមានលទ្ធភាពកែលម្អស្ថានភាពកសិដ្ឋានរបស់ខ្លួន គួរសង់របងជាពីរត្រួតដើម្បីបង្ការជ្រូករកសេរីសេរី។ កសិករផ្សេងទៀតដែលមានសំណង់រឹងមាំពីបេតុង ឬ ឈើ អាចប្រើរបងត្រឹមតែមួយជាន់។
- ត្រូវដាក់ឱ្យអនុវត្តវិធានការអនាម័យសម្រាប់បរិវេណកន្លែងចិញ្ចឹមតូចៗ នៅក្នុងអំឡុងពេលផ្ទុះជំងឺ ដូចជា៖
    - ធ្វើការការសម្អាត និងការរំងាប់មេរោគឱ្យកាន់តែញឹកញាប់
    - បង្ខាំងសត្វជ្រូកក្នុងស្រុកដែលគ្មានទ្រុងសមស្រប និងដែលរកស៊ីសេរី និង
    - ហាមបញ្ចូលជ្រូកថ្មី។

### ៤.១.១ ការបែងចែកជាតំបន់ដាច់គ្នា

តំបន់មួយ សំដៅលើផ្នែកមួយនៃប្រទេស ឬដែនដី ដែលកត់សម្គាល់ដោយព្រំដែនធម្មជាតិ ឬរដ្ឋបាល ដែលមន្ត្រីបសុពេទ្យបានកំណត់ចំនួនសត្វ ដែលអាចបង្កឱ្យមានបញ្ហាជាក់លាក់ចំពោះស្ថានភាពសុខភាពដែលទាក់ទងនឹងជំងឺណាមួយ (ឧទាហរណ៍ ASFV) ក្នុងបំណងបង្ការ គ្រប់គ្រង ឬធ្វើពាណិជ្ជកម្មអន្តរជាតិ (OIE, 2019a)។ ក្នុងអំឡុងពេលផ្ទុះជំងឺ ASF តំបន់ភូមិសាស្ត្រដែលបានកំណត់ព្រំដែនថាជាកន្លែងដែលមានមេរោគ ត្រូវចាត់ទុកថាជា តំបន់ឆ្លងដោយត្រូវមានវិធានការហ៊ុមព័ទ្ធខ្លាំងក្លា (FAO, 2009; OIE, 2019a)។ តាមធម្មតា តំបន់ឆ្លងមេរោគលាតសន្ធឹងក្នុងវិសាលភាពជាក់លាក់ ដោយគិតចាប់ពី កន្លែងដែលសង្ស័យថាមានការឆ្លង ឬអាចកំណត់បាន ដោយឯកត្តាគោលនៃអេពីដេមីសាស្ត្រដែលជាភូមិណាមួយ ដែលមានការឆ្លងជំងឺ។ តាមធម្មតា គេអាចធ្វើបែបនេះបាន ដោយត្រួតផែនទីតំបន់ឆ្លងមេរោគលើគ្នាជាពិសេស ប្រសិនបើវាលាតសន្ធឹងហួសពីព្រំប្រទល់ក្រុងណាមួយផ្សេងទៀត។

ព្រំដែនរដ្ឋបាល ឬវិធានការពាក់ព័ន្ធផ្សេងទៀតជំងឺរាតត្បាត អាចត្រូវបានប្រើប្រាស់ក្នុងការកំណត់វិសាលភាពនៃតំបន់ផងដែរ (OIE, 2019a)។ វិធានការត្រួតពិនិត្យជាក់ស្តែងនៅក្នុងតំបន់ដែលមានមេរោគបែបនេះគួរផ្តោតលើផ្លូវដែលមានសកម្មភាពមមាញឹកនៅជិតសត្តឃាតដ្ឋាន តំបន់ដែលមានដង់ស៊ីតេជ្រូកខ្ពស់ ផ្លូវធំៗ និងផ្លូវរថភ្លើង។ នៅក្នុងប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារគេអាចមិនគ្រាន់តែកំណត់តំបន់ដែលមានមេរោគប៉ុណ្ណោះទេ ព្រោះថា កសិករ និងឈ្មួញកណ្តាលអាចនៅតែជាប់ពាក់ព័ន្ធក្នុងការចរាចរណ៍ដោយល្មើសច្បាប់ជួញដូរជ្រូក និងផលិតផលជ្រូកដែលឆ្លងមេរោគ (USDA & CFSPH, 2016)។ មន្ត្រីបសុពេទ្យត្រូវធ្វើទំនាក់ទំនងជាមួយមន្ត្រីមានសមត្ថកិច្ចក្នុងប្រទេស ដើម្បីពង្រឹងកិច្ចប្រឹងប្រែងការពារការរាតត្បាតជំងឺ។

ប្រសិនបើ មន្ត្រីយោធា/ប៉ូលីសត្រូវធ្វើការល្បាតផ្លូវដែលមិនធ្លាប់ប្រើប្រាស់ ជាពិសេសផ្លូវលំតូចៗ។ ការដាក់របាំងបិទផ្លូវ ការបិទផ្លូវជាបណ្ដោះអាសន្ន និងការត្រួតពិនិត្យយានយន្តកាន់តែខ្លាំងក្លា អាចកាត់បន្ថយភាពញឹកញាប់នៃការលក់ ការពិឃាត និងការដឹកជញ្ជូនដោយសារភាពស្លន់ស្លោ ក្នុងករណីមានការផ្ទុះជំងឺ ASF។ វិធានការទាំងនេះ អាចឱ្យកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ បញ្ឈប់ការរាលដាល ASF ដោយជោគជ័យ។ ស្ថានភាពនៃការផ្ទុះជំងឺ និង និយមន័យនៃការផ្ទុះជំងឺ មានបង្ហាញក្នុងតារាងទី ១។

មធ្យោបាយងាយៗដូចជា សញ្ញាសម្គាល់ ផែនទី ក្រដាសសំបកកេសដែលមានដាក់សញ្ញាសម្ភារៈសរសេរ ជាដើម អាចគ្រប់គ្រាន់ដើម្បីផ្ដួចផ្ដើមរៀបចំផែនការ និងកំណត់ទីកន្លែង និងវិធានការសមស្របសម្រាប់ការត្រួតពិនិត្យរបស់ពួកគាត់ (FAO, 2019)។

### តារាងទី ១. និយមន័យសម្រាប់ការកំណត់តំបន់ (ផែនការត្រៀមបង្ការ និងឆ្លើយតបចំពោះជំងឺសត្វនៅបរទេស USDA)

| តំបន់ | និយមន័យ |
|---|---|
| **តំបន់ឆ្លងមេរោគ (IZ)** | តំបន់នៅជាប់ជុំវិញបរិវេណដែលមានមេរោគ។ |
| **តំបន់ទ្រនាប់ (BZ)** | តំបន់ដែលនៅជាប់ជុំវិញតំបន់ឆ្លងមេរោគ ឬបរិវេណនៃកន្លែងប៉ះពាល់។ |
| **តំបន់ត្រួតពិនិត្យ (CA)** | រួមបញ្ចូល តំបន់ឆ្លងមេរោគ និងតំបន់ទ្រនាប់។ |
| **តំបន់តាមដានឃ្លាំមើល (SZ)** | តំបន់នៅខាងក្រៅ និងនៅតាមព្រំដែននៃតំបន់ត្រួតពិនិត្យ។ |
| **តំបន់គ្មានមេរោគ (FA)** | តំបន់ដែលស្ថិតនៅខាងក្រៅតំបន់ត្រួតពិនិត្យ។ |

ប្រភព៖ USDA & CFSPH, 2016

## តំបន់ឆ្លងមេរោគ

តំបន់ឆ្លងមេរោគ ជាតំបន់មួយដែលការបញ្ជាក់ថាមានការឆ្លង ASFV (OIE, 2019a)។ វាអាចជាតំបន់មួយនៅក្នុងប្រទេសណាមួយជាក់លាក់ដែលមានមេរោគ ASFV ដែលកន្លែងផ្សេងទៀតក្រៅពីតំបន់នេះ នៅតែគ្មាន ASFV ឬ តំបន់មួយនៅក្នុងប្រទេសដែលគ្មានមេរោគ ASF ប៉ុន្តែមានការរាតត្បាតថ្មីៗ ឬការបញ្ចូលមេរោគ ASFV ឡើងវិញនាពេលថ្មីៗ (USDA & CFSPH, 2016; OIE, 2019a)។ ក្នុងអំឡុងពេលមានការផ្ទុះយ៉ាងសកម្ម តំបន់ដែលមានមេរោគ ត្រូវបានកំណត់ថាជាកន្លែងដែលជាប់ជុំវិញកសិដ្ឋាន គ្រួសារ ឬភូមិដែលបានកំណត់ថាមានឆ្លងមេរោគ។ ព្រំដែនត្រូវបានកំណត់ដោយមន្ត្រីបសុពេទ្យដោយពិចារណាអំពីស្ថានភាពរោគរាតត្បាតទូទៅ កត្តាសង្គម ព្រំប្រទល់ភូមិសាស្ត្រ ឬរដ្ឋបាល (USDA & CFSPH, 2016)។ ការប្រើប្រាស់កាំរង្វង់ ក្នុងការកំណត់តំបន់នេះ អាចគ្មានភាពជាក់ស្តែងទេ ដោយសារតែលក្ខណៈធម្មជាតិនៃការឆ្លងមេរោគ ASFV ក្នុងអំឡុងពេលមានការផ្ទុះជំងឺ (USDA & CFSPH, 2016)។

ទោះជាយ៉ាងណាក៏ដោយ គួរបញ្ចូលកន្លែងសំខាន់ៗនៅក្នុងបណ្តាញខ្សែសង្វាក់តម្លៃសាច់ជ្រូកលក្ខណៈគ្រួសារ ទៅក្នុងតំបន់ឆ្លងដែលបានកំណត់ថា មានឆ្លងមេរោគ ព្រោះកត្តាកន្លែងទាំងនេះអាចជំរុញការរាលដាល សូម្បីតែពីទីតាំងទាំងនេះឆ្ងាយៗពីតំបន់ដែលមានមេរោគក៏ដោយ (FAO, 2009)។ មាត្រា ១៥.១.៣ នៃក្រមសុខភាពសត្វលើគោករបស់ OIE ចែងពីជំហានដែលបានណែនាំ ដើម្បីទទួលបានមកវិញនូវស្ថានភាពដែលចាត់ទុកថា គ្មានមេរោគបន្ទាប់ពីបាត់បង់ស្ថានភាពនេះរួចមក(OIE, 2019b)។ នៅពេលចាប់ផ្តើមការផ្ទុះជំងឺ គួរមានការពង្រីកតំបន់ឆ្លងដែលបានកំណត់ថាមានមេរោគ ដើម្បីគិតបញ្ចូលភាពមិនប្រាកដប្រជានៃវិសាលភាពក្នុងការរាលដាល។ បន្ទាប់មក គេអាចកាត់បន្ថយវិសាលភាពនេះជាបណ្តើរៗ នៅពេលមានព័ត៌មានបន្ថែម (USDA & CFSPH, 2016)។

បណ្តាប្រទេសដែលមានមេរោគ ASF ជាប្រចាំ អាចបង្កើតជាបណ្តើរៗនូវតំបន់ដែលគ្មានមេរោគ ASF នៅក្នុងប្រទេសខ្លួន ដោយអនុវត្តវិធានការជីវសុវត្ថិភាពនិងអនាម័យតឹងរ៉ឹង ដោយចាប់ផ្តើមពីតំបន់ភូមិសាស្ត្រតូចៗដែលគេស្គាល់ថា កន្លែងគ្មាន ASF។ ក្រៅពីការតាមដានឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ វិធានការអនាម័យនៅក្នុងកន្លែងទាំងនោះ ត្រូវរួមបញ្ចូលចត្តាឡីស័កនិងត្រួតពិនិត្យការចរាចរណ៍ ក៏ដូចជា ត្រួតពិនិត្យយ៉ាងតឹងរ៉ឹងលើទីផ្សារជ្រូករស់ក៏ដូចជា ការពិឃាតសត្វនៅតាមផ្ទះ និងនៅតាមសត្តឃាតដ្ឋានផងដែរ។ ការពិចារណាអំពីជីវសុវត្ថិភាពដូចមានពិពណ៌នាក្នុងឯកសារនេះ ក៏អាចធ្វើទៅបានផងដែរ ប្រសិនបើកសិករទទួលយក។

### តំបន់ទ្រនាប់

នេះជាតំបន់ដែលស្ថិតនៅជាប់ជុំវិញតំបន់ឆ្លងដែលបានកំណត់ថាមានឆ្លងមេរោគ (USDA & CFSPH, 2016)។

### តំបន់ត្រួតពិនិត្យ

នេះជាតំបន់ដែលគិតបញ្ចូលទាំងតំបន់ឆ្លងមេរោគ និងតំបន់ទ្រនាប់រួមគ្នា (USDA & CFSPH, 2016)។

### តំបន់តាមដានឃ្លាំមើល

តំបន់នៅជាប់ពីខាងក្រៅ និងតាមព្រំដែននៃតំបន់ត្រួតពិនិត្យ។ តំបន់នេះមានវិសាលភាពធំ ហើយអាចលាតសន្ធឹងគ្របដណ្តប់តំបន់រដ្ឋបាលជាច្រើន (USDA & CFSPH, 2016)។

### តំបន់គ្មាន ASF

តំបន់គ្មាន ASF រាប់បញ្ចូល កន្លែងទាំងមូលនៅខាងក្រៅតំបន់ត្រួតពិនិត្យ ដែលរួមទាំងតំបន់តាមដានឃ្លាំមើល (USDA & CFSPH, 2016)។ ក្នុងករណីមានផ្ទុះជំងឺ គួរតែដាក់តំបន់នេះនៅក្រោមការប្រុងប្រយ័ត្នខ្ពស់នៃការឆ្លង ASF ផងដែរ។ ប្រទេសដែលជួបប្រទះការផ្ទុះជំងឺ ASF ជាលើកដំបូង គួរបង្កើនសកម្មភាពតាមដានឃ្លាំមើលនៅក្នុងតំបន់ដែលគ្មានមេរោគ ASF ទន្ទឹមនឹងអនុវត្តវិធានការចត្តាឡីស័ក និងវិធានការជីវសុវត្ថិភាពនៅក្នុងតំបន់ដែលមានមេរោគ។

## ៤.១.២ ការកំណត់បរិវេណរបស់កសិករលក្ខណៈគ្រួសារក្នុងពេលផ្ទុះជំងឺ

ក្នុងអំឡុងពេលផ្ទុះជំងឺ ASF យ៉ាងសកម្ម បរិវេណដូចជា ផ្ទះ កសិដ្ឋាន ឬសូម្បីតែភូមិទាំងមូល ក៏ត្រូវចាត់ទុកថាជាឯកត្តានៃការរាតត្បាត សម្រាប់គោលដៅនៃការគ្រប់គ្រងផងដែរ។ ដោយផ្អែកលើភាពតជាប់គ្នានៃអេពីដេមីសាស្ត្រទៅកាន់បរិវេណផ្សេងទៀត ដែលបានកំណត់រួចហើយថា មានឆ្លងមេរោគ ASFV បរិវេណទាំងនេះអាចត្រូវបានកំណត់ថាជាកន្លែងឆ្លងមេរោគ បរិវេណប៉ះពាល់ដ៏គ្រោះថ្នាក់ បរិវេណដែលមានហានិភ័យ បរិវេណក្រោមការត្រួតពិនិត្យ ឬបរិវេណគ្មានមេរោគ (USDA & CFSPH, 2016)។ ចំណាត់ថ្នាក់នេះមានបង្ហាញនៅក្នុងតារាងទី ២។

### តារាងទី ២. និយមន័យសម្រាប់ការកំណត់បរិវេណនានា

| បរិវេណ | និយមន័យ | តំបន់ |
|---|---|---|
| **បរិវេណមានមេរោគ (IP)** | កន្លែងដែលសន្មតថា មានករណីវិជ្ជមាន ឬករណីវិជ្ជមានត្រូវបានបញ្ជាក់ ដោយផ្អែកលើលទ្ធផលពីមន្ទីរពិសោធន៍ រោគសញ្ញាដែលត្រូវគ្នា និយមន័យករណី ASF និងស្តង់ដារអន្តរជាតិ។ | តំបន់មានមេរោគ |
| **បរិវេណមានការប៉ះពាល់ (CP)** | បរិវេណដែលមានជ្រូកដែលប្រហែលជាបានប្រឈមនឹងជំងឺ ASF ដោយផ្ទាល់ ឬដោយប្រយោល ដែលរួមទាំង ប៉ុន្តែមិនកំហិតត្រឹមបានប៉ះពាល់ជាមួយសត្វ ផលិតផលសត្វ ភ្នាក់ងារចម្លងរោគ ឬ មនុស្សមកពីកន្លែងឆ្លងនានា។ | តំបន់មានមេរោគ<br>តំបន់ទ្រនាប់ |
| **បរិវេណសង្ស័យ (SP)** | បរិវេណដែលស្ថិតក្រោមការស៊ើបអង្កេតដោយសារតែវត្តមានជ្រូកត្រូវបានរាយការណ៍ថា មានរោគសញ្ញាដែលត្រូវគ្នានឹង ASF ។ ទីនេះត្រូវបានកំណត់សម្រាប់រយៈពេលខ្លី។ | តំបន់មានមេរោគ<br>តំបន់ទ្រនាប់<br>តំបន់តាមដានឃ្លាំមើល |
| **បរិវេណមានហានិភ័យ (ARP)** | បរិវេណដែលមានជ្រូក ប៉ុន្តែគ្មានជ្រូកណាមួយបង្ហាញរោគសញ្ញា ដែលត្រូវគ្នាជាមួយ ASF ទេ។ បរិវេណនានាបង្ហាញយ៉ាងច្បាស់ថា វាមិនមែនជាបរិវេណដែលមានមេរោគ បរិវេណដែលមានការប៉ះពាល់ ឬបរិវេណសង្ស័យឡើយ។ បរិវេណដែលមានហានិភ័យអាចព្យាយាមចរាចរណ៍សត្វ ឬផលិតផលដែលងាយរងគ្រោះនៅក្នុងតំបន់ត្រួតពិនិត្យដោយមានការអនុញ្ញាត។ មានតែបរិវេណ ដែលមានហានិភ័យប៉ុណ្ណោះ ដែលមានសិទ្ធិក្លាយជា បរិវេណនៅក្រោមការតាមដានឃ្លាំមើល។ | តំបន់មានមេរោគ<br>តំបន់ទ្រនាប់ |

### តារាងទី ២. និយមន័យសម្រាប់ការកំណត់បរិវេណនានា(ត)

| បរិវេណ | និយមន័យ | តំបន់ |
|---|---|---|
| **បរិវេណត្រួតពិនិត្យ (MP)** | បរិវេណដែលបង្ហាញយ៉ាងច្បាស់ថា វាមិនមែនជាបរិវេណដែលមានមេរោគ បរិវេណមានការប៉ះពាល់ ឬបរិវេណសង្ស័យឡើយ។ មានតែបរិវេណដែលមានហានិភ័យប៉ុណ្ណោះ ដែលមានសិទ្ធិក្លាយជាបរិវេណនៅក្រោមការតាមដានឃ្លាំមើល។ បរិវេណក្រោមការត្រួតពិនិត្យ ដែលបំពេញបានតាមសំណុំនៃលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងការព្យាយាមចរាចរណ៍សត្វ ឬផលិតផលដែលងាយរងគ្រោះចេញពីតំបន់ត្រួតពិនិត្យដោយមានការអនុញ្ញាត។ | តំបន់មានមេរោគ<br>តំបន់ទ្រនាប់ |
| **បរិវេណគ្មានមេរោគ (FP)** | បរិវេណនៅក្រៅនៃតំបន់ត្រួតពិនិត្យ និងមិនមែនជាបរិវេណប៉ះពាល់ ឬបរិវេណសង្ស័យ។ | តំបន់តាមដានឃ្លាំមើល<br>តំបន់គ្មានមេរោគ |

ប្រភព៖ USDA & CFSPH, 2016

## តំបន់ក្នុងការកំណត់នៅពេលមានផ្ទុះជំងឺ ASF

### តំបន់ និងកន្លែងនានា




ប្រភព៖ USDA & CFSPH, 2016

## ៤.២ ត្រួតពិនិត្យការចរាចរណ៍ក្នុងអំឡុងពេលផ្ទុះជំងឺ

វិធានការចត្តាឡីស័ក និងត្រួតពិនិត្យចរាចរណ៍ ក្នុងអំឡុងពេលការឆ្លើយតបនឹងការផ្ទុះជំងឺ ASFV មានសារៈសំខាន់ ចំពោះជោគជ័យនៃរាល់កិច្ចប្រឹងប្រែងគ្រប់គ្រង (USDA & CFSPH, 2016; Geering et al., 2001)។ ការចរាចរណ៍ជ្រូកដែលអាចមានមេរោគ ផលិតផលកខ្វក់ និងចរាចរណ៍មនុស្ស និងការដឹកជញ្ជូន ធ្វើឱ្យ ASF រាលដាលយ៉ាងឆាប់រហ័សពីតំបន់មានមេរោគនានា។ គោលបំណងនៃកិច្ចប្រឹងប្រែងត្រួតពិនិត្យ ASFV គឺទប់ស្កាត់ការចម្លងមេរោគទៅជ្រូករស់និងជ្រូកព្រៃដែលងាយរងគ្រោះ ដោយលុបបំបាត់ប្រភពនៃការឆ្លងមេរោគ។ កិច្ចការនេះអាចពាក់ព័ន្ធនឹងការពិឃាតជ្រូកដែលប៉ះពាល់ និង/ឬឆ្លងមេរោគ និងការហាមឃាត់ពាណិជ្ជកម្មពីតំបន់ដែលមានមេរោគ។ ដោយសារការចោលសាកសពជ្រូកនៅក្នុងដែនដី ដែលមានម្ចាស់ដីតូចៗយ៉ាងច្រើន ប្រហែលជាមិនអាចធ្វើទៅបានទេ គេអាចជម្រុញឱ្យប្រើយុទ្ធសាស្ត្រត្រួតពិនិត្យជំនួស។ ជាឧទាហរណ៍ យុទ្ធសាស្ត្រកំទេចចោល ឬ ធ្វើតេស្ត និងត្រួតពិនិត្យការ

ពិឃាតសត្វដើម្បីយកសាច់ អាចធ្វើឡើងនៅក្នុងបរិវេណ និងដែលមានហានិភ័យខ្ពស់ជំនួសឱ្យការពិឃាតចោល (FAO, 2017)។

មន្ត្រីបសុពេទ្យដែលគាំទ្រដោយច្បាប់ដែលមានស្រាប់ គួរតែចេញវិធានការអនាម័យតឹងរ៉ឹងភ្លាមៗ ចំពោះការផ្អាកជាបណ្តោះអាសន្ន ធ្វើចត្តាឡីស័ក ឬ រឹតត្បិតចលនាចូលក្នុង និងចេញក្រៅតំបន់គ្រប់គ្រង និងបរិវេណពាក់ព័ន្ធដែលមានការប៉ះពាល់ (SPS, 2019)។ មន្ត្រីបសុពេទ្យសត្វគួរបង្កើតផែនការគ្រប់គ្រងការចរាចរណ៍សម្រាប់កសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ នៅក្នុងផែនការជាតិគ្រប់គ្រង ASF របស់ខ្លួន។ ជាការល្អ គួរមានរចនាសម្ព័ន្ធចាត់តាំងដែលកំណត់យ៉ាងច្បាស់នូវតួនាទីរបស់មន្ត្រីឆ្លើយតបទាំងអស់ ដែលបានទទួលការបណ្តុះបណ្តាល។ គួរដាក់ឱ្យអាជ្ញាធរសមស្របដែលកំណត់ដោយច្បាប់ ដើម្បីជួយអនុវត្តវិធានការទាំងនេះ ធ្វើសកម្មភ្លាមៗ (USDA & CFSPH, 2016) ។ ក្នុងករណីដែលពុំមានច្បាប់ដែលចែងច្បាស់លាស់ និងដែលអាចអនុវត្តបាន មន្ត្រីបសុពេទ្យគួរមានផែនការប្រាស្រ័យទាក់ទងជាស្រេច ដែលក្នុងនោះផ្នែកមួយត្រូវចែងអំពីការចូលរួមរបស់ម្ចាស់កសិដ្ឋានលក្ខណៈគ្រួសារនៅក្នុងកិច្ចប្រឹងប្រែងត្រួតពិនិត្យស្ថានការណ៍នេះ។ ផែនការនេះគួរគិតគូរពីបរិបទរបស់ប្រទេស និងអ្វីដែលអាចដំណើរការបាន ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការ។ នេះជាការចាំបាច់ ដោយសារការរត់ពន្ធជ្រូកឆ្លងមេរោគដែលពិឃាតនៅតាមផ្ទះ និងជ្រូករស់ ទំនងជានៅតែមានជាបន្ត ទោះជាមានការរឹតបន្តឹងលើការចរាចរណ៍ក៏ដោយ។

ជាផ្នែកនៃការឆ្លើយតបរបស់ខ្លួន មន្ត្រីបសុពេទ្យត្រូវវាយតម្លៃក្នុងពេលដំណាលគ្នា នូវហានិភ័យនៃការឆ្លងរវាងតំបន់ និងប្រទេសជិតខាង។ បរិវេណនៃកសិដ្ឋានលក្ខណៈគ្រួសារដែលត្រូវបានកំណត់ជាកន្លែងសង្ស័យ ឬកន្លែងដែលមានហានិភ័យខ្ពស់ គួរ ត្រូវបានហាមឃាត់មិនឱ្យទទួល ឬដឹកជញ្ជូនជ្រូកទៅសត្តឃាតដ្ឋាន ឬកន្លែងផ្សេងឡើយ។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរបសុពេទ្យ គួរបើកឱកាសដល់កសិដ្ឋានដែលគ្មានការពាក់ព័ន្ធខាងផ្នែកជំងឺរាតត្បាត ជាមួយកន្លែងឆ្លងមេរោគ កន្លែងប៉ះពាល់ដ៏គ្រោះថ្នាក់ និងកន្លែងដែលមានហានិភ័យខ្ពស់ ដើម្បីពួកគេអាចទទួលបានការអនុញ្ញាតពិសេស ដើម្បីចរាចរណ៍ជ្រូកទៅកន្លែងសត្តឃាតដ្ឋាននៅក្រោមលក្ខខណ្ឌជីវសុវត្ថិភាពតឹងរ៉ឹង (SPS, 2019)។ មន្ត្រីបសុពេទ្យត្រូវធ្វើការវិភាគលើការខាតបង់-ផលប្រយោជន៍នៃវិធានការត្រួតពិនិត្យដែលគ្រោងដាក់ឱ្យអនុវត្ត នៅក្នុងអំឡុងពេលមានការផ្ទុះជំងឺ ASFV នៅក្នុងតំបន់ ឬភូមិភាគជាក់លាក់នានា មុនពេលដាក់ចេញវិធានការបែបនេះ។

## ៤.៣ ការត្រៀមសម្រាប់ការដឹកជញ្ជូនជ្រូករស់

- មានតែជ្រូកដែលមកពីតំបន់ ឬបរិវេណគ្មាន ASFV ដែលរួមទាំង តំបន់ត្រួតពិនិត្យដែលមានលិខិតអនុញ្ញាតសមស្របប៉ុណ្ណោះ ដែលអាចដឹកជញ្ជូនជ្រូកទៅកាន់កសិដ្ឋានផ្សេងទៀត។ មុនពេលដឹកជញ្ជូន គួរមានការដាក់ជ្រូកឱ្យនៅដាច់ដោយឡែកពីគ្នា យ៉ាងហោចណាស់ ១៥ ថ្ងៃ ដើម្បីធានាបាននូវលក្ខខណ្ឌគ្មានមេរោគ (OIE, 2019d; SPS, 2019)។ ចំណុចនេះចាំបាច់ណាស់ ព្រោះថា គេអាចសង្កេតមើលមិនឃើញរោគសញ្ញាបន្ទាប់បន្សំខ្លះៗ។
- ទោះជាយ៉ាងណាក៏ដោយ កសិដ្ឋានជ្រូកប្រភពដើម គួរធានាឱ្យមានការអនុវត្តលក្ខខណ្ឌអប្បបរមានៃជីវសុវត្ថិភាព នៅក្នុងអំឡុងពេលដឹកជញ្ជូន ក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងរបស់មន្ត្រីបសុពេទ្យ។
- រថយន្តដឹកជញ្ជូន គួរប្រើផ្លូវទៅតាមការណែនាំរបស់មន្ត្រីបសុពេទ្យ ធានាឱ្យមានការដឹកជញ្ជូនជ្រូកបានសមស្របក្នុងរយៈពេលខ្លី និងនៅទីបំផុត ត្រូវធ្វើដំណើរត្រង់ទៅកាន់កសិដ្ឋានគោលដៅដោយមិនឈប់នៅផ្សារជ្រូក ឬ កសិដ្ឋានផ្សេងទៀតណាមួយឡើយ។
- រថយន្តដឹកជញ្ជូនត្រូវតែផ្ទុកចំណី និងទឹកគ្រប់គ្រាន់ពីកសិដ្ឋានគោលដៅ ដើម្បីជៀសវាងការឈប់ដើម្បីទិញអាហារនៅតាមផ្លូវទៅកាន់គោលដៅ។


© FAO/R. Willis

# ៥ | ការពិឃាតជ្រូកក្នុងកន្លែងមានផ្ទះជំទី

ស្តង់ដារអនាម័យ និងជីវសុវត្ថិភាព មានភាពខុសប្លែកគ្នាយ៉ាងច្រើន រវាងសត្តឃាតដ្ឋាននានា ដោយអាស្រ័យលើប្រភេទ និងសមត្ថភាពនៃសត្តឃាតដ្ឋានទាំងនោះ។ លើសពីនេះ ជ្រូកជាច្រើនក្បាលត្រូវបានគេពិឃាតនៅតាមផ្ទះសម្រាប់ការបរិភោគក្នុងមូលដ្ឋាន ដោយគ្មានការត្រួតពិនិត្យសាច់ជាផ្លូវការឡើយ។ ការធ្វើបែបនេះទំនងជាបង្កើនហានិភ័យនៃការរាលដាលមេរោគ ASFV ប្រសិនបើគេចែករំលែកសាច់ទាំងនោះរវាងសាច់ញាតិឆ្ងាយ ឬ លក់ដោយខុសច្បាប់នៅទីផ្សារលក់សាច់។ កម្មករនៅសត្តឃាតដ្ឋាន អ្នកពិឃាតសត្វដែលផ្តល់សេវាដល់បុគ្គលនានា និងកសិករដែលពិឃាតជ្រូកដោយខ្លួនឯង អាចមានភាពកខ្វក់ និងដើរតួជាភ្នាក់ងារចម្លង។ ទោះជាយ៉ាងនេះក្តី សេវាកោសល្យវិច័យនៅមុនសត្វស្លាប់ និងក្រោយសត្វស្លាប់ មិនទំនងជាបានផ្តល់ជូនឡើយ ក្នុងអំឡុងពេលសត្តឃាតបែបនេះ។ អនុសាសន៍មួយចំនួនដើម្បីកាត់បន្ថយការរាលដាល ASFV ដែលទាក់ទងនឹងការពិឃាតជ្រូក មានជាអាទិ៍៖

- គួរមានការត្រួតពិនិត្យការចេញចូលទៅកាន់កន្លែងពិឃាតសត្វ នៅតាមកសិដ្ឋានលក្ខណៈគ្រួសារ ដើម្បីធានាថា ភ្ញៀវ និងបសុសត្វផ្សេងទៀត មិនប្រឈមនឹងភាពកខ្វក់ឡើយ (Skaarup, 1985; Wirtanen & Salo, 2014)។
- កន្លែងពិឃាតសត្វ គួរតែស្ថិតនៅឆ្ងាយគ្រប់គ្រាន់ ពីកន្លែងរក្សាទុកជ្រូក ដោយមានដំណើរការឯកទិសនៃការចរាចរណ៍ពី ទីកខ្វក់ (កន្លែងពិឃាតជ្រូក) ទៅកន្លែងស្អាត (កន្លែងច្រៀកសាច់ជាចុងក្រោយ) (Chenais et al., 2017)។
- មន្ត្រីតាមមូលដ្ឋាន គួរពង្រឹងការអនុវត្តវិធានការតឹងរ៉ឹង ដើម្បីទប់ស្កាត់ការផ្តល់សំណល់ពីកន្លែងពិឃាតសត្វ ដូចជាឈាម និងបំណែកសាច់ ធ្វើជាចំណីសម្រាប់ជ្រូក ដោយសារវាជាប់ទាក់ទងនឹងហានិភ័យជាខ្លាំងនៃ ASFV។
- ការចូលរួមរបស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងការពង្រឹងកិច្ចការពារបរិស្ថាននៅក្នុងសត្តឃាតដ្ឋាន និងតាមផ្ទះ អាចកាត់បន្ថយហានិភ័យ ASFV ដោយសារតែបានបង្កើនអនាម័យ និងភាពស្អាត។ ការគ្រប់គ្រងសំណល់កាន់តែប្រសើរឡើងដែលរួមទាំងការចោល ការបង្ហូរទឹកចេញ ការផ្គត់ផ្គង់ទឹក និងប្រព្រឹត្តកម្មលាមកសត្វ និងការដឹកជញ្ជូនឱ្យបានគ្រប់គ្រាន់ អាចកាត់បន្ថយយ៉ាងច្រើននូវហានិភ័យនៃការចម្លងជំងឺ ASF។
- កន្លែងសត្តឃាត ក៏ជាចំណុចនៃការចម្លង ASFV ផងដែរ ដោយសារជ្រូកមកពីតំបន់រដ្ឋបាល និងកន្លែងរក្សាទុកខុសៗគ្នា ត្រូវបានដាក់បញ្ចូលគ្នា សម្រាប់ការពិឃាត និងកែច្នៃជាសាច់។
- ប្រការនេះ ច្រើនតែទាក់ទងនឹងចរាចរយ៉ាងច្រើននៃយានយន្ត និងមនុស្សដែលបង្កើន

ហានិភ័យនៃការឆ្លង ASFV។

- នៅតាមសត្តឃាតដ្ឋានធំៗ មន្ត្រីបសុពេទ្យពង្រឹងការពិនិត្យជ្រូក ចាប់តាំងពីមុនពេលពិឃាតជ្រូក រហូតដល់ក្រោយជ្រូកស្លាប់ ដោយធានាថា គ្មានការពិឃាតជ្រូកឈឺដើម្បីយកសាច់ឡើយ។
- នៅទីសត្តឃាតតាមផ្ទះ គេអាចបញ្ចុះបញ្ចូលកសិករ តាមរយៈការបង្កើតការយល់ដឹងប្រកបដោយប្រសិទ្ធភាព និងការបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណសញ្ញាគ្លីនិកមុនពេលពិឃាតជ្រូកតែប៉ុណ្ណោះ។
- សត្តឃាតដ្ឋាន ត្រូវតែធានាឱ្យមានការសម្អាត និងរំងាប់មេរោគនៅកន្លែងកែច្នៃសាច់ នៅចុងបញ្ចប់នៃថ្ងៃធ្វើការនីមួយៗ ដើម្បីយកចេញនូវលាមក រោម និងកំទេចកំទីដែលអាចកខ្វក់។
- សត្តឃាតដ្ឋានត្រូវធានាឱ្យមានការសម្អាត និងរំងាប់មេរោគបានហ្មត់ចត់លើមធ្យោបាយដឹកជញ្ជូនទាំងអស់ដែលនាំជ្រូកទៅកន្លែងរបស់ខ្លួន ដោយយកចិត្តទុកដាក់ជាពិសេសចំពោះ កង់ ឃ្លុបនានា និងផ្នែកខាងក្រោម។
- សត្តឃាតដ្ឋានត្រូវត្រួតពិនិត្យការចេញចូល និងការចរាចរណ៍បុគ្គលិកនៅក្នុងបរិវេណរបស់ខ្លួន។ គួរហាមឃាត់បុគ្គលិក មិនឱ្យទៅមើលកសិដ្ឋានចិញ្ចឹមជ្រូក និងទៅបរបាញ់ឡើយ។
- សត្តឃាតដ្ឋាន ត្រូវធានាឱ្យមានការត្រួតពិនិត្យជាអតិបរមាលើសត្វល្អិត និងការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ។

## ៥.១ ការពិឃាតសត្វនៅតាមផ្ទះ

ការពិឃាតជ្រូកតាមផ្ទះ សំដៅលើការពិឃាតជ្រូកនៅក្នុងបរិវេណ របស់កសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ដែលតាមធម្មតាសម្រាប់ការបរិភោគផ្ទាល់ខ្លួន ឬ ក្នុងគ្រួសារ (FSA, 2020)។ សម្រាប់គោលបំណងនៃការបង្ការ និងគ្រប់គ្រងមេរោគ ASFV យើងអាចរួមបញ្ចូលម្ចាស់ជ្រូកដែលបញ្ជូនជ្រូករស់ទៅកាន់សត្តឃាតដ្ឋាន ដើម្បីពិឃាតយកសាច់។ ដើម្បីបង្កើនអនាម័យ និងបង្ការជំងឺ៖

- មន្ត្រីបសុពេទ្យគួរធានាថាសាច់ទាំងអស់សម្រាប់មនុស្សបរិភោគ មានប្រភពពីសត្វដែលពិឃាតនៅក្នុងសត្តឃាតដ្ឋាន ដែលមានការអនុញ្ញាត និងនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីនៅតាមមូលដ្ឋាន (FSA, 2020)។
- ប្រសិនបើត្រូវដឹកជ្រូកទៅសត្តឃាតដ្ឋាន ក្នុងគោលដៅលក់សាច់ទៅទីផ្សារ ត្រូវដាក់ជ្រូកទាំងនោះដាច់ដោយឡែករយៈពេល ១៥ ថ្ងៃ ដោយគ្មានសញ្ញាគ្លីនិកណាមួយឡើយ។ ប្រសិនបើមិនអាចបំបែកជ្រូកនីមួយៗចេញពីគ្នាទេនោះ កសិករគួរចៀសវាងការបញ្ចូលជ្រូកថ្មីមកក្នុងហ្វូងជ្រូកនេះ រយៈពេល ១៥ ថ្ងៃចុងក្រោយនេះ។

- អាចអនុញ្ញាតឱ្យមានការពិឃាតជ្រូកមួយក្បាលនៅតាមផ្ទះ សម្រាប់បរិភោគក្នុងគ្រួសារប៉ុណ្ណោះ។
- គួរជៀសវាងទម្លាប់ដែលអ្នកកាប់ជ្រូកក្នុងមូលដ្ឋាន ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីពិឃាតជ្រូក។ ក្នុងអំឡុងពេលបុណ្យប្រពៃណីតាមភូមិ តាមធម្មតាគ្រួសារនីមួយៗពិឃាតជ្រូកមួយក្បាលសម្រាប់បរិភោគក្នុងគ្រួសារ ហើយពួកគេអាចហៅអ្នកកាប់ជ្រូក មកជួយធ្វើសត្តឃាតជ្រូករបស់ខ្លួនផងដែរ។
  ក្នុងករណីនេះ គេអាចរៀបចំផែនការភូមិ ដើម្បីស្នើសុំមន្ត្រីបសុពេទ្យមកឱ្យចុះពិនិត្យជ្រូក និងគ្រោងអំពីរបៀបធ្វើសត្តឃាតជ្រូកនៅតាមផ្ទះ ដែលរួមទាំង របៀបគ្រប់គ្រងការចរាចរណ៍របស់អ្នកកាប់ជ្រូក ឬ ចាត់តាំងអ្នកជ្រូកច្រើននាក់ ឱ្យមកជួយគ្រួសារណាមួយនៅក្នុងពេលតែមួយ។
- មន្ត្រីបសុពេទ្យដែលមានច្បាប់សមស្របសម្រាប់បង្ការ និងត្រួតពិនិត្យជំងឺ គួរធានាថាការពិឃាតជ្រូកយកសាច់លក់ទៅទីផ្សារ ត្រូវធ្វើឡើងតែនៅក្នុងសត្តឃាតដ្ឋានដែលមានការអនុញ្ញាតតែប៉ុណ្ណោះ។ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងនូវការពិឃាតជ្រូក(ច្រើនជាងមួយក្បាល)នៅផ្ទះ សម្រាប់លក់ជាលក្ខណៈពាណិជ្ជកម្ម។
- ម្ចាស់អាជីវកម្មលក្ខណៈគ្រួសារដែលពិឃាតជ្រូកតាមផ្ទះសម្រាប់បរិភោគផ្ទាល់ខ្លួន គួរធានាថា (Chenais et al., 2017)៖
  - មានតែជ្រូកដែលមានសុខភាពល្អ ដែលគ្មានរោគសញ្ញាប៉ុណ្ណោះ ដែលត្រូវបានធ្វើសត្តឃាត។
  - ការពិឃាតជ្រូក ត្រូវធ្វើឡើងនៅឆ្ងាយគ្រប់គ្រាន់ពីទ្រុងជ្រូក និងធ្វើនៅលើផ្ទៃរឹង ដែលងាយស្រួលបង្ហូរទឹកចេញ សម្អាត និងរំងាប់មេរោគ។
  - ការសម្អាត និងការរំងាប់មេរោគ ធ្វើឡើងបន្ទាប់ពីការសំលាប់សត្វ។ គ្មានការចរាចរណ៍ខុសច្បាប់នូវសាកសពជ្រូក ឬ សាច់ជ្រូកឡើយ លុះត្រាតែមានការបញ្ជាក់សម្រាប់ទីផ្សារក្នុងស្រុក។
  - បំណែកសត្វ និងសំណល់នានា ត្រូវបានបោះចង់ចោលឱ្យបានត្រឹមត្រូវ។
  - សមាជិកគ្រួសារដែលមើលថែជ្រូករស់ មិនគួរជាអ្នកពិឃាតជ្រូកនោះទេ។ ប្រសិនបើមានករណីបែបនេះ យ៉ាងហោចណាស់ជននោះត្រូវទុកពេល ៤៨ម៉ោង មុននឹងអាចមកថែទាំជ្រូកឡើងវិញ។
  - គួរមានការកំណត់ព្រំដែនច្បាស់លាស់សម្រាប់កន្លែងស្អាត និងកខ្វក់នៅក្នុងកសិដ្ឋានឬបរិវេណនៃផ្ទះ ហើយដំណើរការពិឃាត គួរតែអនុវត្តតាមលំហូរឯកទិស ចេញពីកន្លែងកខ្វក់ ដែលរក្សាទុកជ្រូកសម្រាប់ធ្វើសត្តឃាត និងកន្លែងច្រៀក ឬកែច្នៃសាច់។ ដូចគ្នានេះដែរចំពោះអ្នកកាប់សាច់ និងកម្មករ ពួកគេត្រូវផ្លាស់ទីពីកន្លែងក្រខ្វក់ ទៅកន្លែងស្អាត។ និង

- ▫ ទីសត្តឃាត និងឧបករណ៍ ត្រូវតែអាចឱ្យមានការសម្អាត និងរំងាប់មេរោគបាន យ៉ាងងាយ។
- កសិករម្ចាស់សត្វ អ្នកពិឃាតជ្រូក ឈ្មួញកណ្តាល និងអ្នកទិញ ត្រូវទទួលការបណ្តុះបណ្តាលដើម្បីឱ្យមានការយល់ដឹងអំពីមូលហេតុដែលមានការហាមឃាត់ការពិឃាតសត្វតាមផ្ទះសម្រាប់លក់ជាលក្ខណៈពាណិជ្ជកម្ម និងមូលហេតុដែលអាចបង្កនូវផលវិបាកនៃការរាលដាលនៃជំងឺនេះ។
- មន្ត្រីបសុពេទ្យគួរចាត់ចែងឱ្យមានដំណើរការចុះឈ្មោះសម្រាប់សត្តឃាតដ្ឋានមានលក្ខណៈជាក់ស្តែង និងអាចធ្វើទៅបាន ដើម្បីអាចឱ្យឈ្មួញក្នុងស្រុកទទួលយកបាន។
- ការពិឃាតសត្វដោយសុវត្ថិភាពនៅក្នុងបរិវេណនៃកន្លែងចិញ្ចឹមជ្រូកលក្ខណៈគ្រួសារក្នុងតំបន់ដែលឆ្លងមេរោគ ASF ឬ តំបន់ដែលមានជំងឺនេះកើតឡើងដោយឯកឯង គឺជាលំបាក ដោយសារទាមទារឱ្យមានជីវសុវត្ថិភាពតឹងរ៉ឹង ដើម្បីកាត់បន្ថយហានិភ័យនៃការរាលដាលនៃជំងឺ ASF។

## លំហូរដែលស្នើឡើងសម្រាប់ដំណើរការពិឃាតនៅសត្តឃាតដ្ឋាន



## ៥.២ ការដឹកជញ្ជូនទៅសត្តឃាតដ្ឋាន

- កសិករម្ចាស់សត្វ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយសត្តឃាតដ្ឋាន ដែលដឹកជញ្ជូនជ្រូកដោយផ្ទាល់ គួរតែមានលិខិតអនុញ្ញាតចាំបាច់ពីមន្ត្រីបសុពេទ្យ។
- កសិករគួរតែបង្កើតទម្លាប់មួយ និងធានាឱ្យមានការប្រាស្រ័យទាក់ទងជាប្រចាំជាមួយសត្តឃាតដ្ឋានជាគោលដៅ។
- ត្រូវអនុវត្តជំហានជាក់ស្តែង ដើម្បីធានាបាននូវជីវសុវត្ថិភាពសម្រាប់ការផ្ទុក និងផ្ទេរទំនិញ ទន្ទឹមនឹងកាត់បន្ថយការចម្លងរោគ និងការឆ្លងទៅមកក្នុងពេលដឹកជញ្ជូន។
- គួរសម្អាត និងរំងាប់មេរោគលើឡានដឹកទំនិញ រ៉ឺម៉ក និងរទេះឱ្យបានហ្មត់ចត់នៅចន្លោះពេលដឹកជញ្ជូនមួយជើងៗ។
- កសិករ ឬជំនួយការទទួលបន្ទុកផ្នែកនេះ ត្រូវត្រួតពិនិត្យយានយន្តឱ្យបានហ្មត់ចត់ នៅកន្លែងផ្ទុកដែលបានកំណត់។ កសិករ អ្នកបើកបរ និងជំនួយការ ត្រូវតែដឹងអំពីដែនកំណត់នៃចរាចរណ៍ ប្រសិនបើមាន និងផ្លូវដែលមានការអនុញ្ញាតដើម្បីជៀសវាងតំបន់ដែលមានមេរោគ។
- សត្តឃាតដ្ឋានជាគោលដៅ គួរមានប្លង់ដែលបង្ហាញការដឹកជញ្ជូន ដែលមិនមានការប៉ះពាល់ ឬប៉ះពាល់តិចតួចបំផុត ជាមួយរថយន្តដឹកទំនិញផ្សេងទៀត។ ចំណុចផ្ទុកទំនិញនៅសត្តឃាតដ្ឋាន អាចជាកន្លែងចម្រុះសម្រាប់យានយន្ត អ្នកបើកបរ និងអាចជាជ្រូកផងដែរ។
- បើអាចធ្វើបាន សត្តឃាតដ្ឋានគួរផ្តល់មធ្យោបាយរំងាប់មេរោគសម្រាប់គ្រប់យានយន្ត មុនពេលចូលដល់កន្លែងផ្ទេរទំនិញ និងនៅច្រកចេញ។
- នៅចំណុចសត្តឃាតទាំងអស់ ទោះជាលក្ខណៈឧស្សាហកម្ម ឬមិនមែនក៏ដោយ គួរមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយមន្ត្រីបសុពេទ្យ ដែលពង្រឹងការអនុវត្តយ៉ាងហោចណាស់ស្តង់ដារអប្បបរមាជីវសុវត្ថិភាព។

## ៥.៣ ការរំងាប់មេរោគនៅសត្តឃាតដ្ឋាន

អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន មានភារៈទទួលខុសត្រូវលើការបង្កើតវិធានការសម្អាត និងរំងាប់មេរោគជាប្រចាំសម្រាប់សត្តឃាតដ្ឋានរបស់ខ្លួន។ វិធានការទាំងនេះត្រូវតែអាចអនុវត្តបានដោយផ្អែកលើកត្តាសេដ្ឋកិច្ច ដោយគិតគូរពីសមត្ថភាពរបស់សត្តឃាតដ្ឋាន និងឆ្លើយតបចំពោះតម្រូវការទឹក ថាមពល និងកម្លាំងពលកម្ម សម្រាប់ការសម្អាត និងការរំងាប់មេរោគប្រកបដោយប្រសិទ្ធភាព។

- ប្រការសំខាន់គឺត្រូវមានកម្មវិធីអប់រំ និងបណ្តុះបណ្តាល ជាពិសេសដែលទាក់ទងនឹងសត្តឃាតដ្ឋាន និងជីវសុវត្ថិភាព ASFV ដែលត្រូវបានរៀបចំឡើងសម្រាប់កម្មករ និងអ្នកគ្រប់គ្រងទាំងអស់។
- គណៈគ្រប់គ្រងសត្តឃាតដ្ឋាន គួរចងក្រងឯកសារអំពីទម្លាប់សម្រាប់ជីវសុវត្ថិភាពរបស់

ខ្លួន នៅក្នុងកម្មវិធីសម្អាតលម្អិត ដែលគិតគូរពីបរិបទជាក់លាក់នៃសត្តឃាតដ្ឋានជាក់លាក់ ដែលរួមទាំង ការជានាឱ្យ៖

- មានក្រុមដែលផ្តោតលើការងារសម្អាត និងរំងាប់មេរោគដោយយកចិត្តទុកដាក់ ដោយម្នាក់ៗយល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។
- មានប្រព័ន្ធសមស្របសម្រាប់រាយការណ៍ និងស្តារភាពមិនប្រក្រតីឡើងវិញ។
- មានចែងគោលការណ៍ច្បាស់លាស់នៃការលាងសម្អាត និងការរំងាប់មេរោគ។
- កម្មករទាំងអស់ចូលរួមក្នុងអំឡុងពេល និងក្រោយពេលពន្លះសាច់។

- អ្នកគ្រប់គ្រងត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីកម្រិតញឹកញាប់នៃការសម្អាត និងរំងាប់មេរោគ។ ការលាងសម្អាត និងរំងាប់មេរោគគួរតែធ្វើឱ្យបានហ្មត់ចត់ យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។
- ការអនុវត្តល្អក្នុងការសម្អាត និងរំងាប់មេរោគ អាចជួយឱ្យកម្មវិធីដែលបានគ្រោងទុកយ៉ាងល្អ ក្នុងការកាត់បន្ថយការចម្លងរោគមកលើជ្រូក បុគ្គលិក ឧបករណ៍ សាកសពសត្វ និងផ្ទៃនានា។
- កម្មវិធីសម្អាតប្រកបដោយប្រសិទ្ធភាព មានជាអាទិ៍ ការលាងជម្រះ បន្ទាប់មកការលាងដោយប្រើសាប៊ូ និងថ្នាំរំងាប់មេរោគ ដែលមានកំហាប់សមស្រប ដោយពិចារណាលក្ខខណ្ឌនៃមជ្ឈដ្ឋានជុំវិញ ឧ. សីតុណ្ហភាព។ សីតុណ្ហភាពត្រជាក់អាចធ្វើឱ្យថ្នាំរំងាប់មេរោគមិនសូវមានប្រសិទ្ធភាព។ គួរផ្តល់ការណែនាំលម្អិត ដែលទាក់ទងនឹង៖
  - ការយកឧបករណ៍កែច្នៃសាច់ចេញពីកន្លែងដើម និងចេញពីទីធ្លាខាងក្នុងសម្រាប់សម្អាត
  - ការលាងសំអាតបង្គុំនៃឧបករណ៍
  - ការយកសំណល់រឹងចេញពីទីធ្លាខាងក្នុង
  - ការដោះ និងយកសំណល់រឹងចេញពីឧបករណ៍
  - លាងជម្រះជាមួយទឹកជាមុន
  - ការសម្អាត និងលាងជម្រះផ្ទៃខាងក្នុង
  - ការប្រើសាប៊ូលាងឧបករណ៍
  - ការលាងឧបករណ៍ដោយប្រើប្រាស់ទឹកដែលមានសម្ពាធទាប
  - ការរំងាប់មេរោគលើឧបករណ៍
  - ក្រោយលាងឧបករណ៍ដោយប្រើទឹកស្អាត និងការធ្វើប្រព្រឹត្តកម្មក្រោយពេលផ្គុំឡើងវិញ។ និង
  - ទីបំផុត ដោះបំណែកឧបករណ៍ដែលត្រូវសម្អាត និងការរំងាប់មេរោគក្នុងបន្ទប់ដែលបាញ់ផ្សែងចូល រួមជាមួយលទ្ធភាពក្នុងការបើកឱ្យមានចរន្តខ្យល់ចេញចូលបានល្អ។

## នីតិវិធីសម្អាត និងរំងាប់មេរោគសម្រាប់សត្តឃាតដ្ឋាន

### ចំណុចត្រូវចងចាំ

- អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន ត្រូវផ្តល់ការណែនាំជាក់លាក់ សម្រាប់កន្លែងជាក់លាក់ ឬឧបករណ៍ដែលត្រូវសម្អាត ឧ. រោងជ្រូក។ កន្លែងផ្សេងគ្នា អាចមានការប្រឡាក់ខុសៗគ្នា ឧទាហរណ៍ ការសម្អាតលាមកសត្វនៅក្នុងរោងជ្រូក ធៀបនឹងការសម្អាតស្នាមប្រឡាក់ឈាមនៅកន្លែងច្រៀកសាច់។
- ប្រសិនបើប្រើឧបករណ៍ ត្រូវអនុវត្តតាមសេចក្តីការណែនាំរបស់ក្រុមហ៊ុនផលិត អំពីការសម្អាត និងថែទាំឧបករណ៍នោះ តាមតែអាចធ្វើបាន។ ត្រូវបានកំណត់កាលវិភាគសមស្រប សម្រាប់សម្អាតឧបករណ៍ថ្លៃៗ ប៉ុន្តែត្រូវធ្វើឱ្យទៀងទាត់។
- ត្រូវមានការទទួលខុសត្រូវរួមគ្នាលើការលាងសម្អាត និងរំងាប់មេរោគ។ បើអាចធ្វើបាន ត្រូវចាត់តាំងបុគ្គលិកម្នាក់ៗសម្រាប់កន្លែងជាក់លាក់ណាមួយ ជាពិសេស កន្លែងធ្វើការផ្ទាល់របស់ខ្លួន ក្រោយម៉ោងធ្វើការ។ ត្រូវមានមនុស្សម្នាក់ ដឹកនាំសកម្មភាពសម្អាត។ ការលាងសម្អាតភ្លាមៗបន្ទាប់ពីធ្វើការរួច អាចឱ្យដំណើរការសម្អាតកាន់តែងាយស្រួល។
- រយៈពេលនៃដំណើរការសម្អាតទាំងមូល អាចខុសគ្នា អាស្រ័យលើលក្ខខណ្ឌទូទាំងនៃបរិស្ថាន។ ត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់ការសម្អាត និងរំងាប់មេរោគ។
- អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន គួរធានាឱ្យមានការសម្អាតនិងការរំងាប់មេរោគ – មិនគួរមើលរំលងចំណុចនេះបានឡើយ។ គួរមានការពិចារណាអំពីលក្ខខណ្ឌតម្រូវខាងថាមពល ដោយអាស្រ័យលើប្រភេទសត្តឃាតដ្ឋាន។ កន្លែងសត្តឃាតនៅតាមផ្ទះ និងក្នុងទីវាលចំហ ច្រើនធ្វើការសម្អាតដោយគ្មានគ្រឿងម៉ាស៊ីនជាជំនួយ។
- បុគ្គលិក និងក្រុមអ្នកសម្អាត គួរទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវអំពីដំណើរការសមស្រប សម្រាប់ការសម្អាត និងរំងាប់មេរោគ ជាពិសេស អំពីរបៀបប្រើប្រាស់ឧបករណ៍ និងបរិក្ខារនានាដែលមានស្រាប់។

### ការរៀបចំសម្រាប់ការលាងជម្រះដីជាមុន

- នីតិវិធីសម្អាត ចាប់ផ្តើមដោយការយកគ្រោងឆ្អឹងចេញពីកន្លែងពន្លះសាច់។
- គួរយកចេញនូវវត្ថុដែលអាចរារាំងដំណើរការសម្អាតឱ្យមានប្រសិទ្ធភាព ឬ ដែលអាចខូចដោយសារប៉ះទឹក។ គួរគ្របព្រីភ្លើង និងបិទបាំងឱ្យជិតដើម្បីជៀសវាងប៉ះទឹក។ គួរគ្របឱ្យបានត្រឹមត្រូវនូវឧបករណ៍ដែលមិនអាចចរាចរណ៍បាន ដើម្បីការពារពីការប៉ះទឹក។ ឧបករណ៍ដែលអាចចរាចរណ៍បាននៅក្នុងកន្លែងនោះ អាចត្រូវបញ្ជូនទៅសម្អាតនៅកន្លែងដែលបានកំណត់។
- បន្ទាប់ពីការយកចេញនៃគ្រោងឆ្អឹង និងឧបករណ៍ផ្សេងទៀតចេញរួចហើយ គួរត្រៀម និងតម្លើងឧបករណ៍សម្ភារៈទាំងអស់ដែលចាំបាច់សម្រាប់ការសម្អាត។ ការត្រៀមនេះ

រាប់បញ្ចូល ការរៀបចំសាប៊ូ សូលុស្យុងថ្នាំរំងាប់មេរោគ ធុងទឹក។

- គួរមានសម្ភារៈសម្អាតដែលសមស្របតាមប្រភេទនៃសត្តឃាតដ្ឋាន ឧ. កន្លែងពិឃាត ក្នុងទីលានចំហ ការពិឃាតចល័ត ការពិឃាតនៅតាមផ្ទះ។ល។ គេអាចប្រើប្រាស់សម្ភារៈសម្អាតធម្មតា ដូចជា ធុងសំរាម អំបោស ច្រាស សាប៊ូម្សៅ ជាដើម ដើម្បីធ្វើការសម្អាត និងរំងាប់មេរោគប្រកបដោយប្រសិទ្ធភាព។
- សម្ភារៈសម្អាតសមស្រប ដែលត្រូវផ្គុំឡើងវិញ គួរតែជាប្រភេទនៃកន្លែងប្រឡាក់ដែលត្រូវសម្អាត ឧ. ឈាម សារធាតុរាវ ខ្លាញ់ ជាដើម ព្រមទាំងសីតុណ្ហភាពក្នុងមជ្ឈដ្ឋានជុំវិញ។

## ការសម្អាត និងការរំងាប់មេរោគ

- បន្ទាប់ពីការបោសសម្អាត និងការតម្លើងសម្ភារៈសម្អាត គួរប្រមូលយកសំណល់រឹងចេញ មុនលាងសម្អាតជាមួយទឹក។ បើអាចធ្វើបាន គួរប្រមូលយកសំណល់រឹងទាំងអស់នៅក្នុងកន្លែងនេះ ចេញជាមុនសិន។
- ជាដំបូង ត្រូវសម្អាតបរិស្ថានខាងក្នុងឱ្យបានហ្មត់ចត់ជានិច្ច មុនពេលសម្អាតឧបករណ៍។ បើអាចធ្វើបាន គួររើឧបករណ៍ចេញ ដើម្បីអាចសម្អាតដោយប្រសិទ្ធភាពខ្ពស់។ ត្រូវយកសំណល់រឹងចេញពីឧបករណ៍សិន មុននឹងលាងជម្រះជាមួយទឹក។ ការយកសំណល់រឹងចេញជាមុន កាត់បន្ថយរយៈពេលលាងសម្អាតជាមុន និងសន្សំសំចៃទឹក។
- ត្រូវយកសំណល់រឹងទាំងអស់ចេញ ហើយត្រូវលាងសម្ភារៈ/បរិក្ខារ/ផ្ទៃនានាជាមុនសិន ទើបប្រើសាប៊ូជាបន្ត។ ប្រសិនបើផ្ទៃលាងសម្អាតមានជាប់ខ្លាញ់ និងប្រេងរំអិល គេអាចប្រើទឹកក្តៅសម្រាប់ការលាងជម្រះជាមុន។ ប្រសិនបើប្រើទឹកត្រជាក់សម្រាប់លាងជម្រះផ្ទៃដែលមានជាតិខ្លាញ់ ក្នុងករណីនេះត្រូវអនុវត្តដំណើការសម្អាតឱ្យបានហ្មត់ចត់ជាបន្ត។
- សត្តឃាតដ្ឋាន ដែលប្រើសម្ពាធទឹកសម្រាប់លាងជម្រះ សម្ពាធទឹកមិនគួរលើសពី ៣០បារ (៣០០០ kPa) ព្រោះថា សម្ពាធខ្ពស់ជាងនេះ អាចធ្វើឱ្យខូចផ្ទៃ ឬ ធ្វើឱ្យភ្នាក់ងារបង្ករោគបើងទៅជាប់លើផ្ទៃកខ្វក់ ដែលអាចបង្កើនហានិភ័យនៃការរាលដាល។
- គួរមានការចាត់ចែងលាងសម្អាតតាមវិធីផ្សេង ក្នុងករណីដែលឧបករណ៍សម្អាតណាមួយមិនដំណើរការ ហើយត្រូវមានផែនការសម្រាប់ការជួសជុលឧបករណ៍នោះ។
- សម្រាប់សត្តឃាតដ្ឋានដែលប្រើសម្ពាធទឹក គួរប្រើសម្ពាធទាប (រវាង ២០ និង ៣០បារ) ដែលហូរក្នុងអត្រា ១៨ ទៅ ២០ លីត្រក្នុងមួយនាទី។ គួរជៀសវាងបាញ់ទឹកដែលមានសម្ពាធខ្លាំង ព្រោះនាំឱ្យមានសម្ពាធខ្ពស់ខ្លាំងពេក។
- បន្ទាប់ពីការយកសំណល់រឹងចេញ និងការលាងជម្រះជាមុន គេអាចប្រើសាប៊ូនៅក្នុងការលាងសម្អាត។
- គួរជៀសវាងការលាងសម្អាត ឬបាញ់ទឹកលាង ដោយចេញពីកន្លែងមិនស្អាតទៅ

កន្លែងស្អាត។

- គួរប្តូរស្កូលុយស្យុងទឹក និងសាប៊ូ នៅពេលប្តូរទៅសម្អាតនៅកន្លែងខុសគ្នា។
- បន្ទាប់ពីអនុវត្តនីតិវិធីសម្អាតយ៉ាងហ្មត់ចត់ គួរអនុវត្តសកម្មភាពរំងាប់មេរោគ។ ត្រូវប្រាកដថា បានបាញ់សូលុយស្យុងនៅគ្រប់កន្លែងទាំងអស់យ៉ាងម៉ត់ចត់ ដោយទុកពេលវេលាសមស្របសម្រាប់ប្រភេទទឹកថ្នាំដែលប្រើ (ពី ១៥ វិនាទីទៅ ១០នាទី)។ ត្រូវលាងសម្អាតទឹកសាប៊ូ និងទឹកថ្នាំរំងាប់មេរោគចេញឱ្យបានពេញលេញដើម្បីកម្ចាត់ជាតិគីមី។
- នៅក្នុងកន្លែងពន្លះសាច់ គួរយកសំណល់រឹងដែលប្រឡាក់លើផ្ទៃនានាចេញដោយកោសជុសច្រាស ឬបូមធូលីតាមដែលអាចធ្វើបាន ដោយត្រូវបាញ់ទឹកលាងសំណល់ដែលអាចមើលឃើញនៅមុនពេលលាងជម្រះជាមុន ដោយប្រើប្រាស់ទឹកដែលមានសម្ពាធទាប។
- ការប្រើប្រាស់សាប៊ូ ជួយកម្ចាត់ភាគល្អិតនៃសំណល់រឹង និងអតិសុខុមប្រាណដែលនៅជាប់នឹងផ្ទៃ បន្ទាប់ពីការដកយកសំណល់រឹងចេញ។
- ការរុះរើ បន្ទាប់ពីការសម្អាត មានជាអាទិ៍ ការសម្អាតធុង និងលាងសម្អាតឧបករណ៍សម្អាត មុនយកទៅទុកផងដែរ។ បន្ទាប់ពីការលាងសម្អាតហើយ ត្រូវធ្វើការរំងាប់មេរោគដោយទុកពេលសមស្របមុននឹងលាងសម្អាត ដោយអាស្រ័យលើប្រភេទថ្នាំរំងាប់មេរោគដែលបានប្រើនោះផងដែរ។
- គួរយកចិត្តទុកដាក់ជាពិសេសចំពោះឧបករណ៍ពន្លះសាច់ ដូចជា ម៉ាស៊ីនកាត់កកាំបិតខ្សែក្រវាត់បញ្ជូន ជាដើម ព្រោះវាអាចពិបាកក្នុងការសម្អាត និងការរំងាប់មេរោគ។
- គួរធ្វើការថែទាំ និងសម្អាតឧបករណ៍ បរិក្ខារ ឬម៉ាស៊ីន ឱ្យបានទៀងទាត់ព្រោះភាគច្រើនវាប៉ះពាល់ផ្ទាល់ជាមួយ ឈាម ជាលិកា និងវត្ថុរាវផ្សេងទៀតពីសាកសពសត្វ។

## ក្រោយការសម្អាត និងក្រោយការរំងាប់មេរោគ

- គួរជៀសវាងការចម្លងភ្នាក់ងារបង្ករោគ ដោយធានាថា សម្ភារៈលាងសម្អាត ដូចជា ច្រាស់អាចម៍ដែក និងក្រណាត់ជូតត្រូវរក្សាឱ្យស្អាត ក្រោយដំណើរការសម្អាត និងរំងាប់មេរោគ។ គួររក្សាទុកឧបករណ៍ទាំងនោះឱ្យបានត្រឹមត្រូវ។
- ក្រោយការតម្លើងសម្ភារៈសម្អាត ការយកសំណល់រឹងចេញ ការលាងជម្រះជាមុនដោយប្រើទឹក ការលាងដោយប្រើសាប៊ូ បន្តដោយការលាងជម្រះ និងការសម្អាតនៅក្រោយពេលលាងជម្រះ ត្រូវតែមានដំណើរការក្រោយប្រព្រឹត្តកម្មដែលពាក់ព័ន្ធនឹងការបញ្ជូនសម្ភារៈសម្អាតត្រឡប់ទៅកន្លែងដើមវិញ និងការធ្វើប្រព្រឹត្តកម្មសម្អាតទឹកដែលនៅសល់ពីការលាងសម្អាត និងការរំងាប់មេរោគ។



© FAO/T. Dejyong

# ៦ | ការចិញ្ចឹមសត្វឡើងវិញ ក្នុងបរិវេណមានមេរោគ និងមានការប៉ះពាល់ដ៏គ្រោះថ្នាក់

- បន្ទាប់ពីការកំណត់អត្តសញ្ញាណបរិវេណនៃកន្លែងមានមេរោគ និងដែលមានការប៉ះពាល់ដ៏គ្រោះថ្នាក់ ត្រូវពិឃាតជ្រូកទាំងអស់នៅក្នុងនោះទាំងមូលភ្លាមៗ បន្តដោយនីតិវិធីនៃការកំចោលសាកសព និងកំចាត់មេរោគឱ្យបានសមស្រប (Penrith et al., 2013; Skaarup, 1985)។
- ត្រូវតែទុកចោលបរិវេណនៃកន្លែងមានមេរោគ និងដែលមានការប៉ះពាល់ដ៏គ្រោះថ្នាក់ យ៉ាងហោចណាស់ ៤០ ថ្ងៃ ប្រសិនបើបរិវេណនោះ គ្មានជាប់ពាក់ព័ន្ធនឹងភ្នាក់ងារចម្លងណាមួយ។
- ក្រោយផុតរយៈពេលកំណត់សម្រាប់ការពិឃាតជ្រូកចោល និងក្រោមការត្រួតពិនិត្យរបស់មន្ត្រីបសុពេទ្យ កសិករអាចការចិញ្ចឹមសត្វក្នុងកសិដ្ឋានរបស់ខ្លួនឡើងវិញ ដោយដាក់ជ្រូកដែលមានសុខភាពល្អ និងគ្មាន ASF។
- មន្ត្រីបសុពេទ្យត្រូវតែបង្ហាញ ជាមួយភាពប្រាកដប្រជាសមហេតុផលថា បរិវេណនៃកន្លែងដែលមានមេរោគ និងដែលមានការប៉ះពាល់ដ៏គ្រោះថ្នាក់ពីមុនទាំងនេះ លែងមានហានិភ័យនៃមេរោគ ASFV ទៀតហើយ។
- មន្ត្រីបសុពេទ្យអាចដាក់ជ្រូកសង់ទីណែល ក្នុងកម្រិត ១០% នៃសមត្ថភាពស្តុកធម្មតាក្នុងបរិវេណទាំងនេះ ដើម្បីកាត់បន្ថយហានិភ័យនៃការកើតមាន ASFV ឡើងវិញ។ នៅកន្លែងដែលពុំអាចធ្វើបែបនេះបាន គួរអនុញ្ញាតឱ្យកសិករទិញជ្រូកសង់ទីណែលក្នុងចំនួនណាមួយ ទៅតាមលទ្ធភាពរបស់ពួកគាត់។
- មន្ត្រីបសុពេទ្យត្រូវធ្វើការតាមដាន ជ្រូកសង់ទីណែលទាំងនេះ យ៉ាងហោចណាស់ប្រាំមួយសប្តាហ៍ នៅក្រោមការឃ្លាំមើលសត្វសង់ទីណែល ដើម្បីធានាថា ជ្រូកទាំងនេះគ្មានមេរោគ ASFV មុនអនុញ្ញាតឱ្យដាក់សត្វចិញ្ចឹមធម្មតាឡើងវិញឱ្យពេញសមត្ថភាពនៃកន្លែងនោះ។
- បន្ទាប់ពីការចិញ្ចឹមសត្វឡើងវិញ គួរបន្តការឃ្លាំមើលនៅក្នុងបរិវេណទាំងនេះ សម្រាប់រយៈពេលសមរម្យមួយ អាស្រ័យលើគោលបំណងរបស់ជាតិក្នុងការត្រួតពិនិត្យជំងឺ ASF។
- ត្រូវដាក់តែជ្រូកមកពីតំបន់ ឬប្រទេសដែលគេដឹងថា គ្មាន ASF ប៉ុណ្ណោះសម្រាប់ការចិញ្ចឹមសត្វពេញលេញឡើងវិញ បន្ទាប់ពីរយៈពេលឃ្លាំមើលសង់ទីណែល។
- ត្រូវធ្វើការវាយតម្លៃហានិភ័យនៃការបញ្ចូលជំងឺសត្វឆ្លងដែនផ្សេងទៀត ដើម្បីធានាថា នឹងគ្មានជំងឺផ្សេងទៀតមកជំនួស ASFV ឡើយ។
- ជាយុទ្ធសាស្ត្រកែលម្អផលិតកម្ម ភាគីពាក់ព័ន្ធអាចប្រើការចិញ្ចឹមសត្វឡើងវិញ ជាឱកាសមួយដើម្បីធានាថា កសិករក្នុងមូលដ្ឋានធ្វើការកែលំអពូជជ្រូករបស់ខ្លួន ដោយទិញជ្រូករស់ពីកសិដ្ឋានពាណិជ្ជកម្ម ដែលមានពូជជ្រូកគ្មានមេរោគ ASFV។

## នីតិវិធីនៃការចិញ្ចឹមសត្វឡើងវិញ

- មន្ត្រីបសុពេទ្យគួរពិនិត្យមើលស្ថានភាព និងហានិភ័យនៃការកើតមានមេរោគ ASFV ក្នុងមូលដ្ឋាន មុននឹងបន្ធូរបន្ថយការត្រួតពិនិត្យ ASFV ជាបណ្តើរៗ និងការរឹតបន្តឹងលើការចិញ្ចឹមសត្វឡើងវិញនៅក្នុងបរិវេណដែលមានមេរោគ និងមានការប៉ះពាល់ដ៏គ្រោះថ្នាក់។ គេអាចធ្វើបែបនេះជាដំណាក់កាល ក្នុងរយៈពេលយ៉ាងតិច ៦ខែ ដែលអនុញ្ញាតឱ្យមានការចិញ្ចឹមសត្វឡើងវិញនៅក្នុងបរិវេណដែលមានការប៉ះពាល់ បន្ទាប់មកអនុញ្ញាតឱ្យចិញ្ចឹមសត្វឡើងវិញតាមក្រោយ នៅក្នុងបរិវេណដែលមានមេរោគ។
- មន្ត្រីបសុពេទ្យត្រូវមានទំនុកចិត្តថា មានហានិភ័យតិចតួចប៉ុណ្ណោះនៃការកើតជំងឺ ASF ឡើងវិញ នៅក្នុងការវាយតម្លៃកន្លែងដែលមានឆ្លងមេរោគ និងកន្លែងមានការប៉ះពាល់ដ៏គ្រោះថ្នាក់ មុនពេលអាចអនុញ្ញាតឱ្យចិញ្ចឹមសត្វឡើងវិញ។
- ជានិច្ចកាល ត្រូវចិញ្ចឹមសត្វឡើងវិញដោយដាក់ជ្រូកសង់ទីណែល មុនធ្វើការចិញ្ចឹមសត្វពេញលេញឡើងវិញ នៅក្នុងបរិវេណនានា ដែលហានិភ័យនៃការកើត ASFV ឡើងវិញស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន។ ការធ្វើបែបនេះត្រូវអនុវត្តយ៉ាងតិច ៤០ ថ្ងៃក្រោយបានកំចាត់មេរោគ (FAO 2017)។ ដូចដែលបានបញ្ជាក់ពីខាងដើម ចំនួនជ្រូកសង់ទីណែលដែលប្រើ គួរអាស្រ័យលើកម្រិតដែលមន្ត្រីពេទ្យសត្វ និង/ឬកសិករអាចទិញបាន (ប្រសិនបើមានកិច្ចព្រមព្រៀងរួមគ្នា) និងសមត្ថភាពនៃការចិញ្ចឹមធម្មតានៃបរិវេណនោះ។
- ជាផ្នែកនៃគម្រោងផ្តល់សំណង មន្ត្រីបសុពេទ្យ ឬនាយកដ្ឋានពាក់ព័ន្ធ អាចរ៉ាប់រងថ្លៃចំណាយលើជ្រូកសង់ទីណែល ជំនួសឱ្យការផ្តល់ប្រាក់សំណង បន្ទាប់ពីបានពិឃាតជ្រូកក្នុងកន្លែងនោះ។
- តាមធម្មតា គេអាចរក្សាពូជនៃជ្រូកសង់ទីណែលនៅក្នុងបរិវេណនៃកសិដ្ឋានលក្ខណៈគ្រួសារបាន ជាមួយជ្រូកដែលបានដាក់ថ្មី ដែលជាផ្នែកមួយការចិញ្ចឹមសត្វឡើងវិញ ទៅតាមវគ្គនីមួយៗ ប្រសិនបើជ្រូកទាំងនោះគ្មានមេរោគ ASFV បន្ទាប់ពីផុត រយៈពេលតាមដានឃ្លាំមើលសង់ទីណែល។ ទោះជាយ៉ាងណាក៏ដោយ ត្រូវរក្សាជ្រូកទាំងនោះក្នុងកន្លែងដាច់ពីគ្នា យ៉ាងហោចណាស់ ៣០ ថ្ងៃ។
- មន្ត្រីបសុពេទ្យ គួរពិចារណាបញ្ចូលការតាមដានឃ្លាំមើលជ្រូកសង់ទីណែល ទៅក្នុងទម្រង់ខ្លះនៃគម្រោងផ្តល់សំណងដែលជាផ្នែកនៃការត្រួតពិនិត្យការចិញ្ចឹមសត្វឡើងវិញ។
- សត្វជ្រូកសង់ទីណែល ត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងឃ្លាំមើលជាប្រចាំ នៅក្នុងអំឡុងពេលឃ្លាំមើលជ្រូកសង់ទីណែលដោយអ្នកថែទាំ ដែលបានទទួលការបណ្តុះបណ្តាល ហើយនៅចុងរយៈពេលនេះ មន្ត្រីបសុពេទ្យត្រូវធ្វើតេស្តវត្តមានមេរោគ ASFVលើជ្រូកទាំងនេះ ដែលត្រូវតែបង្ហាញលទ្ធផលអវិជ្ជមាន។
- នៅក្នុងស្ថានភាព ASFV ដែលការស៊ើបអង្កេតនៅក្នុងបរិវេណនោះ បានបង្ហាញថាចៃតុកកែ

គឺជាភ្នាក់ងារចម្លងរោគ ក្នុងករណីនេះត្រូវធ្វើការរឹតត្បិតលើការចិញ្ចឹមសត្វឡើងវិញ រហូតដល់មន្ត្រីបសុពេទ្យបានលុបបំបាត់ទាំងស្រុងនូវបៃតុកកែនិងភ្នាក់ងារចម្លងរោគដទៃទៀតចេញពីកន្លែងនោះ។

- មន្ត្រីបសុពេទ្យ ត្រូវតែអាចបង្ហាញថា ការគំរាមកំហែងបណ្តាលពីការកើតឡើងវិញនៃ ASFV មានត្រឹមតិចតួច។
- ការរឹតត្បិតលើការចិញ្ចឹមសត្វឡើងវិញ នៅកន្លែងដែលមានមេរោគ ASF និងដែលមានការប៉ះពាល់ដ៏គ្រោះថ្នាក់ គួរអាចលុបចោល តែក្នុងករណីដែលបានកំចាត់មេរោគទាំងអស់នោះ បានអនុវត្តការឃ្លាំមើលសង់ទីណែល និងបានសម្រេចថា ហានិភ័យនៃការឆ្លងឡើងវិញមានត្រឹមកម្រិតទាបសមរម្យតែប៉ុណ្ណោះ។

## ជ្រូកសង់ទីណែល

ក្នុងករណីសេវាបសុពេទ្យជាតិមានលទ្ធភាព គេអាចដាក់ជ្រូកសង់ទីណែល ជាផ្នែកមួយនៃនីតិវិធីការចិញ្ចឹមសត្វឡើងវិញ នៅក្នុងគម្រោងរួមនៃការឃ្លាំមើល និងការផ្តល់សំណង។ នៅពេលអនុវត្តវិធីនេះ មន្ត្រីបសុពេទ្យត្រូវតាមដានជ្រូកសង់ទីណែល ដោយមានជំនួយពីអ្នកថែទាំនិងកសិករចិញ្ចឹមលក្ខណៈគ្រួសារ យ៉ាងហោចណាស់ ៤៥ ថ្ងៃ ក្រោមការតាមដានឃ្លាំមើលជ្រូកសង់ទីណែល ដើម្បីធានាថា ជ្រូកទាំងនោះគ្មានមេរោគ ASFV មុនពេលអនុញ្ញាតឱ្យដំណើការចិញ្ចឹមសត្វ ក្នុងបរិវេណនោះឡើងវិញ។ វិធានការនេះបង្កើនទំនុកចិត្ត អំពីអវត្តមាននៃ ASFV នៅក្នុងកន្លែងរក្សាទុកជ្រូក។ ទោះយ៉ាងណាក៏ដោយ គេត្រូវធ្វើតេស្តលើឈាមជ្រូកទាំងនោះ នៅចុងបញ្ចប់នៃការតាមដានឃ្លាំមើលសង់ទីណែល។ ការពិចារណាក្នុងការដាក់ជ្រូកសង់ទីណែល មានជាអាទិ៍៖

- មន្ត្រីបសុពេទ្យត្រូវកំណត់រយៈពេលសមរម្យសម្រាប់ការដាក់ជ្រូកសង់ទីណែល។ ប្រសិនបើរកមិនឃើញសញ្ញា ASFV ទេ នៅក្នុងអំឡុងពេលនោះ គួរអនុញ្ញាតឱ្យមានការចិញ្ចឹមសត្វឡើងវិញការពេញសមត្ថភាពឡើងវិញ។
- មន្ត្រីបសុពេទ្យត្រូវបញ្ជាក់គុណភាព និងប្រភពជ្រូកសង់ទីណែលដែលប្រើប្រាស់។ ជ្រូកទាំងនោះអាចត្រូវបានបង្កាត់ពូជក្នុងស្រុក ពីក្រុមហ៊ុនបង្កាត់ពូជជ្រូក ឬ ប្រភពអន្តរជាតិ។
- មន្ត្រីបសុពេទ្យត្រូវកំណត់ចំនួនអប្បបរមានៃកូនជ្រូក ដែលត្រូវប្រើក្នុងបរិវេណនីមួយៗ ដើម្បីអាចរកឃើញភាគល្អិត ASFV ដែលមានជីវិត នៅក្នុងបរិវេណទាំងនោះ។ គេអាចដាក់ជ្រូកទាំងនេះក្នុងអត្រា ១០% ភាគរយនៃសមត្ថភាព ចិញ្ចឹមសត្វឡើងវិញក្នុងបរិវេណនោះ។
- ជ្រូកសង់ទីណែលដែលត្រូវប្រើ ត្រូវបង្ហាញលទ្ធផលអវិជ្ជមានក្នុងកាធ្វើតេស្តអង្គបដិបក្ខ ASFV ឬ បានមកដោយផ្ទាល់ពីបរិវេណដែលគ្មាន ASF ជាមួយនឹងជីវសុវត្ថិភាពកម្រិតខ្ពស់ ដូចជាទ្រុងដែលគ្មាន ASF។
- មន្ត្រីបសុពេទ្យ ត្រូវតាមដាន ASFV ដែលរួមទាំង ការធ្វើតេស្តឈាមជាចុងក្រោយ លើជ្រូក

សង់ទីណៃល យ៉ាងហោចណាស់ ៤៥ ថ្ងៃបន្ទាប់ពីការមកដល់នៃជ្រូកសង់ទីណៃលចុងក្រោយមកក្នុងបរិវេណនោះ។

- ការចិញ្ចឹមសត្វឡើងវិញដោយដាក់ជ្រូកសង់ទីណៃលទៅតាមវគ្គ នៅក្នុងបរិវេណណាមួយ គួរតែបានអនុវត្តការតាមដាន ក្នុងរយៈពេល ២០ ថ្ងៃ ដោយមិនអាចអនុញ្ញាតឱ្យមានការបញ្ចូលនៅវគ្គបន្ទាប់ មកក្នុងបរិវេណនោះទៀតទេ។
- មន្ត្រីបសុពេទ្យ និងកសិករម្ចាស់សត្វ ឬអ្នកពាក់ព័ន្ធ ត្រូវពិភាក្សារួមគ្នា អំពីការចំណាយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជ្រូកសង់ទីណៃល ដែលរួមទាំង ការធ្វើតេស្តទាំងអស់។ មន្ត្រីបសុពេទ្យអាចចាត់ចែងឱ្យអ្នកផ្គង់ផ្គត់ជ្រូក បង្កើនផលិតកម្មទ្វេដង សម្រាប់ការចិញ្ចឹមសត្វឡើងវិញ បន្ទាប់ពីផុតរយៈពេលតាមដានឃ្លាំមើលសង់ទីណៃល។ ការធ្វើបែបនេះនឹងកាត់បន្ថយតម្រូវការប្រាក់សំណង បន្ទាប់ពីការពិឃាតជ្រូកអស់ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យ ASFV និងកាត់បន្ថយយ៉ាងច្រើននូវចន្លោះពេលរវាង ការពិឃាតជ្រូក និងការចិញ្ចឹមសត្វឡើងវិញ។


© FAO/B. Simon

# ៧ | អនាគត នៃនិរន្តរភាពជីវសុវត្ថិភាព ASFV

អនុសាសន៍សម្រាប់ការអនុវត្តល្អផ្នែកជីវសុវត្ថិភាពសម្រាប់ ASFV នៅតាមកសិដ្ឋាន ដែលមានចែងក្នុងឯកសារនេះ ព្យាយាមឆ្លុះបញ្ចាំងភាពស្មុគស្មាញនៃការចិញ្ចឹមលក្ខណៈគ្រួសារ និងខ្សែសង្វាក់តម្លៃនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទោះជាយ៉ាងណាក៏ដោយក្នុងស្ថានភាពជាក់ស្តែង ខ្សែសង្វាក់តម្លៃសាច់ជ្រូកមានភាពខុសប្លែកគ្នារវាងតំបន់រដ្ឋបាល និងសូម្បីតែភូមិនានា ហើយអាចងាយរងគ្រោះដោយសារការប្រែប្រួលស្ថានភាពជំងឺក្នុងមូលដ្ឋាន ក៏ដូចជា ដោយសារកត្តាមនុស្សផងដែរ។ ដូច្នេះ ប្រការចាំបាច់គឺត្រូវចាត់ទុកថា នេះជាឯកសាររស់ ហើយអនុសាសន៍ដែលបានស្នើឡើង គឺជាកម្មវត្ថុនៃការសាកល្បងលទ្ធភាពអនុវត្ត សម្រាប់ការកែលម្អឥតឈប់ឈរ ស្របតាមវិទ្យាសាស្ត្រល្អបំផុតដែលមាន និងការយល់ដឹងកាន់តែប្រសើរឡើងអំពីសេដ្ឋកិច្ចសង្គមនៅក្នុងមូលដ្ឋាន។ ការពិចារណាជាក់លាក់ក្នុងការធ្វើឱ្យឯកសារនេះ រួមបញ្ចូលការគិតគូរសម្រាប់អនាគត ជាអាទិ៍៖

## ១ ការលើកអនុសាសន៍ថ្មី ឬ អនុសាសន៍កែសម្រួល

ជានិច្ចកាល ការកែប្រែនូវការអនុវត្តលើផ្នែកជីវសុវត្ថិភាពទូទៅ និងធ្វើឱ្យអនុសាសន៍ទាំងនេះមានភាពជាក់ស្តែង និងជាក់លាក់ចំពោះការត្រួតពិនិត្យ ASFV សម្រាប់ការអនុវត្តក្នុងប្រព័ន្ធចិញ្ចឹមលក្ខណៈគ្រួសារ គឺជាការលំបាក។ ដូច្នេះមន្ត្រីបសុពេទ្យ គួរចូលរួមជាមួយអ្នកពាក់ព័ន្ធ នៅក្នុងប្រព័ន្ធចិញ្ចឹមសត្វលក្ខណៈគ្រួសារ ដើម្បីព្យាយាមវាយតម្លៃការយល់ដឹង អនុលោមភាព និងឧបសគ្គក្នុងចំណោមពួកគាត់ ដែលធ្វើឱ្យការទទួលយកអនុសាសន៍ជីវសុវត្ថិភាពមានការយឺតយ៉ាវ។ ការស្នើឱ្យមានវិធីសាស្ត្រកម្រិតតំបន់សម្រាប់ត្រួតពិនិត្យ ASF គួរតែអាចជួយឱ្យកិច្ចការនេះធ្វើទៅបាន តាមរយៈវិធីសាស្ត្រពហុជំនាញនៅក្នុងការស្រាវជ្រាវដែលអង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលរួមចំណែកផ្តល់មូលនិធិដល់ស្ថាប័នបសុពេទ្យក្នុងតំបន់ សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍការបង្ការ និងការត្រួតពិនិត្យ ASFV។

## ២ ការកសាងសមត្ថភាពសម្រាប់ពង្រឹងជីវសុវត្ថិភាព

បន្ថែមពីលើអនុសាសន៍សម្រាប់បន្តការបណ្តុះបណ្តាលដល់កសិករលក្ខណៈគ្រួសារ និងអ្នកពាក់ព័ន្ធក្នុងខ្សែសង្វាក់តម្លៃ ក្នុងគោលបំណងបង្កើនការទទួលយកអនុសាសន៍ស្តីពីជីវសុវត្ថិភាព មន្ត្រីបសុពេទ្យ អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល គួរជួយឱ្យបុគ្គលិកបំរើសេវាបសុពេទ្យ បានទទួលការបណ្តុះបណ្តាលសមស្រប និងមានបុគ្គលិកប្រកបដោយសមត្ថភាព ដើម្បីឆ្លើយតបនឹងតម្រូវការនៃការពង្រឹងជីវសុវត្ថិភាព និងការពង្រីកសេវាផ្សព្វផ្សាយ។ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅខ្វះអ្នកជំនាញបសុពេទ្យ

និងអ្នកជំនាញក្នុងមូលដ្ឋាន ដូច្នេះគួរមានគម្រោងបណ្តុះបណ្តាលដែលអាចអនុញ្ញាតឱ្យសាធារណជនទូទៅ ចុះឈ្មោះបំពេញការងារជាអ្នកផ្តល់សេវាសុខភាពសត្វសហគមន៍។

អនុសាសន៍ដែលបានលើកឡើងក្នុងឯកសារនេះភាគច្រើនផ្តោតចំបញ្ហាហើយក្នុងករណីខ្លះទៀត គាំទ្រតាមរូបភាពសមរម្យ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីបង្កើនប្រសិទ្ធភាព និងបង្កើនការទទួលយក គេត្រូវការជាចាំបាច់នូវបុគ្គលិកសុខភាពសត្វសហគមន៍ ដែលបានទទួលការបណ្តុះបណ្តាល តំណាងមកពីអង្គការក្រៅរដ្ឋាភិបាល និងអ្នកគ្រប់គ្រងកសិដ្ឋានក្នុងកិច្ចសន្យា ឬ អ្នកម៉ៅការ និងសហគមន៍ផលិតកម្មផ្សេងទៀត ដើម្បីអប់រំកសិករលក្ខណៈគ្រួសារ តាមរយៈការអនុវត្តបង្ហាញនៅតាមកសិដ្ឋាន។ ចំណុចទាំងនេះអាចកើតមានឡើងនៅក្នុងអំឡុងពេលពិភាក្សាក្រុមគោលដៅ និងសិក្ខាសាលាបណ្តុះបណ្តាល។ ការប្រើប្រាស់កសិករដែលមានបទពិសោធន៍ល្អ ធ្វើជាជនគំរូ និងអនុញ្ញាតឱ្យធ្វើការបង្ហាញជាក់ស្តែងនៅក្នុងភូមិ អំពីរបៀបដែលពួកគេកំពុងអនុវត្តជាក់ស្តែងនូវអនុសាសន៍ដែលលើកឡើងក្នុងឯកសារនេះ អាចផ្តល់ប្រយោជន៍យ៉ាងច្រើន។ មន្ត្រីបសុពេទ្យគួរទទួលបាននូវការលើកទឹកចិត្តឱ្យផ្តួចផ្តើមការចងក្រងជាឯកសារអំពីការអនុវត្តល្អ ដូចដែលបានស្នើឡើងនៅក្នុងគោលការណ៍ណែនាំទាំងនេះ ពីប្រទេសផ្សេងទៀត នៅក្នុងតំបន់នេះ ក្នុងទម្រង់វីដេអូខ្លីដែលមានចំណងជើងសម្រាប់ការផ្សព្វផ្សាយក្នុងចំណោមកសិករចិញ្ចឹមសត្វលក្ខណៈគ្រួសារ។

## ៣ បង្កើតការយល់ដឹង

ក្នុងន័យនេះ អនុសាសន៍ខាងលើស្តីពីការអនុវត្តបង្ហាញ រួមចំណែកក្នុងការបង្កើតការយល់ដឹង។ ទោះជាយ៉ាងណាក៏ដោយ ដោយសារការបង្ការ និងត្រួតពិនិត្យ ASFV គិតគូរពីកត្តាមនុស្សផ្សេងទៀតទាំងអស់នៅក្នុងមូលដ្ឋានផងដែរ ដូច្នេះប្រការសំខាន់គឺ ត្រូវបង្កើតការយល់ដឹងក្នុងចំណោមសាធារណជនទូទៅ អំពីផលប៉ះពាល់នៃ ASFV មកលើសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងវិធានការដែលមានស្រាប់ ដើម្បីការពារមេរោគ ASFV។ មន្ត្រីបសុពេទ្យគួរប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងសាធារណៈ ក្នុងអំឡុងពេលការជួបជុំសាសនា ការជួបជុំសង្គម ការផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងផ្ទាំងព័ត៌មានដើម្បីបង្កើតការយល់ដឹងអំពីមេរោគ ASFV នៅក្នុងភូមិនានា។ ការផ្សព្វផ្សាយនេះអាចផ្តោតលើកត្តាហានិភ័យជាក់លាក់ ប៉ុន្តែគួរពិចារណាផ្តោតលើតួអង្គផ្សេងទៀតទាំងអស់ តាមខ្សែសង្វាក់តម្លៃសាច់ជ្រូកលក្ខណៈគ្រួសារផងដែរ។ មន្ត្រីបសុពេទ្យមិនត្រូវមើលស្រាលលើឥទ្ធិពលនៃប្រព័ន្ធព័ត៌មានសង្គមមកលើអាកប្បកិរិយាសង្គមឡើយ និងគួរប្រើប្រាស់មធ្យោបាយនេះឱ្យអស់លទ្ធភាព តាមរយៈរូបភាពទាក់ទាញ និងអត្ថបទខ្លីៗ។

ការយល់ដឹងទាំងនេះពីការណែនាំស្តីពីជីវសុវត្ថិភាពដែលជាក់លាក់ចំពោះ ASFV ក៏នឹងរួមចំណែកដល់ការគ្រប់គ្រងជំងឺជ្រូកផ្សេងទៀតដែលកើតមានតាមមូលដ្ឋានផងដែរ

ដែលនាំឱ្យមានការកែលម្អជាទូទៅ នូវផលិតភាព និងរបរចិញ្ចឹមជីវិតរបស់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ។

## ៤ ការបង្កើតតារាងត្រួតពិនិត្យសង្ខេបសម្រាប់កសិករលក្ខណៈគ្រួសារធ្វើការវាយតម្លៃដោយខ្លួនឯង

ជីវសុវត្ថិភាពនៅតាមកសិដ្ឋាន ទាមទារឱ្យមានកិច្ចប្រឹងប្រែងជាប្រចាំនៃអ្នកចិញ្ចឹមជ្រូក។ គួរកត់សំគាល់ថា កសិករលក្ខណៈគ្រួសារភាគច្រើន អាចពុំបានទទួលការគាំទ្រគ្រប់គ្រាន់ពីអ្នកជំនាញបសុពេទ្យឡើយ ដោយសារធនធានមានកម្រិត ឬពុំមានសេវាកម្មនេះ។ ដូច្នេះ ការវាយតម្លៃដោយខ្លួនឯងអំពីជីវសុវត្ថិភាពក្នុងកសិដ្ឋាន នឹងជួយកាត់បន្ថយគម្លាតនេះ តាមរយៈការផ្តល់តារាងត្រួតពិនិត្យសង្ខេប។

បច្ចុប្បន្ន មានតារាងត្រួតពិនិត្យសម្រាប់ការវាយតម្លៃដោយខ្លួនឯងខ្លះមកហើយ អំពីជីវសុវត្ថិភាពក្នុងផលិតកម្មសាច់ជ្រូក។ ទោះជាយ៉ាងណាក៏ដោយ តារាងត្រួតពិនិត្យទាំងនោះភាគច្រើន ត្រូវបានរចនាឡើងសម្រាប់ កសិដ្ឋានខ្នាតធំ ហើយអាចលំបាកយកមកអនុវត្តក្នុងកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ។ ដោយផ្អែកលើអនុសាសន៍សំខាន់ៗក្នុងឯកសារនេះ ការងារបន្ថែមទៀតដែលត្រូវធ្វើ គឺការបង្កើតតារាងត្រួតពិនិត្យសង្ខេបសម្រាប់កសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារធ្វើការវាយតម្លៃដោយខ្លួនឯង។ ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មៃប្រឌិត ដើម្បីបង្កើតតារាងត្រួតពិនិត្យដែលងាយស្រួលប្រើ គឺជាកម្មវត្ថុដែលគួរតែស្វែងយល់ជាបន្ថែមក្នុងពេលអនាគត ដូចជា ការប្រើប្រាស់កម្មវិធីលើទូរស័ព្ទដៃ ឬការឆ្លើយតបក្នុងទំនាក់ទំនងជាសំឡេង (IVR)។


© FAO/R. Willis

# ឯកសារយោង

**Animal Health Australia.** 2020. Response strategy: African swine fever. 5. (available at https://www.animalhealthaustralia.com.au/our-publications/ausvetplan-manuals- and-documents/)

**Bellini, S., Rutili, D., & Guberti,** V. 2016. Preventive measures aimed at minimizing the risk of African swine fever virus spread in pig farming systems. Acta Veterinaria Scandinavica, 58(1751-0147 (Electronic)). (available at https://actavetscand.biomedcentral.com/articles/10.1186/s13028-016-0264-x).

**Chenais, E., Sternberg-Lewerin, S., Boqvist, S., Liu, L., LeBlanc, N., Aliro, T., Stahl, K**. 2017. African swine fever outbreak on a medium-sized farm in Uganda: biosecurity breaches and within-farm virus contamination. ***Trop Anim Health Prod,*** 49(2), 337-346. doi:10.1007/s11250-016-1197-0

**Correia-Gomes, C., Henry, M.K., Auty, H.K., & Gunn, G. J.** 2017. Exploring the role of small-scale livestock keepers for national biosecurity-The pig case. ***Prev Vet Med,*** 145(1873-1716 (Electronic)), 7-15. doi:10.1016/j.prevetmed.2017.06.005

**Deka, R.P., Grace, D., Lapar, M.L. and Lindahl, J.** 2014. Sharing lessons of smallholders' pig system in South Asia and Southeast Asia: A review. ***Paper presented at the National Conference on Opportunities and Strategies for Sustainable Pig Production, Guwahati, India.*** (available at https://hdl.handle.net/10568/53928)

**Delsart, M., Pol, F., Dufour, B., Rose, N., & Fablet, C.** 2020. Pig farming in alternative systems: strengths and challenges in terms of animal welfare, biosecurity, animal health and pork safety. Agriculture, 10(7). doi:10.3390/agriculture10070261

**Department of Environment Food and Rural Affairs, UK.** 2020. Disease control strategy for African and classical swine fever in Great Britain. (available at https://assets.publishing.service. gov.uk/government/uploads/system/uploads/attachment_data/file/877081/disease-control- strategy-csf-2020a.pdf)

**European Commission.** 2020. Strategic approach to the management of African swine fever for the EU. (available at https://ec.europa.eu/food/sites/food/files/animals/docs/ad_control- measures_asf_wrk-doc-sante-2015-7113.pdf)

**FAO.** 2009. Preparation for of African swine fever contingency plans. (available at http://www.fao.org/3/i1196e/i1196e.pdf)

**FAO.** 2010. Good practices for biosecurity in the pig sector – Issues and options in developing and transition countries.

**FAO.** 2012. Swine Health Management. In (Vol. 3). Bangkok.

**FAO.** 2017. African swine fever: Detection and diagnosis. A manual for veterinarian.

**FAO.** 2020. FAO Regional Conference for Asia and the Pacific – Report on African swine fever in Asia and the Pacific. (available at http://www.fao.org/3/nb742en/NB742EN.pdf)

**FAO,** AU-IBAR, & ILRI. 2017. Regional strategy for the control of African swine fever in Africa. (available at http://www.fao.org/3/cb2118en/cb2118en.pdf)

**Food Standards Agency (FSA).** 2020. Home slaughter of livestock: A guide to the law in England and Wales. (available at https://www.food.gov.uk/sites/default/files/media/ document/home-slaughter-guide-england-and-wales-september-2020-.pdf)

**Jurado, C., Martinez-Aviles, M., De La Torre, A., Stukelj, M., de Carvalho Ferreira, H. C., Cerioli, M., Bellini, S.** 2018. Relevant measures to prevent the spread of African swine fever in the European Union do mestic pig sector. Front Vet Sci, 5(APR), 77. doi:10.3389/fvets.2018. 00077

**Levis, D. G., & Baker, R. B.** 2011. Biosecurity of pigs and farm security: University of Nebraska–Lincoln Extension.

**Matsuzaki, S., Azuma, K., Lin, X., Kuragano, M., Uwai, K., Yamanaka, S., Tokuraku, K.** 2021. Farm use of calcium hydroxide as an effective barrier against pathogens. Sci Rep. 11(1):7941. doi: 10.1038/s41598-021-86796-w. https://www.nature.com/articles/s41598-021-86796-w.pdf.

**National Bureau of Agricultural commodity and Food Standards – Ministry of Agriculture and Cooperatives, Thailand.** 2006. Good manufacturing practices for pig abattoir. Thai Agricultural Standard. TAS 9009-2006. (available at https://www.acfs.go.th/standard/download/eng/pig_abattoir.pdf)

**OIE.** 2017. Technical item I – How to implement farm biosecurity: the role of government and private sector. **Paper presented at the 30th Conference of the OIE Regional Commission for Asia, The Far East and Oceania, Putrajaya, Malaysia.** (report of the conference available at https://rr-asia.oie.int/en/events/30th-conference-of-the-oie-regional-commission-for-afeo/)

**OIE.** 2019a. Terrestrial Animal Health Code. Chapter 4.4 Zoning and compartmentalisation. (available at https://www.oie.int/en/what-we-do/standards/codes-and-manuals/terrestrial- code-online-ac cess/?id=169&L=1&htmfile=chapitre_zoning_compartment.htm)

**OIE.** 2019b. Terrestrial Animal Health Code. Chapter 15.1 Infection with African swine fever virus. (available at https://www.oie.int/en/what-we-do/standards/codes-and-manuals/ terrestrial-code-online-ac cess/?id=169&L=1&htmfile=chapitre_asf.htm)

**OIE.** 2019c. Terrestrial Animal Health Code. Glossary. (available at https://www.oie.int/en/what- we-do/standards/codes-and-manuals/terrestrial-code-online-access/?id=169&L=1&htmfile=- glossaire.htm)

**OIE.** 2019d. Technical disease cards: African swine fever. (available at https://www.oie.int/en/ disease/african-swine-fever/)

**Penrith, M. L., Vosloo, W., Jori, F., & Bastos, A. D.** 2013. African swine fever virus eradication in Africa. ***Virus Res,*** 173(1), 228-246. doi:10.1016/j.virusres.2012.10.011

**Roubík, H., Mazcancová, J., Phung, L.D., Banout, J.** 2018. Current approach to manure management for small-scale Southeast Asian farmers – Using Vietnamese biogas and non-biogas farms as an example. ***Renewable Energy,*** 115, 362-370. https://doi.org/10.1016/j.renene.2017.08.068

**Secure Pork Supply (SPS).** 2019. Self-assessment checklist for enhanced pork production biosecurity: Animals with outdoor access. (available at https://www.securepork.org/ Resources/SPS-Biosecurity-Checklist-for-Animals-with-Outdoor-Access.pdf)

**Skaarup, T.** 1985. Slaughterhouse cleaning and sanitation. (available at http://www.fao.org/3/ x6557e/X6557E00.htm#TOC)

**USDA & CFSPH.** 2016. Foreign animal disease preparedness & response plan. (available at http://www.cfsph.iastate.edu/pdf/fad-prep-nahems-guidelines-biosecurity)

**Wirtanen, G., & Salo, S.** 2014. Cleaning and disinfection. In Meat In spection and Control in the Slaughterhouse (pp. 453-471).

# សទ្ទានុក្រម

**ជីវសុវត្ថិភាព Biosecurity**
បណ្តុំនៃវិធានការគ្រប់គ្រង និងវិធានការអនុវត្តផ្សេងៗ ដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យនៃចម្លងជំងឺ ការកកើតជំងឺ និងការរីករាលដាលនៃជំងឺសត្វ ការឆ្លងមេរោគ ឬការបំបែកខ្លួនរបស់មេរោគ ក្នុងហ្វូងសត្វមួយ ឬពីហ្វូងសត្វមួយទៅហ្វូងសត្វមួយទៀត។

**ការពិឃាតសត្វ Culling**
ការកំចាត់/ពិឃាតហ្វូងសត្វចេញពីតំបន់ណាមួយជាក់លាក់ ដើម្បីគ្រប់គ្រង ឬទប់ស្កាត់ការរីករាលដាលនៃជំងឺ។

**ថ្នាំរំងាប់មេរោគ Disinfectant**
សារធាតុគីមី ដែលត្រូវបានប្រើសម្រាប់បំផ្លាញភ្នាក់ងារបង្កជំងឺក្រៅសារពាង្គកាយសត្វ។

**ការរំងាប់មេរោគ Disinfection**
នីតិវិធីដែលមានបំណងបំផ្លាញភ្នាក់ងារបង្កជំងឺសត្វ ដែលអនុវត្តចំពោះ ទីក្នុងបរិវេណឆ្លងជំងឺសត្វ យានជំនិះ និងវត្ថុផ្សេងៗដែលអាចមានការឆ្លងមេរោគដោយផ្ទាល់ ឬដោយប្រយោល។

**ការកំទេចចោល Disposal**
ការប្រមូលយកចេញនូវសាច់សត្វ កំទេចកំទី និងសម្ភារៈពាក់ព័ន្ធផ្សេងទៀតតាមវិធានអនាម័យ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ។

**ទឹកក្រោមដី Groundwater**
ទឹក ដែលមានក្រោមស្រទាប់ដី។

**បរិវេណឆ្លងមេរោគ Infected premises**
កន្លែងមួយ ដែលអាចជាទីតាំងទាំងមូល ឬដោយផ្នែក ដែលមានសត្វឆ្លងជំងឺ ASF ឬមានវត្ថុមាន ASF ឬមានការសង្ស័យថាមានវត្ថុមានមេរោគ ASFV ក្រោមកម្មវត្ថុនៃការសម្រេចចិត្តរបស់មន្ត្រីបសុពេទ្យ។

**សារធាតុរាវកខ្វក់ Leachate**
សារធាតុរាវមិនស្អាត/កខ្វក់ដែលកើតចេញពីការរលាកសពសត្វរលួយ និងដែលអាចជ្រាបចូលទៅក្នុងដី។

**បរិវេណ Premises**
ដីមួយកន្លែង រួមបញ្ចូលទាំង អគារ ឬកសិដ្ឋាន ឬទីដាច់ដោយឡែកដែលមានដំណើរការដោយសេវាកម្មផ្សេងៗ និងបុគ្គលិកមួយក្រុម។

**ការជួសជុលឡើងវិញ Remediation**
ការជួសជុលស្ថានភាពនៅទីតាំងណាមួយ ដើម្បីស្តារ ឬបញ្ឈប់ការប៉ះពាល់បរិស្ថាននៅទីនោះ។

**ជ្រូកសង់ទីណែល Sentinel pigs**
ជ្រូកដែលគេដឹងពីស្ថានភាពសុខភាព នឹងដាក់ពិនិត្យតាមដាន រកមើលវត្តមានជំងឺណាមួយជាក់លាក់ (ដូចជា ASFV)។

**សត្វងាយរងគ្រោះ Susceptible animals**
សត្វដែលអាចឆ្លងជំងឺណាមួយជាក់លាក់ (ឧទាហរណ៍ ASF) ។

**ភ្នាក់ងារចម្លងមេរោគ Vector**
សារពាង្គកាយមានជីវិត (ឧ. អាកត្រូប៉ូដ) ដែលអាចចម្លងភ្នាក់ងារបង្ករោគ (ឧ. ASFV) ពីសត្វមួយទៅសត្វមួយទៀត។

ការតាមដាន និងឃ្លាំមើល
ជំងឺប៉េសជ្រូកអាហ្វ្រិក

ការពិឃាត និង
កំទេចបោលជ្រូកឈឺ
នៅពេលផ្ទុះជំងឺប៉េស្តជ្រូក
អាហ្វ្រិក

សុវត្ថិភាពកសិដ្ឋាន ការ
ពិឃាតសត្វ និង
ការចិញ្ចឹមសត្វឡើងវិញ

ការអនុវត្តវិធីសាស្ត្រខ្សែ
សង្វាក់ផ្គត់ផ្គង់ស្អាតសម្រាប់
ជំងឺប៉េស្តជ្រូកអាហ្វ្រិក នៅ
ក្នុងការចញ្ចឹមជ្រូក
លក្ខណៈគ្រួសារ

ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច

FAO-RAP@fao.org
fao.org/asiapacific

**Food and Agriculture Organization of the United Nations**

ភ្នំពេញ កម្ពុជា

ISBN 978-92-5-137979-0

CB9187KM/1/07.23